# ការតស៊ូខ្មែរ ប្រឆាំងនឹង យួនកុម្មុយនិស្ត
## ១៩៧០-១៩៩០



Lon Nol (center) in 1970. Photo by Denis Cameron.
Courtesy: Marc Cameron

ឧប សៅ សង្ហា

## មាតិការឿង


អារម្មកថា 1

សេចក្តផ្តើម 3

បុព្វហេតុ នៃសង្គ្រាម ឆ្នាំ ១៩៧០ 5

ការទទួលខុសត្រូវ របស់ សម្តេច សីហនុ 10

ភ្លើងសង្គ្រាម 14

ការតស៊ូ របស់ សាធារណរដ្ឋខ្មែរ (១៩៧៥-១៩៧០) 21

នៅមានបន្ត 50

*Sirik Matak et Lon Nol*



# អារម្ភកថា

ក្រោយពីបានអាន ឯកសារ ជាភាសាខ្មែរ នៃស្ថានទូត សហរដ្ឋអាមេរិក នៅកម្ពុជា មានចំណងជើងថា «ខួបលើកទី៦០ នៃទំនាក់ទំនង ការទូត រវាង សហរដ្ឋអាមេរិក (ស.រ.អ.) នឹង កម្ពុជា៖ ១៩៥០-២០១០។ ស.រ.អ. បានសរសេរដោយសង្ខេបថា សាធារណរដ្ឋ ចាញ់សង្រ្គាមដោយសារ លោក លន់-នល់ ជាអ្នកដឹកនាំ គ្មានសមត្ថភាព ដឹកនាំសង្រ្គាមប្រឆាំងនឹង យួនកុម្មុយនិស្ត និង ខ្មែរក្រហម។

ក្នុងនាមខ្ញុំជាកូនខ្មែរម្នាក់ ខ្ញុំមានការសោកស្តាយជាអនេក នូវការសង្ខេបនេះ ហាក់បីដូចជា ស.រ.អ. មិនអើពើនឹង ពលិកម្ម កូនខ្មែរ រាប់ម៉ឺននាក់ ចូលធ្វើសង្រ្គាម ជាមួយកងទ័ព អាមេរិកាំង ទប់ទល់នឹង វិត្ថាកម្ម កម្លាំង កុម្មុយនិស្ត យួន/ចិន នៅក្នុងដំបន់ឥណ្ឌូចិន។ ម្យ៉ាងមួយទៀត នៅក្នុងទស្សនៈ នេះ ហាក់បី ស.រ.អ. គ្មានទទួលខុសត្រូវបន្តិចបន្តួចសោះ ក្នុងបរាជ័យ កងទ័ពសាធារណរដ្ឋខ្មែរ និង យៀកណាមខាងត្បូងដែលជា សម្ពន្ធមិត្ត របស់ខ្លួន ក្នុងការប្រយុទ្ធ ប្រឆាំងនឹង កម្លាំងកុម្មុយនិស្ត។

តែទោះបី ស.រ.អ. ទុកឈាមកូនខ្មែរ ដែលបានបូជាជីវិត នៅក្នុងសមរភូមិ ដើម្បីការពារឧត្តមគតិ នៃមនុស្សជាតិ គឺ **សេរីភាព** កំរិតត្រឹមតែ អសមត្ថភាព លោក លន់-នល់ ក៏កូនខ្មែរនៅតែអគុណ ដល់ ស.រ.អ. ដែលបានផ្តល់ជំនួយ ទោះបីតិចតួចក្តី ដើម្បីឲកូនខ្មែរបង្ហាញ នូវសេចក្តីក្លាហាន របស់ខ្លួន ក្នុង សមរភូមិ ច្បាំងទប់ទល់ នៃការឈ្លានពានដល់បូរណភាពទឹកដីខ្មែរ ពីសំណាក់ យួនកុម្មុយនិស្ត ដោយបានទទួលជំនួយគ្មានកំរិតពី ប្លុក លោកកុម្មុយនិស្ត។

ការសាកល្បង សរសេរ របស់ខ្ញុំនេះ គ្មានមានគោលបំណង តបត ឬ ប្រឆាំងនឹង ទស្សនៈ ជាផ្លូវការ របស់ស.រ.អ. ពាក់ព័ន្ធនឹង មរណភាព នៃសាធារណខ្មែរ នោះឡើយ តែគ្រាន់តែជាការបញ្ចេញមតិមួយ សំរាប់ រំលឹក វិញ្ញាណក្ខន្ធ កូនខ្មែរ ដែលបានបូជាជីវិតក្នុង សមរភូមិ ដើម្បី ការពារជាតិខ្មែរ និង សេរីភាព ដោយមានជំនឿជាក់ច្បាស់ក្នុងចិត្តថា ស.រ.អ. ជាមិត្តដ៏ល្អមួយនឹង ប្រជាពលរដ្ឋខ្មែរ ដែលស្រឡាញ់ សេរីភាព និង លទ្ធិប្រជាធិបតេយ្យ។

ប្រជាពលរដ្ឋខ្មែរ បច្ចុប្បន្ន មានតែស្វាគមន៍ ដល់ ការវិលត្រឡប់ នៃមិត្តដ៏ល្អ របស់ខ្លួនមកកម្ពុជា ក្នុង ការទំនាក់ទំនង ជាថ្មី ផ្អែកលើគោលគំនិត សមភាព និង ភាតរភាព។ សូមអធិដ្ឋាន ដល់ទេព្តា រក្សា ទឹកដីខ្មែរ ឲជួយថែរក្សា មិត្តភាព ប្រទេស និង ប្រជា

ពលរដ្ឋ ទាំងពីរ ឲបានគង់វង់ ជានិច្ច។ ខ្មែរម្នាក់ៗ ទុក ពលរដ្ឋអាមេរិកាំងម្នាក់ៗជា អនុរាគតា[1] ចំពោះខ្លួន ក្នុងឋានៈ ជា អតិថិ[2] របស់ ស្រុកខ្មែរ ដែលជាមិត្ត នឹង ស.រ.អ.។

[1] អនុរាគតា= Personne bienvenue។
[2] អតិថិ= ភ្ញៀវកិត្តិយស ; Hôte។



# សេចក្ដីផ្ដើម

ខ្មែរយើង តែងតែរំលឹកជានិច្ចថា ប្រទេសខ្មែរ ធ្លាប់ជា ប្រទេសមហាអំណាច នៅក្នុងដំបន់អាស៊ីភាគអគ្នេយ៍ ដោយមាន ប្រវត្តិសាស្ត្រ ជារូបភាពក្ដី ជាចំណេរក្ដី បញ្ជាក់បង្ហាញ នូវពលានុភាពជាតិ ដែលបុព្វបុរសខ្មែរ ទុកឲ ជាមរតក។ តែ ការពិតបច្ចុប្បន្ន បានបង្ហាញនូវកង្វះ នៃសមត្ថភាពខ្មែរ សំរាប់ថែរក្សា សម្បត្តិមរតកជាតិ ឲបានគង់វង់ ដែលនាំឲប្រទេសខ្មែរ ក្លាយជាប្រទេសទុនខ្សោយបំផុត នៅចំពោះមុខ ប្រទេសជិតខាងខ្លួន។

អំពើប្រល័យពូជសាសន៍ ដោយខ្មែរខ្លួនឯង មានកើតឡើងក្នុង ទស្សវត្សរ៍ទី ៧០ ក្នុងរបបខ្មែរក្រហម លើក ជាបញ្ហា សីលធម៌ ចំពោះខ្មែរយើង ដែល ជាអ្នកពុទ្ធសាសនានិយមព្រោះ អំពើដែលមានកើតឡើងនោះ ជាអំពើឃោរឃៅហួសហេតុដែលកម្រមាននៅក្នុងប្រវត្តិសាស្ត្រ នៃមនុស្សជាតិ។ អំពើប្រល័យពូជសាសន៍នេះ ក៏បាននាំឲ សហគមន៍អន្តរជាតិ ខសួរ លើ សមញ្ញា[3] នៃនិមិត្តរូប នៃមនុស្សខ្មែរ ជា «មនុស្សញញឹម» ដែល វាមានភាព ផ្ទុយស្រឡះពី «ខ្មែរ+ក្រហម» ដែលជា «មនុស្សយង់ឃ្នង» ប្រព្រឹត្តអំពើឧក្រឹដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

ថ្ងៃទី ៧ មករា ឆ្នាំ ១៩៧៩ បង្ហាញ នូវទុព្វលភាព នៃប្រជាជាតិខ្មែរ ធ្វើការទប់ទល់នឹងការឈ្លានពានជាថ្មី ដោយកម្លាំងទ័ព ពីសំណាក់ យៀកណាម។ តើ នរណា ជាអ្នកទទួលកំហុស នៅមុខបរាជ័យ នេះ ? បើយោង តាមការពិសោធ ម៉ឺនឆ្នាំរបស់ប្រជាជាតិខ្មែរ នៅចំពោះមុខ មហិច្ឆតា យៀកណាម គេអាចទុក បរាជ័យនេះ ជា បរាជ័យ ដ៏ចម្លែកមួយ ដែលខ្មែរយើងមិនអាចជឿបាន ដែលនាំដំណើរជាតិខ្មែរ ឲដើរវិលត្រឡប់ មកក្នុងសតវត្សទី១៩ វិញ ក្នុងឆ្នាំ ១៨៣៥ ដែល យៀកណាម បានតែងតាំង ព្រះអង្គម្ចាស់ក្សត្រីអង្គ-មៃ (១៨៣៥-១៨៤១) ជា ព្រះមហាក្សត្រីខ្មែរ ហើយបន្ទាប់មក ដាក់បញ្ចូលស្រុកខ្មែរ ជាខេត្ត យៀកណាម តែម្ដង។ ផលប៉ះពាល់ នៃ ថ្ងៃទី ៧ មករា មកលើ ប្រជាជាតិខ្មែរ មានភាពជាក់ស្ដែង គឺ ប្រជាពលរដ្ឋខ្មែរ អាចរួចចេញ ពី អបាយ[4] នៃរបបខ្មែរ

[3] សមញ្ញា= Réputation។
[4] អបាយ= កន្លែង នៃទុក្ខវេទនា ; Lieu de souffrance។

ក្រហមពិតប្រាកដ តែក៏ត្រឡប់ធ្លាក់ចូល ទៅក្នុង រូងទ្រុង យៀកណាម រស់ជា អនុប្រជាជន នៅក្នុងមហាយៀកណាម ដែលជា សហព័ន្ធឥណ្ឌូចិនថ្មី អង្គាអរូបី[5] មាន អទិដ្ឋហត្ថ[6] ដែលខ្មែរយើង ហៅថា ដៃទី៣ សំរាប់ លួចធ្វើឃាត ជនខ្មែរ និង ជនលាវ ជាអ្នកស្នេហាជាតិ ដើម្បីរកអត្ថប្រយោជន៍ ឲប្រជាជនយួន ដែល យៀកណាម គេទុក ជា ប្រជាជន មាន អគ្គភាព នៅក្នុងដំបន់ឥណ្ឌូចិន។ ការរំដោះ កម្ពុជា ដោយ យៀកណាមជា ការរំដោះ រកប្រយោជន៍ផ្ទាល់ខ្លួន ដែលជាបំណងពាន់ឆ្នាំ ផ្ចិតជាប់ ក្នុងសតិយៀកណាម។

55 អង្គាអរូបី= Corps invisible។
66 អទិដ្ឋហត្ថ= ដៃគ្មានរូប ; main invisible។



# បុព្វហេតុ នៃសង្គ្រាម ឆ្នាំ ១៩៧០

តើ សង្គ្រាម នៅប្រទេសយៀកណាម ជាបុព្វហេតុ នៃសង្គ្រាម នៅកម្ពុជា ?

ប្រទេសកម្ពុជា រស់នៅក្បែរសង្គ្រាម នៅយៀកណាម អស់រយៈច្រើនទស្សវត្សរ៍មកហើយ តាំង ពីសង្គ្រាម បារាំង ជា មួយ កងកម្លាំងទ័ពបដិវត្ត កុម្មុយនិស្តយួន ផ្តើមកើតឡើង ក្នុងទស្សវត្សរ៍ទី ៤០ រហូត មកដល់ សង្គ្រាម រវាង យៀកណាម ខាងត្បូង ដែលមាន ស.រ.អ. ជាសម្ពន្ធមិត្ត ចូលរួមធ្វើសង្គ្រាម ក្នុងទស្សវត្សរ៍ទី ៦០ ប្រឆាំងនឹង រណសិរ្សជាតិរំដោះ យៀកណាម ខាងត្បូង ហៅថា យៀកកុង ដែលជា សាខាយោធា នៃ សាធារណរដ្ឋសង្គម និយម នៃយៀកណាមខាងជើង ដែលមាន លោកកុម្មុយនិស្ត មានជាអាទិ សហភាពសូវៀត និង ចិនប្រជាមានិត ជាអ្នកផ្តល់ជំនួយ គ្រប់បែបយ៉ាង។ សង្គ្រាមនៅយៀកណាម នេះ ជាសង្គ្រាម មួយ នៅក្នុង សង្គ្រាមត្រជាក់ រវាង ប្លុកលោកសេរី នឹង ប្លុកលោកកុម្មុយនិស្ត ក្រោយពីសង្គ្រាមលោក លើកទី២។ ចំពោះ លោកសេរី យៀកណាម ជាច្រកចូល នៃលទ្ធិកុម្មុយនិស្ត ក្នុងដំបន់ អាស៊ីភាគអគ្នេយ៍ មានប្រទេស សៀម ភូមា លាវ កម្ពុជា និង យៀកណាម។ បើ យៀកណាម ដួល ដោយខ្យល់កុម្មុយនិស្ត គឺវានឹងនាំឲប្រទេស នៅក្នុងដំបន់អស៊ីភាគអគ្នេយរ៍ ដួលបន្តបន្ទាប់គ្នាជាពុំខាន ដូចជា «ល្បែកដូមីណូ» នេះឯង។ ទស្សនះ នេះ បានត្រូវ ស.រ.អ. យកមកធ្វើជាទ្រឹស្តីនយោបាយ ទុក លទ្ធិកុម្មុយនិស្ត ជាអភិទ្រោះ (គំរាម) នៅអាស៊ី។ ក្រោយពី សន្និសិទ នៅទីក្រុង ស៊ីណែវ (២១ កក្កដា ១៩៥៤) នៅ ថ្ងៃទី ៨ កញ្ញា ១៩៥៤ នៅទីក្រុង ម៉ានិល នៃប្រទេស ហ្វីលីពិន ប្លុកលោកសេរី បានបង្កើត អង្គការការពាររួម មួយ មានឈ្មោះថា «អង្គការ នៃសន្ធិសញ្ញា នៃ ប្រទេស អាស៊ី ភាគអគ្នេយ៍» (SEATO)។ អង្គការនេះ មានគោលដៅទប់ទល់នឹង ការវាតទី នៃកម្លាំងកុម្មុយនិស្ត នៅតណ្ឌូចិន និង ដំបន់ អាស៊ីទាំងមូល។

សង្គ្រាម ត្រជាក់ រវាង ប្លុកលោកសេរីនឹង ប្លុកលោកកុម្មុយនិស្ត នាំបង្កើត ឲមាន ក្រុមប្រទេស មិនចូលប្លុកណាមួយ ប្រមូលផ្តុំឡើង នៃបណ្តាប្រទេស ដែលទើបតែបានឯករាជ្យពីអាណានិគមនិយម មានសេដ្ឋកិច្ចទន់ខ្សោយ។ អង្គការនេះ ជា ប្លុកទី៣ ដែលមានឈ្មោះថា ប្លុកតតិយលោក។ ប្រទេសកម្ពុជា នៅក្រោមនយោបាយ សម្តេច សីហនុ បានជ្រើសរើស មាគា នយោបាយ ការបរទេស របស់ខ្លួន ដោយប្រកាន់យក គោលជំហរ អព្យាក្រិតភាព ហើយ បានចូលធ្វើជាសមាជិក នៃក្រុមមិនចូលប្លុកណាមួយ។ ដើម្បីរកតុល្យាភាព នៃនយោបាយការបរទេស នៅក្នុង ឆ្នាំ ១៩៥៧ សម្តេច សីហនុ សម្រេចចិត្ត ទទួលជំនួយ សេដ្ឋកិច្ច ពីសំណាក់ប្រទេសចិនប្រជាមានិត បន្ថែមលើជំនួយ អាមេ

វិកាំង ដែលប្រទេសកម្ពុជា បានទទួលយក តាំងពីឆ្នាំ ១៩៥៥។ របត់ នយោបាយ នេះ នាំបង្កើតឲមានបញ្ហាស្មុកស្មាញជាច្រើន នៅក្នុងទំនាក់ទំនង ជាមួយ ស.រ.អ. ដែលកំពុងដើរតួ ជាមេដឹកនាំ ប្រឆាំងនឹង កុម្មុយនិស្ត នៅក្នុងពិភពលោក។ ការរំកិល កាន់តែខ្លាំងៗ នៃប្រទេស កម្ពុជាទៅរក ប្រទេសចិនប្រជាមានិត តម្រូវឲ សម្តេច សីហនុ គាំទ្រមិនចេញមុខ ដល់កម្លាំងតស៊ូយួនកុម្មុយនិស្ត នៅប្រទេសវៀតណាមខាងត្បូង។ ទំនោរ នេះ នាំបង្កើតឲមាន ភាពតានតឹង ជាមួយ សាធារណរដ្ឋ វៀតណាមខាងត្បូង ដែលកំពុងតែទទួលការវាយប្រហារ ពីកម្លាំងកុម្មុយនិស្តយួន។

ចាប់ពីឆ្នាំ ១៩៦៣ សង្គ្រាម នៅវៀតណាម កាន់តែមានសន្ទុះខ្លាំងឡើងៗ រវាង កងទ័ពវៀតណាមខាងត្បូង នឹង វៀតកុង ដែលនាំឲមានការរាលដាលនៅតាមព្រំដែនខ្មែរ-វៀតណាមខាងត្បូង នាំឲកងកម្លាំងទ័ពវៀតណាមខាងត្បូង ចូលមកក្នុងទឹកដីខ្មែរ ដើម្បីតាមវាយប្រហារ វៀតកុង ដែលរត់ចូលមកពួន។ នៅចំពោះមុខបញ្ហានេះ សម្តេច សីហនុ បានសុំជំនួយយោធាបន្ថែម ពី ស.រ.អ. ដើម្បីពង្រឹង និង កែទម្រង់កងទ័ពខេមរភូមិន្ទខ្មែរ ឲទំនើប តែព្រះអង្គ ក៏បានស្នើទៅចិនប្រជាមានិត សុំជំនួយ ផ្នែកយោធាបន្ថែមលើផ្នែកសេដ្ឋកិច្ចដែរ។ លើសពីនេះ ព្រះអង្គបានស្នើ ដល់ ស.រ.អ. ឲជួយរៀបចំ ឲមានសន្និសិទអន្តរជាតិមួយ ដើម្បី រកការធានា និង ការគោរព បូរណភាពទឹកដីខ្មែរ។ តែសំណើរ នេះមិនមានការគាំទ្រពី ស.រ.អ. ដោយសំអាងថា វាគ្មានប្រសិទ្ធភាព ជ្រើនជាង ការពង្រឹងទំនាក់ទំនង ជាទ្វេភាគី រវាង កម្ពុជា នឹង ស.រ.អ. នោះទេ តែទោះបីយ៉ាងណា តាមលិខិត លោក ប្រធានាធិបតី Kennedy លោក បានបញ្ជាក់ដល់ សម្តេច សីហនុ នូវការគោរព និង ធានា ការពារ បូរណភាពទឹកដីខ្មែរ ពី ស.រ.អ.។ ឧប្បត្តិហេតុ កើតមានក្នុងឆ្នាំ១៩៦៣ គឺ ការវាយប្រហារ ភូមិខ្មែរមួយ ពីសំណាក់ កងកម្លាំងទ័ព វៀតណាម ខាងត្បូង នាំឲសម្តេច សីហនុ បញ្ចប់ នៅខែសីហា ទំនាក់ទំនងតាមផ្លូវទូត ជាមួយ សាធារណរដ្ឋ វៀតណាមខាងត្បូង។ ក្រោយពីលោកប្រធានាធិបតី Kennedy ត្រូវបានគេធ្វើឃាតលោក ទំនាក់ទំនង រវាង ស.រ.អ. នឹង កម្ពុជា មានការចុះអន់ថយកាន់តែខ្លាំងឡើងរហូត ដល់ សម្តេច សីហនុ មើលងាយ សពលោក អតីតប្រធានាធិបតី ស.រ.អ. ថាជា «ចៅហ្វាយធំ នៃពួកអ្នកឈ្លានពាន»។

ឧប្បត្តិហេតុ នៅឈូងសមុទ្រ តុងកឹង រវាងកងនាវា អាមេរិក នឹង វៀតណាមខាងជើង នៅក្នុងឆ្នាំ ១៩៦៥ នាំពង្រីក សមរភូមិ នៃសង្គ្រាម នៅវៀតណាម គឺការសម្រេចចិត្ត របស់ ស.រ.អ. ធ្វើការទម្លាក់គ្រាប់បែប នៅ វៀតណាមខាងជើង ដែល ស.រ.អ. តែងតែទុកប្រទេសនេះ ជាចៅហ្វាយផ្ទាល់ នៃពួកវៀតកុង។ លើសពីនេះ ស.រ.អ.បានបញ្ជូនកងទ័ពជើងគោក មកកាន់ ប្រទេសវៀតណាមខាងត្បូង ដើម្បីជួយច្បាំងកងទ័ពវៀតណាមសេរី ប្រឆាំងនឹង កងទ័ព វៀតកុង។ នៅចំពោះមុខស្ថានភាពថ្មីនេះ នៅ

ខែ ឧសភា សម្តេច សីហនុ បានបញ្ឈប់ ទំនាក់ទំនងទូត ជាផ្លូវការ ជាមួយ ស.រ.អ. ហើយ អនុញ្ញាត ជាសម្ងាត់ ឲពួកយៀកកុង ចូលមកក្នុងទឹកដីខ្មែរ ដើម្បីបង្កើតមូលដ្ឋាន ក្រោយ នៃកងទ័ព សំរាប់គាំទ្រ សមរភូមិមុខ នៅ យៀកណាមខាងត្បូង។ ចំនួនយោធា យៀកកុង មកតាំងទី នៅក្នុងស្រុកខ្មែរ មាន ប្រមាណ ៦ម៉ឺននាក់ រីឯ កងទ័ពខេមរភូមិន្ទខ្មែរ វិញ មានចំនួនតែ ៣ម៉ឺននាក់តែប៉ុណ្ណោះ។ យៀកកុង បានបន្តផ្លូវលំ ហូជីមិញ ចូលមកក្នុងស្រុកខ្មែរ សំរាប់ដឹកជញ្ជូន ជំនួយយោធា ពីសំណាក់ អង្គការយោធា ហ្វាសូវី ចេញពី កំពង់ផែ កំពង់សោម ឆ្ពោះទៅកាន់ សមរភូមិ នៅយៀកណាមខាងត្បូង។ តាមឯកសារ ប្រទេសកម្ពុជា យកជាកម្រៃ ១០% ពីចំនួនជំនួយនេះ។ ប៉ុន្តែនៅពេលនោះ យៀកកុង គេយក ប្រទេសកម្ពុជា ជាមូលដ្ឋានសេដ្ឋកិច្ច សំរាប់ ទ្រទ្រង់ រណសិរ្សរបស់គេ។ តាមឯកសារ ចំនួន ១ ភាគ ៤ នៃផលិតផលស្រូវខ្មែរ ត្រូវបាន យៀកកុង ទិញយក ទៅចិញ្ចឹមកងទ័ពគេ ដែលកំពុងបំពេញបេសកកម្មសឹក នៅយៀកណាមខាងត្បូង។ ដើម្បីវាយបំផ្លាញមូលដ្ឋានយោធាយៀកកុង នៅកម្ពុជា លោកប្រធានាធិបតីអាមេរិក Lyndon Johnson បានអនុញ្ញាតិ ឲកងទ័ពអាមេរិកាំង ធ្វើប្រតិបត្តិការសឹកសំងាត់ចូលមកក្នុងទឹកដីខ្មែរ។ ក្នុងឆ្នាំ ១៩៦៨ ឆ្លើយតបទៅនឹង បេសកជន នៃរដ្ឋាភិបាល ស.រ.អ.មកកម្ពុជា លោក Chaster A. Bowles ស្តិពី វត្តមានទ័ពយៀកកុង នៅកម្ពុជា សម្តេចសីហនុ ព្រះអង្គ ព្រមទទួលថាមានពិត ហើយ ព្រះអង្គបានអនុញ្ញាតិ ឲកងទ័ពអាមេរីកាំង ធ្វើប្រតិបត្តិសឹកទ្រង់ទ្រាយតូច នៅតាមដំបន់ដាច់ស្រយាល ក្នុងទឹកដីខ្មែរ ដ៏វាបណាសកម្មភាពទាំងនោះ មានកំរិតតិចតួចមែនទែន។ នៅថ្ងៃទី ២ មេសាឆ្នាំ១៩៦៩ ក្នុងនយោបាយ រកការទំនាក់ទំនង ជាថ្មី រវាង ស.រ.អ. ជាមួយ កម្ពុជា លោក ប្រធានាធិបតិ Richard M. Nixon បានប្រកាសជាឧឡារីក ទទួលស្គាល់នូវ អធិបតេយ្យភាព ឯករាជភាព អព្យាក្រឹតភាព និង បូរណភាពទឹកដី នៃរាជាណាចក្រកម្ពុជា។ ផ្ទុយទៅវិញ កងកម្លាំងកុម្មុយនិស្តយួនបានចូលមកកាន់កាប់ ១ ភាគ ៣ នៃទឹកដីខ្មែរ។ដើម្បីទប់ទល់នៃការរាតទី នេះ លោក Richard M. Nixon បានអនុញ្ញាតិ ឲកងទ័ពអាកាស ស.រ.អ. ទម្លាក់គ្រាប់បែក ដោយសំងាត់ក្នុងស្រុកខ្មែរ នៅក្នុងទីដំបន់ណា ដែលមាន មូលដ្ឋានទ័ពកុម្មុយនិស្តយួន។ ប្រតិបត្តិការសឹក នេះ មានឈ្មោះថា « Menu »។ នៅក្នុងឆ្នាំ១៩៦៩ នេះ ដែរ កម្ពុជា និង ស.រ.អ. បានមានការទំនាក់ទំនង តាមផ្លូវទូត ឡើងវិញហើយស្ថានទូត ស.រ.អ. ចាប់ផ្តើមបើក នៅកម្ពុជា ក្នុងថ្ងៃទី ១៦ សីហា។ តែ ស.រ.អ.ក៏ចាប់ផ្តើម អនុវត្ត ផែនការដកទ័ពខ្លួន ចេញពីយៀកណាមដែរ ដោយសារ ជនជាតិអាមេរីកាំង ដែលជាអ្នកប្រឆាំងនឹង សង្គ្រាម នៅយៀកណាម កាន់តែកើតចំនួនច្រើនឡើងៗ ព្រោះសង្គ្រាមនេះ កាន់តែបង្ហាញ នូវរូបភាពអាសគ្រាម ផ្សាយតាម កញ្ចក់ទូរទស្សន៍នៅ ស.រ.អ. និងនៅ បស្ចឹមប្រទេស ដែលនាំឲ មតិសាធារណជន ក្នុងពិភពលោក ផ្តន្ទាទោស តាមផ្លូវចិត្ត តាមបាតុកម្ម ប្រឆាំងនឹង នយោបាយ ស.រ.អ. នៅយៀកណាម។

មកដល់ទីនេះ យើងគួរ លើកយកគោលដៅ របស់ យួនកុម្មុយនិស្ត មកសិក្សា ដោយសួរជាសំណួរថាតើ ពួកគេចង់បានអ្វី ?

គោលដៅចម្បង របស់បក្សកុម្មុយនិស្តយួន គឺ **ឯកភាពយៀកណាម**។ យួនគេទុកជ័យជំនះ របស់គេលើ កងទ័ពបារាំង នៅក្នុងឆ្នាំ ១៩៥៤ ជា ជ័យជំនះ មិនគ្រប់គ្រាន់ ព្រោះយៀកណាមនៅតែកាត់ចែកជាពីរចំណែក ខាងត្បូង ជាយៀកណាមសេរី ខាងជើង ជាយៀកណាមកុម្មុយនិស្ត។ ដូច្នេះ បក្សកុម្មុយនិស្តយួន ត្រូវមានករណីយកិច្ច បន្តសង្គ្រាមដើម្បី បង្រួបបង្រួមយៀកណាម ឲ្យរួមតែមួយ។ នៅក្នុងគោលដៅចម្បង នេះ បក្សកុម្មុយនិស្តយួនមានគោលបំណងសំខាន់ពីរទៀត ដែលជាគោលបំណង របស់អ្នកដឹកនាំយួនតាំងពីសម័យដើមមក គឺ វិជ្ជមានកម្ម[7] នៃឯករាជ្យប្រជាជាតិយៀកណាម ទល់មុខនឹងប្រទេសចិន ហើយ តាំងពី សតវត្សទី១៦មក អ្នកដឹកនាំយួន តែងតែមាន មហិច្ឆតាខ្ជាប់ខ្ជួន ស្រូបយក ប្រទេសខ្មែរ និង លាវ បញ្ចូល ទៅក្នុងប្រទេសយួន។ តែដោយសារមានអន្តរាគមន៍ ស.រ.អ. នៅយៀកណាមខាងត្បូង ប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត តាមផ្លូវនយោបាយ និង មធ្យោបាយ យោធា នាំឲបក្សកុម្មុយនិស្ត ប្រមូលផ្តុំថាមពលខ្លួនធ្វើសង្គ្រាមឲឈ្នះ ស.រ.អ. សិន។ ដូច្នេះ ចម្បាំង ប្រឆាំងនឹង អាមេរិកាំង គ្រាន់ជា ដំណាក់ អន្តរកាល ដើរឆ្ពោះទៅ ទៅរក មហិច្ឆតា ពាន់ឆ្នាំ របស់ប្រជាជាតិយួន។ នៅចំពោះមុខមហាអំណាចពិភពលោក បក្សកុម្មុយនិស្តយួន ដើរតួខ្លួន ជា អ្នករងគ្រោះ ផង និង ជាបក្សតស៊ូ មិនចុះចាញ់ ផង ប្រើគ្រប់ កលល្បិច និង សម្ពិច (កលល្បិចលាក់មុខ) ដើម្បី ធ្វើឲ ស.រ.អ. អប្បយស ក្លាយជាប្រទេសចក្រពត្តិនិយម ឈ្លានពាន ប្រទេសទន់ខ្សោយ ដើម្បីដាក់ជាប្រទេសអាណានិគមរបស់ខ្លួន។ ក្នុង សម្ពិច នេះ បក្សកុម្មុយនិស្តយួន ទទួលបានជោគជ័យ ដូចបំណងខ្លួន គឺអាចរុញច្រាន កងទ័ពអាមេរិកាំង ឲចេញពីប្រទេសយៀកណាមបាន ដោយមិនបាច់ឈ្នះសង្គ្រាម។ ជ័យជំនះ នេះ ជាជ័យជំនះ ពេញលេញ ដែលអាចឲអ្នកដឹកនាំយៀកណាម បន្ត កលល្បិច ដើម្បី ធ្វើឲសម្រេច នូវគោលបំណង នៃមហិច្ឆិតា របស់បុព្វបុរសខ្លួន គឺស្រូបយក ប្រទេសខ្មែរ និង លាវ បញ្ចូលក្នុងប្រទេសយៀកណាម ដើម្បីឲក្លាយទៅជា មហាយៀកណាម មានឯករាជ្យ បរិបូរ នៅចំពោះមុខ មហាប្រទេសចិន។

យើងឃើញថា សង្គ្រាមនៅយៀកណាម មិនមែនជា បុព្វហេតុសំខាន់ នៃសង្គ្រាម កើតមាននៅស្រុកខ្មែរ ក្នុងឆ្នាំ ១៩៧០ នោះទេ។ **បុព្វហេតុ ពិត គឺ មហិច្ឆតា របស់បក្សកុម្មុយ**

---

[7] វិជ្ជមានកម្ម = សេចក្តីអះអាង ; Affirmation។

**និស្តយួន** ប្រើគ្រប់កលល្បិចផ្តាច់ កម្ពុជា ឲនៅតែឯង ក្នុងយុទ្ធសាស្ត្រ ស.រ.អ. ប្រឆាំងកុម្មុយនិស្ត នៅតំបន់ចិន។ ភាពឯកោ នេះ ធ្វើឲ ស្រុកខ្មែរ គ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បី ការពារខ្លួនឯង រាល់ការគំរាមកំហែង មកលើខ្លួន។ ស្រុកខ្មែរ ក្លាយជា រំពា សំរាប់យៀកណាម ចាប់ស៊ី ងាយស្រួលបំផុត នៅពេលណាដែលគេអាចចាប់ស៊ីបាន។



# ការទទួលខុសត្រូវ របស់ សម្តេច សីហនុ

នយោបាយ ការបរទេស របស់ សម្តេច សីហនុ ក្នុងទសវត្សរ៍ ទី ៦០ ទុកដូច ជាការហែរ កម្ពុជា ទាំងរស់ ទៅកាន់ អន្សាហណដ្ឋាន ឬ ក៏ចិញ្ចឹម ហ្វូងខ្លា នៅក្នុងផ្ទះខ្មែរ។ ក្រោយពី ព្រះអង្គ ដាក់រាជ្យ នៅថ្ងៃ ទី២ មិនា ឆ្នាំ១៩៥៥ ហើយ រំលំ របប ប្រជាធិបតេយ្យ បាន នៅក្នុងឆ្នាំ ១៩៥៦ តាមវិធី រដ្ឋប្រហារត្រជាក់ គឺធ្វើវិសោធនកម្ម រដ្ឋធម្មនុញ្ញ នៅថ្ងៃទី១៤ មករា ដើម្បី បំរើអំណាច របស់ព្រះអង្គ ធ្វើឲស្រុកខ្មែរ ដើរត្រឡប់ថយក្រោយវិញ ក្នុង វិស័យ អភិវឌ្ឍន៍ នៃលទ្ធិប្រជាធិបតេយ្យសេរី ដែលមានចែកច្បាស់លាស់ នៅក្នុង រដ្ឋធម្មនុញ្ញ ទី១ (១៩៤៧) របស់ ខ្មែរ។ ព្រះអង្គ បានបង្កើត ចលនា សង្គមរាស្ត្រនិយម (ស.រ.ន.) ក្នុងឆ្នាំ ១៩៥៥ ដើម្បី ចូលរួម បោះឆ្នោត ជ្រើសរើ សមាជិកសភាជាតិ ហើយ ចលនាបាន ទទួលជ័យជំនិះ។ នៅថ្ងៃ ទី១៤ មករា ឆ្នាំ ១៩៦៦ មានប្រកាសប្រើ រដ្ឋធម្មនុញ្ញថ្មី  ហើយ នៅថ្ងៃទី ៨ មករា ឆ្នាំ ១៩៥៨ សម្តេច សីហនុ ប្រកាស រំលាយ រដ្ឋសភា។ នៅថ្ងៃទី ២៩ មករា ឆ្នាំ ១៩៥៨ ចលនាសង្គមរាស្ត្រនិយម បានទទួលជោគជ័យជាលើកទី២ ក្នុងការបោះឆ្នោតថ្នាក់ជាតិ ទទួលបាន អាសនៈទាំងអស់ នៅក្នុងរដ្ឋសភាជាតិ។ នៅថ្ងៃទី១៧ធ្នូឆ្នាំ ១៩៦០ សភាទាំងពីរ (រដ្ឋសភាព និង ក្រុមព្រឹក្សាព្រះរាជាណាចក្រ) បោះឆ្នោតតែងតាំង សម្តេច សីហនុជាព្រះប្រមុខរដ្ឋ អស់មួយជាជិវិត។ នៅថ្ងៃទី ៣ មេសាឆ្នាំ១៩៦០ ព្រះមហាក្សត្រ នរោត្តមសុរាម្រិត ទ្រង់សោយព្រះទិវង្គត នៅក្នុងព្រះជន្មាយុ៦៤វស្សា។ មរណៈភាព ព្រះបិតារបស់សម្តេច សីហនុ នាំបង្កើតជាវិបត្តិ នៃស្ថាប័ន រាជានិយម ដោយសារ សម្តេច សីហនុ មិនហ៊ាន ឡើងសោយរាជសម្បត្តិ ដោយខ្លាចចាញ់សម្បថ ព្រោះព្រះអង្គ បានធ្វើសច្ចា ជាឧឡារិក ថាលែងវិលត្រឡប់មកសោយរាជ្យវិញហើយ។ តែព្រះអង្គ ក៏មិន អនុញ្ញាតិ ឲ ព្រះអង្គម្ចាស់ណាម្នាក់ ឡើងគ្រោងរាជ្យ បន្តពី ព្រះបិតា របស់ព្រះអង្គដែរ។ តាម កបិចិត្ត ជា មនុស្ស មានសេចក្តីច្រណែននាំឲ សម្តេច សីហនុ បង្កើត ស្ថាប័ន រាជានិយម ដ៏ចម្លែកមួយ គឺ រាជានិយម ឥតមានព្រះមហាក្សត្រ ដោយតែងតាំង ព្រះមាតា របស់ ព្រះអង្គ ជា រាជអភិរក្ស នៃរាជបល្ល័ង្កមានបាវចនា របប «ជាតិ សាសនា រាជបល្ល័ង្ក»។ តាមពិត រាជានិយម នេះ ជា រាជានិយមផ្តាច់ការ ព្រោះ ជាការផ្ទេរ បុព្វសិទ្ធិ ព្រះមហាក្សត្រ ថ្វាយ ដល់ សម្តេច សីហនុ ក្នុង ឋានៈព្រះអង្គជា អតីតព្រះមហាក្សត្រនិង ជា ព្រះប្រមុខរដ្ឋ អស់មួយជីវិត។

ក្រោយពី ព្រះរាជទស្សនាកិច្ច សម្តេច សីហនុ នៅសាធារណរដ្ឋ ចិនប្រជាមានិត ក្នុងឆ្នាំ ១៩៥៧ នយោបាយការបរទេសខ្មែរ បានចាប់ផ្តើមមានទំនោរ ទៅខាង លោកកុម្មុយនិស្ត ព្រោះថា ព្រះអង្គ បានទទួលស្គាល់ជាផ្លូវការ ប្រទេសចិន ប្រជាមានិត នៅខែកក្ក

ដាឆ្នាំ១៩៥៨។ ទំនោររនេះ ក៏នាំបង្កើតអោយមាន បរិយាកាកាសតានតឹងជាមួយ លោកសេរី ជាពិសេស ជាមួយ ស.រ.អ.។ បន្ទាប់ ពីការផ្តាច់ ចំណងទូត បន្តបន្ទាប់គ្នាជាមួយ យៀកណាមខាងត្បូង រាជាណាចក្រថៃឡង់ ស.រ.អ. អង់គ្លេស កូរ៉េខាងត្បូង ហើយ ដាក់ចំណងទូត ជាមួយ កូរ៉េខាងជើង យៀកណាមខាងជើង ទទួលស្គាល់ ជាផ្លូវការ រណសិរ្សរំដោះយៀកណាមខាងត្បូង នាំចោទជាបញ្ហាដល់ សទ្ធាលុភាព នៃអព្យាក្រឹតភាពខ្មែរ ដែល សម្តេច សីហនុ ទុកជា បេះដូង នៃនយោបាយការបរទេសរបស់ ព្រះអង្គ។

សួរថា តើជម្រើស ទិសថ្មី នៃនយោបាយ ការបរទេស នេះ ជា សម្ពីគិត[8] របស់ សម្តេចសីហនុ ឬ ជា កបិចិត្ត របស់ ព្រះអង្គ ? តែទោះបី នៅក្នុងគំនិតណាមួយក៏ដោយ ចំពោះជាតិខ្មែរ គឺនៅតែជា ការភាន់ច្រឡំ ជានិច្ចះ ទី១ ក្នុងឋានៈជាអ្នកដឹកនាំជាតិ ព្រោះអ្នកដឹកនាំជាតិខ្មែរ ត្រូវចាំបាច់ ស្គាល់ប្រវត្តិសាស្ត្រជាតិខ្លួន ជា កាតព្វកិច្ច ស្តីអំពី មហិច្ឆតាពាន់ឆ្នាំ នៃប្រជាជាតិយួន មកលើ ប្រជាជាតិខ្មែរ ដែលមាន ភស្តុតាងជាក់ច្បាស់ ជា មេរៀន ផង ជា អនុស្សាវរីយ៍ ដ៏ជូរចត់ សំរាប់ជាតិខ្មែរ ផង គឺ ការបត់បង់ទឹកដីទឹកដីកម្ពុជាក្រោម ; ទី២ ក្នុងឋានៈជាមនុស្ស ព្រោះខ្មែរអ្នកជា ជាមនុស្ស យក វិចារណញ្ញាណ សំរាប់ ឆ្លុះមើល ផ្លូវនៃជីវិត សំរាប់ដើរ មិនមែន យក កបចិត្ត សំរាប់ ធ្វើជា ក្បូន នៃការរស់នៅ នោះឡើយ។ ដូច្នេះ សម្តេច សីហនុ ជា អ្នកទទួលខុសត្រូវ នៃបុព្វហេតុ នៃសង្គ្រាមឆ្នាំ ១៩៧០ លើផ្ទៃនយោបាយ ផង និង សីលធម៌ ផងះ

## ការទទួលខុសត្រូវ លើផ្ទៃ នយោបាយ

អព្យាក្រឹតខ្មែរ អាចមាន តម្លៃ លើផ្ទៃ នយោបាយទូត លុះត្រាតែ ប្រទេសមហាអំណាចទាំងឡាយ គេទទួលស្គាល់ ហើយ គោរព វា។ នៅក្នុងសង្គ្រាម ត្រជាក់ ររៀង លោកសេរីនឹង លោកកុម្មុយនិស្ត ស.រ.អ. ប្រឹងប្រែង ប្រលោម ផង ធ្វើសម្ពាធ ផង ដល់ សម្តេច សីហនុ ឲព្រះអង្គ ចូលរួមក្នុងនយោបាយ «containement» គឺការទប់ ឥទ្ធពល កុម្មុយនិស្ត កុំឲរាលដាលបាន។ តែការព្យាយមនេះ មិនបានទទួល លទ្ធផលនោះឡើយ ដោយសារ សមតេច សីហនុ ព្រះអង្គ នៅតែរក្សាជានិច្ច នូវគោលជំហរ នៃអព្យាក្រឹតខ្មែរ លើឆាក អន្តរជាតិក្នុងគោលដៅ រកការគាំទ្រ ដើម្បី ទូទាត់នឹង សម្ពាធ អាមេរិក។ ចាប់ ពី ឆ្នាំ ១៩៦៣ ទៅសង្គ្រាម នៅយៀកណាមខាងត្បូង កាត់តែមានសន្ទុះខ្លាំងឡើងៗ ហើយ រាលដាលចូលមកក្នុងទឹកដីខ្មែរ ដោយសារ កងទ័ពយួនខាងត្បូង រុលចូលមកក្នុងទឹក

---

[8] សម្ពីគតិ= ការពិចារណា ជាជម្រៅ។

ដីខ្មែរ ដើម្បីតាមវាយ ពួកយៀកកុង ដែលមានជំរុំនៅក្នុង ស្រុកខ្មែរ។ ចំពោះ សម្តេច សីហនុ ឧប្បត្តិហេតុ រឿយៗ នេះ នាំឲព្រះអង្គ ទុក យួនខាងត្បូង និង អាមេរិក ជាការគំរាបកំហែង ដល់បូរណភាពទឹកដីខ្មែរ ហើយកាន់តែមានជំនឿ ទៅលើនយោបាយ របស់ព្រះអង្គ យកចិន និង យួនកម្មុយនិស្ត ជាមិត្ត និង ជាអ្នកធានា ដល់ អធិបតេយ្យភាពស្រុកខ្មែរ។ ម្យ៉ាងមួយទៀត ព្រះអង្គ មានជំនឿថា អនាគត នៃដំបន់ អាស៊ីភាគអគ្នេយ៍ នឹងធ្លាក់ទៅក្នុងកណ្តាប់ដៃ លោកកុម្មុយនិស្ត ដូច្នេះ ការយក ចិន និង យួនកុម្មុយនិស្ត ជាមិត្ត វាមានប្រយោជន៍ ដល់នយោបាយផ្ទៃក្នុងខ្មែរ គឺ កាច់ កូនដើមឈើ កុម្មុយនិស្ត ខ្មែរកុំឲវាដុះធំបាន។ ចក្ខុនិមិត្ត នេះហើយ ដែលជំរុញ ឲព្រះអង្គ អនុវត្ត អព្យាក្រឹតអកម្ម ចំពោះ ពួកយៀកកុង និង យួនខាងជើង ដែលនាំឲប៉ះពាល់ ដល់នយោបាយអព្យាក្រឹត របស់ព្រះអង្គ លើឆាកអន្តរជាតិ ជាពិសេសចំពោះ ស.រ.អ. ដែលជាកំពែងការពារសំខាន់ ទប់ទល់នឹង កម្លាំងកុម្មុយនិស្ត នៅតណ្ឌូចិន។ រហូតមកដល់ឆ្នាំ១៩៦៧ ទើប ព្រះអង្គ ចាប់ផ្តើមភ្ញាក់ខ្លួន ដោយសារមានការជ្រៀតជ្រែក ដោយចំពោះ ពីសំណាក់ ចិនកុម្មុយនិស្តក្នុងនយោបាយផ្ទៃក្នុងកម្ពុជា ព្រោះថា ចិន ជាអ្នកនៅពីក្រោយនៃការបះបោលនៅភូមិសំឡូត ដែលមាន កម្មាភិបាល កុម្មុយនិស្ត ខ្មែរ យួន ជាដឹកនាំផ្ទាល់ នៅក្រោមឪវាទចិន ។ តែការភ្ញាក់ខ្លួន របស់ព្រះអង្គ វាហួសពេលវេលា ដើម្បីស្តារ នយោបាយ ដ៏ស្មុកស្មាញ របស់ ព្រះអង្គ ជាមួយចិន និងយួនកុម្មុនិស្ត ព្រោះយៀកកុង និង យួនខាងជើង បានបញ្ចូលទ័ពមកតាំងទី នៅពាសពេញ ស្រុកខ្មែរ រួចបាត់ទៅហើយ។ ក្នុងកំលុង ឆ្នាំ ១៩៦៨ សម្តេចសីហនុ ចាប់ផ្តើម រកការទំនាក់ទំនង ឡើងវិញជាមួយ ស.រ.អ. តាមរយៈ សមាជិកព្រឹទ្ធសភាអាមេរិក លោក Mick Mansfield ដើម្បី ធ្វើការកែតម្រូវនយោបាយ អព្យាក្រឹតរបស់ព្រះអង្គ។ ការប៉ុនប៉ង របស់ សម្តេចសីហនុនេះ នាំចោទជាសំនួរ ក្នុង មជ្ឈដ្ឋាន អ្នកនយោបាយ អាមេរីកាំង។ ក្រុមទី១ យល់ឃើញថាត្រូវឆ្លៀតឪកាស ដែល សីហនុ កំពុងមាន បញ្ហាជាមួយ ចិន-យួន កុម្មុយនិស្ត ដើម្បី ធ្វើសម្ពាធតែម្តង ទៅលើព្រះអង្គ ឲប្តូរនយោបាយ មកនៅក្នុងឧបាយរួម នៃអង្គការ SEATO ទប់ទល់នឹងកុម្មុយនិស្ត នៅតណ្ឌូចិន ព្រោះ ពួកគេគ្មានជំនឿ ទៅលើរបត់របស់ព្រះអង្គ ថាគ្មានចិត្តស្មោះ ចង់ប្រឆាំងនឹង ចិន-យួន កុម្មុយនិស្ត នោះឡើយ ; ក្រុមទី២ យល់ឃើញថា ជំហរ នៃអព្យាក្រឹតភាពខ្មែរ ពិតប្រាកដ វាគ្រប់គ្រាន់ ដើម្បី អមគម(គាំទ្រ) នយោបាយ យួនរូប្បនីយកម្មនៃសង្គ្រាម នៅយៀកណាម ដូច្នេះ ស.រ.អ. មិនចាំបាច់ ស្នើឲសម្តេច សីហនុ ប្តូរនយោបាយ នៃអព្យាក្រឹតភាព របស់ព្រះអង្គ នោះទេ តែគ្រាន់តែសុំឲព្រះអង្គ អនុវត្តវា ឲបានច្បាស់លាស់ តែប៉ុណ្ណោះ។ និក្ខេបបទ នៃក្រុមទី២ នេះហើយ ដែល ស.រ.អ. យកមកអនុវត្ត ក្នុងទំនាក់ទំនងឡើងវិញតាមផ្លូវទូតជាមួយកម្ពុជា។ តាមទំនង ហាក់បីដូចជា សម្តេច សីហនុ យល់ព្រមជាមួយ ស.រ.អ. យក អព្យាក្រឹតភាពខ្មែរ ជា ពាក្យដាស់តឿនដល់ យួនកុម្មុយនិស្ត ថាព្រះអង្គ ឈប់អនុវត្ត អ

ព្យាក្រឹត អកម្ម ជាមួយពួកគេទៀតហើយ ដូច្នេះចិន-យួនកុម្មុយនិស្ត ត្រូវតែគោរពជាដាច់ខាត អធិបតេយ្យភាពស្រុកខ្មែរ។ តែក្រោយពី ព្រះអង្គវិលត្រឡប់ ពីបុណ្យសពលោក ហូ-ជីមិញ វិញ នៅទីក្រុងហាណូយ ហាក់បីដូចជា ព្រះអង្គនៅតែមានការស្ទាក់ស្ទើរ ក្នុងចិត្ត មិនអស់ចិត្តនឹង គោលជំហរថ្មី របស់ព្រះអង្គចំពោះយួនកុម្មុនិស្ត ព្រោះពួកអ្នកដឹកនាំចិនប្រជាមានិត និង យួនខាងជើង គេនាំគ្នា ពន្យល់ព្រះអង្គ អំពីគ្រោះថ្នាក់ដល់កម្ពុជា ក្នុងអនាគតកាលដ៏ខ្លី បើគ្មានលោកកុម្មុយនិស្ត ជួយទប់ទល់នឹងនយោបាយចក្រពត្តិនិយម ស.រ.អ. នៅក្នុងដំបន់អាស៊ីភាគអគ្នេយ៍ ព្រោះអាមេរិកាំង មានគ្រប់មធ្យោបាយ គឺ រដ្ឋាភិបាលខ្មែរ ដឹកនាំដោយ លោក លន់-នល់ សំរាប់ទំលាក់ព្រះអង្គ ពីដំណែង ព្រះប្រមុខរដ្ឋ។ ពាក្យដាស់តឿននេះហើយ ដែលនាំឲព្រះអង្គ មានជំនឿ នៃគម្រងការណ៍អាក្រក់មួយរបស់ C.I.A ដើម្បីទំលាក់ ព្រះអង្គ ពីអំណាច ឬ លួចធ្វើឃាតព្រះអង្គតែម្តង។

យើងឃើញថា សង្គ្រាម ដែលផ្ទុះឡើង នៅក្នុងឆ្នាំ ១៩៧០ គឺជា វិបាក នៃជម្រើសនយោបាយការបរទេស និង ចិត្តស្រាល របស់ សម្តេច សីហនុ ដែលអាច ហុចឱកាសឲយួនកុម្មុយនិស្ត វាយប្រហារ កងទ័ពជាតិខ្មែរ ដោយប្រើឈ្មោះ សីហនុ ជាអ្នកប្រកាស សង្គ្រាមស៊ីវិល នៅស្រុកខ្មែរ។ ព្រឹត្តិការណ៍ ថ្ងៃទី ១៨ មិនា ឆ្នាំ ១៩៧០ កើតមានឡើងក៏ដោយសារ សម្តេច សីហនុ ជ្រើសរើសយក ឧបាយកលយួន មកប្រឆាំងចេញមុខនឹង រាជរដ្ឋាភិបាល របស់ព្រះអង្គ ដឹកនាំដោយ លោក លន់-នល់ ដែលជា សហការីជំនិតមានភក្តីបំផុត ចំពោះព្រះអង្គ។ សង្គ្រាម បានកើតឡើងក្តី អវសាន នៃសីហនុនិយមក្តី គឺ សម្តេច សីហនុ ខ្លួនឯង ជា បង្កបង្កើតឲមានឡើង។

ការយកឧបាយកលយួនកុម្មុយនិស្ត មកធ្វើជា មធ្យោបាយ សំរាប់សងសឹង នឹងប្រជាជាតិ ខ្លួនឯង ជា កំហុស សីលធម៌ របស់ សម្តេច សីហនុ ហើយអ្នកដែករងគ្រោះ គឺប្រជាពលរដ្ឋខ្មែរ ហើយគាត់នៅតែ ទទួលរងទុក្ខវេទនាគ្រប់បែបយ៉ាង រហូតមកដល់បច្ចុប្បន្ននេះ។



## ត្បែងសង្គ្រាម

ដោយជឿល្បិច ចិន-យួន កុម្មុយនិស្ត នាំឲព្រះអង្គ មានពិភាល់ថានឹងមាន គម្រង ការណ៍អាក្រក់ របស់ C.I.A ដើម្បីទំលាក់ ព្រះអង្គ ពីអំណាច ឬ លួចធ្វើឃាតព្រះអង្គតែម្តង តាមវិធីរដ្ឋប្រហារ ពីសំណាក់ ទ្រង់ សិរិមតៈ ព្រះអង្គបានយាងចាកចេញពីស្រុកខ្មែរ យ៉ាងប្រញាប់ នៅថ្ងៃទី៦មករា ឆ្នាំ ១៩៧០ ដោយយកលេសថា ទៅពិនិត្យសុខភាព នៅប្រទេសបារាំង។ គេនៅចាំបានថា នៅថ្ងៃទី ៦ មករា ឆ្នាំ ១៩៦៧ មុនមួយខែ ផ្ទុះកុបកម្ម ខ្មែរ យៀកម៉ិញ នៅភូមិសំឡូត សម្តេច សីហនុ បានចាកចេញពីស្រុកខ្មែរទៅស្រុកបារាំង ជាប្រញាប់ ដើម្បី ទុកឲ ខ្មែរ និង យួនកុម្មុយនិស្ត ធ្វើឲជ្រួលច្របល់ នៅក្នុងស្រុក ដើម្បីអាចឲព្រះអង្គ ដាក់កំហុស លើរដ្ឋាភិបាល នៅពេលនោះដឹកនាំ លើកទី១ ដោយ លោក លន់-នល់។

ការចេញពីប្រទេសនេះ វាជា អនុភាព នៃបរាជ័យ នូវការប៉ុនប៉ង របស់ សម្តេច សីហនុ ទម្លាក់ រដ្ឋាភិបាល លោក លន់-នល់ នៅក្នុង សមាជជាតិ ទី២៨ ដែលជាសមាជាតិចុងក្រោយបង្អស់ របស់ ចលនា សង្គមរាស្ត្រនិយម ក្នុងខែ ធ្នូ ឆ្នាំ ១៩៦៩ នៅពេលនោះគ្មានវត្តមាន លោក លន់-នល់ ព្រោះលោកមានជម្ងឺ អញ្ជើញទៅ ព្យាបាលរោគ នៅប្រទេសបារាំង តាំងពីខែ តុលា មកម្លេះ។ នៅពេលអវត្តមាន លោក លន់-នល់ ទ្រង់ សិរិមតៈ ជាអ្នកដឹកនាំ រដ្ឋាភិបាល, ក្នុងឋានៈជានយករដ្ឋមន្ត្រីស្តីទី, ទ្រង់ ហ៊ានតតាំងនឹង សម្តេចសីហនុ ទោះបី សម្តេច សីហនុ ប្រើគ្រប់ មធ្យោបាយ នយោបាយ ដើម្បីរំលំ រដ្ឋាភិបាល។ លោក លន់-នល់ វិលត្រឡប់ចូលស្រុកខ្មែរ វិញ នៅថ្ងៃទី ១៨ កុម្ភៈឆ្នាំ ១៩៦៩។ នៅពេលដែល សម្តេចសីហនុ និង លោក លន់-នល់ ជួបសន្ទនាគ្នា នៅប្រទេសបារាំងមុនលោក លន់-នល់ វិលត្រឡប់ ចូលស្រុកវិញ តើ ឥស្សរជន ទាំងពីរនេះបានលើក បញ្ហាជាតិ អ្វីខ្លះ មក ពិច័យ ជាមួយគ្នា ?

នៅក្នុងរយៈពេល ដែល សម្តេច សីហនុ គង់នៅប្រទេសបារាំង នៅស្រុកខ្មែរ ក្នុងខែ មិនា ឆ្នាំ ១៩៧០ មានបាតុកម្មប្រជាពលរដ្ឋ នៅខេត្ត ស្វាយរៀង ដេញ យៀកកុង ឲចេញពីស្រុកខ្មែរ។ នៅថ្ងៃទី ១១ យុវជនខ្មែរ នៅភ្នំពេញ ធ្វើបាតុកម្ម វាយកំទេច ស្ថានទូត យៀកកុង និង យួនខាងជើង។ រដ្ឋាភិបាល ប្រញាប់ប្រញាលថ្វាយដំណឹង នេះ ដល់ សម្តេចសីហនុ តែព្រះអង្គបែរ ជាចោទដល់ រដ្ឋាភិបាល ថាជាអ្នកញុះញង់ឲមានកើតព្រឹត្តការណ៍ ដើម្បីប្រឆាំងនឹងព្រះអង្គ។ ទោះបីយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាល នៅតែខំស្វែងរកគ្រប់មធ្យោបាយ ដើម្បី ពន្យល់អំពី ស្ថានការណ៍ពិត ដែលកំពុង កើតមាននៅក្នុងស្រុក តែ សម្តេច សីហនុ បានបដិសេធ ជាដាច់ខាត មិនព្រមទទួលយកការពន្យល់របស់ រដ្ឋា

ភិបាល និង មិនព្រមទាំងទទួល ប្រតិភូខ្មែរមួយ ដែលមាតាព្រះអង្គ គ្រោងបញ្ជូនទៅជួបព្រះអង្គ ដើម្បីថ្វាយដំណឹងពិត។ មិនគ្រាន់តែបដិសេធទាំងមូល ព្រះអង្គ ថែមទាំងធ្វើការគំរាម នៅចំពោះមុខ អ្នកហែហមព្រះអង្គថា នៅពេលព្រះអង្គវិលត្រឡប់ចូលស្រុកវិញ ព្រះអង្គ នឹងបញ្ជា ឲបាញ់សម្លាប់ សមាជិក រដ្ឋាភិបាល ពីបទ ក្បត់ព្រះអង្គ។ នៅថ្ងៃទី១៦ មិនា មានបាតុកម្ម របស់យុវជនខ្មែរ នៅមុខរដ្ឋសភា ស្នើសុំឲរដ្ឋសភាជាតិ យកបញ្ហា នៃវត្តមាន ទ័ព យៀកកុង និង យួនខាងជើង នៅស្រុកខ្មែរ យកទៅដោះស្រាយជាបន្ទាន់។ ដោយហេតុថា សម្តេច សីហនុ ព្រះអង្គ ប្រកាន់ជំហរ ផ្ទុយពីប្រយោជន៍ជាតិ សភាជាតិខ្មែរ បានបោះឆ្នោត ទម្លាក់ព្រះអង្គ ពីតំណែង ព្រះប្រមុខរដ្ឋ នៅថ្ងៃទី ១៨ មិនា ១៩៧០។ បន្ទាប់មក រដ្ឋាភិបាលខ្មែរ ចាប់ផ្តើមធ្វើការចរចារជាមួយតំណាងទូត យៀកកុង និង យួនខាងជើង សូមឲគេដកទ័ពចេញពីកម្ពុជា។ មិនត្រឹមតែមិនឆ្លើយនឹងឧសានវាទ របស់ រដ្ឋាភិបាលខ្មែរ កងទ័ព កុម្មុយនិស្តយួន បានធ្វើការវាយប្រហារ កងទ័ពខ្មែរ នៅថ្ងៃទី ២៧ មិនា ឆ្នាំ ១៩៧០ តាមការប្រកាស ពីទីក្រុង ប៉េកាំង របស់ សម្តេច សីហនុ ឲជួយព្រះអង្គ ដើម្បី ដណ្តើមយកអំណាចព្រះអង្គមកវិញ។ ដូច្នេះសង្គ្រាម បានផ្ទុះឡើងនៅស្រុកខ្មែរ ដោយសារ តែ សម្តេច សីហនុ ស្រវឹងនឹង តណ្ហាអំណាច យកការសងសឹង ទៅបំរើមហិច្ឆតាពាន់ឆ្នាំយួន គឺស្រូបស្រុកខ្មែរបញ្ចូលទៅក្នុងស្រុកយួន។ សង្គ្រាមនៅឆ្នាំ១៩៧០ ជាសង្គ្រាមឈ្លានពាន ពីសំណាក់យួនកុម្មុយនិស្ត មកលើ អធិបតេយ្យជាតិខ្មែរ ដែលមាន សម្តេច សីហនុ ជា ឈ្នួញសង្គ្រាមដូរ កិត្តិយស ជាខ្មែរ យកស្រមោលសង្ឃឹមមួយ មាននៅក្នុងមហិច្ឆតាយួន គឺ លក់ទឹកដីខ្មែរ ដើម្បី ស្វែងរកអំណាចជាអ្នកបំរើយួន ដែលខ្មែរយើងហៅថា **អំណាចអាយ៉ងយួន**។ គួរកត់សំគាល់ថា យៀកកុង វាហ៊ានឈ្លានពានខ្មែរ ព្រោះ សម្តេច សីហនុ នៅក្នុង ខែ ធ្នូ ឆ្នាំ ១៩៦៩ បានព្យួរ សកម្មភាព គណកម្មការអន្តរជាតិ ពិនិត្យ ការអនុវត្ត ឲត្រឹមត្រូវ នៃ កិច្ចព្រមព្រៀង នៅទីក្រុង ស៊ីណែវ ស្តីពីសន្តិភាពនៅឥណ្ឌូចិន។ គេដឹងច្បាស់ថា ព្រះអង្គ ព្យួរ សកម្មភាពនេះ ដើម្បី ស្រួលឲយៀកកុង ប្រើទឹកដីខ្មែរ សំរាប់ ឧបត្ថម សមរភូមិ យៀកកុងនៅយួនខាងត្បូង។ នៅថ្ងៃទី ១៧ កុម្ភៈឆ្នាំ ១៩៧០ មានយន្តហោះមួយគ្រឿង ចុះចត នៅ ប្រលាន យន្តហោះ ពោធិនតុង ដឹកថ្នាំពេទ្យ សំរាប់ ប្រគល់ឲ ពួក យៀកកុង។ នេះហើយ អព្យាក្រឹតភាព របស់ សម្តេច សីហនុ !

នៅថ្ងៃទី ២៧ មិនា ឆ្នាំ ១៩៧០ ដោយគ្មានធ្វើការប្រកាសសង្គ្រាមជាមុន កងទ័ពយួនកុម្មុនិស្ត ស្ថិតនៅក្នុងដីខ្មែរស្រាប់ បានវាយប្រហារ ទីតាំងទ័ពខ្មែរ៖

ស្នួល, ជប់, មេមុត, ក្រែក, ស្អាង, កោះធំ នៅក្នុងភូមិភាគយោធា ទី១ ;

កំពង់ត្រាច នៅក្នុងភូមិភាគយោធា ទី២ ;

ក្រុង ស្ទឹងត្រែង ក្នុងភូមិភាគយោធា ទី៥ ;

ក្រុង ក្រចេះ នៅក្នុងភូមិភាគយោធា ទី៦។

ដើម្បី ឲស្រួលយល់ អំពី ស្ថានភាពកងទ័ពខ្មែរ ដែលមានឈ្មោះថា កងទ័ពខេមរភូមិន្ទ នៅពេលមុនផ្ទុះសង្គ្រាម យើង ធ្វើសង្ខេបដូចតទៅៈ

កងទ័ពជើងគោកខ្មែរ មាន កងវរសេនាតូច ៣០កង, ១៣ ទៅ ១៥ កងអនុសេនាធំ គាំទ្រ នៅក្នុងវិស័យ ស៊ើបការ, ដឹកជញ្ជូន, វិស្វកម្ម, បាញ់យន្តហោះ, កងវរសេនាធំ យកការ ១កង, កងកាំភ្លើងធំ ១កង និង អង្គភាព ពេទ្យ និង សុខាភិបាល។ ទីតាំង កងឯកភាពចម្បាំង មាននៅ ពាសពេញផ្ទៃដីជាតិ ក្នុង ខេត្ត កំពត, តាកែវ, ស្វាយរៀង, កំពង់ស្ពឺ, ភ្នំពេញ, កំពង់ចាម, កំពង់ឆ្នាំង, ក្រចេះ, ស្ទឹងត្រែង, មណ្ឌលគីរី, បាត់ដំបង, សៀមរាប, ពោធិសាត់, ស្រុក កំពង់ត្រាច, ស្រែក្តុង, កោះរោង, រមាស, ថ្មពុក, តាខ្មៅ, កោះញែក, លំផាត់, បានឡុង, វរជ័យ, ត្បែងមានជ័យ, ម៉ង តែទីតាំងធំ គឺនៅ ដំបន់ព្រៃសាន ក្នុងខេត្ត រតនគីរី និង ជុំវិញទីក្រុងភ្នំពេញ។ កងទ័ពអាកាស មានទាហានចំនួន ១ ២៥០ នាក់ មាន មូលដ្ឋានអាកាស នៅ ពោចិនតុង, កងទ័ពនាវី មានចំនួនទាហានប្រហែលនឹង កងទ័ពអាកាសដែរ មាន មូលដ្ឋានទឹកសាប នៅ ជ្រោយចង្វា និង មូលដ្ឋានទឹកសមុទ្រ នៅ រាម។ កងទ័ពខេមរភូមិន្ទ ប្រើសម្ភារៈយោធា ជម្រុះ គឺ សម្ភារៈបារាំង អាមេរិកាំង និង ចិន ដែលខ្មែរបានទទួលជំនួយ។ ការលាយចូលគ្នា នេះ បង្កើតជាបញ្ហា ដល់ ការរៀបចំ កងឯកភាពចម្បាំង។ នៅក្រោម ការដឹងនាំ របស់ សម្តេច សីហនុ ព្រះអង្គ មិនសូវយកចិត្តទុកដាក់ លើវិស័យយោធា ដែលនាំឲកងខេមរៈភូមិន្ទ គ្មានលទ្ធភាពធ្វើ ទំនើបភាវូបនីយកម្ម និង សុក្រឹតកម្ម ដែលជាគ្រោះថ្នាក់មួយ ក្នុងបេសកកម្មការពារបូរណភាពទឹកដី និង អធិបតេយ្យជាតិ។ បន្ទាប់ ពី សម្តេច សីហនុ បញ្ឈប់ទំនាក់ទំនងទូតជាមួយ ស.រ.អ. ព្រះអង្គថ្លែង ជាឧឡារិកថា ប្រទេសចិនប្រជាមានិត គេនឹងជួយជំនួយយោធាដល់កម្ពុជា ដើម្បីឲកងទ័ពខ្មែរ ក្លាយជា មហាកងទ័ពមួយ នៅក្នុងដំបន់អាស៊ី តែសេចក្តីប្រកាសនេះ គ្រាន់តែជាការបញ្ឆោតមួយ ពីសំណាក់ចិន ដល់ ព្រះអង្គតែប៉ុណ្ណោះ។ តាម លោក ឧត្តមសេនីយ សាក់-ស៊ុតសាខន អតីត អគ្គមេបញ្ជាការកងទ័ពជាតិ នៅពេលដែលយៀកកុង វាយប្រហារខ្មែរ ពភ្លាមមរណា[9] ដល់ប្រជា

[9] ពភ្លាម មរណា= ដោយចោល ពន្លឺមរណា ; En lançant des éclairs mortels។

ជាតិខ្មែរ ស្ថានភាព កងទ័ពខេមរភូមិន្ទ នៅពេលនោះ គឺដូចជា កូនក្មេងម្នាក់ កំពុងមានជម្ងឺ និង មានទោមនស្ស នៅចំពោះមុខសត្រូវ មានសុខភាពបរិបូរ។

យើងឃើញថា ចិន បោកបញ្ឆោត សម្តេច សីហនុ ហើយ ព្រះអង្គ យកការសន្យាចិន មកបោក បញ្ឆោតរាស្ត្រខ្មែរ ហើយ រាស្ត្រខ្មែរ ក៏នាំគ្នាជឿ សម្តេច សីហនុ ឃើញ ព្រះអង្គ ចាត់ទឹកអាមេរិកាំងចោល ពីក្អមពាង នៅខែចែត អង្គុយចាំ ទឹកភ្លៀងចិន ក៏នាំគ្នា អង្គុយបន់ស្រន់ ដល់ទេព្តា ឲមានភ្លៀង តែបែរ ជាបានទទួល អសនី ពី យក្សកុម្មុយនិស្ត បាញ់ដុតផ្ទះ ស្រែចំការខ្មែរ ឲវិនាសអន្តរាយ ឥតចាំបាច់ធ្វើវិកាស (ប្រកាស) ជាមុន នាំឲមានវិការ(ការប្រែប្រួល) ដល់សង្គមជាតិខ្មែរ ធ្វើឲរាស្ត្រខ្មែរ ក្លាយជា អនាគារ (ជនគ្មានទីលំនៅ) រស់យ៉ាងសង្វេគ នៅតាមជំរុំជនភាសខ្លួន នៅក្នុងប្រទេសខ្លួនឯង។ សួរថា តើប្រជារាស្ត្រខ្មែរ សុខចិត្ត អនុមោទនា (យល់ព្រម) នៃទុក្ខនេះ ថាជាកម្មផល របស់ខ្លួនតាមច្បាប់ សង្សារចក្រ (កង់ចក្រវដ្តសង្សារ) ដែរឬទេ ?

ថ្ងៃបន្ទាប់ ពីយៀកកុង វាយប្រហារ កងទ័ពជាតិ នាំឲយុវជនខ្មែរ រាប់ម៉ឺននាក់ បានស្ម័គ្រចិត្តចូលធ្វើទាហាន ស្មាល់ស្មាគ្នា ធ្វើជារបបការពារ បូរណភាពទឹកដីខ្មែរ។ ចម្រៀងលោក ស៊ិន-ស៊ីសាមុត មួយបទ មានចំណងជើងថា «លាម៉ែទៅច្បាំង» បញ្ជាំង នូវការពិតមួយ នៃទឹកចិត្តកូនខ្មែរ នៅពេលនោះ។ ការរំលឹក អំពីអតីតកាលជាតិ ប្រាប់ដល់កូនខ្មែរថា ខ្មែរជាពូជអ្នកច្បាំង គឺការចាំបាច់មួយ សំរាប់តម្រូវនឹងកាលៈទេសៈដែលជាតិខ្មែរ ត្រូវការឆន្ទៈ និង សេចក្តីក្លាហាន ពីសំណាក់យុវជន ដើម្បី ការពារជាតិខ្មែរ ដែលត្រូវ យួនកុម្មុយនិស្ត ឈ្លានពាន។ តែឆន្ទៈ និង សេចក្តី ក្លាហាន វាមិនគ្រប់គ្រាន់ សំរាប់ ប្រឈមមុខនឹង សង្គ្រាមព្រៃ និង នៅចំពោះមុខសត្រូវ មានបង្វឹកខាងផ្លូវសឹកនោះឡើយ។ យោធិនខ្មែរ ត្រូវការ ការហ្វឹកហ្វឺន ក្នុងផ្នែក បច្ចេកទេស ប្រើអាវុធ, ការវាយលុក និង ការពារខ្លួន, នាយទាហានរង ត្រូវមានចំណេះ ដឹកនាំក្រុមខ្លួន ធ្វើការប្រយុទ្ធនៅក្នុងសមរភូមិ, នាយទាហាន ត្រូវចេះក្បួន បើកការប្រយុទ្ធ រីឯ នាយទាហានជាន់ខ្ពស់ ត្រូវចេះ យុទ្ធសាស្ត្រសឹក និង សេនាធិការ ដើម្បីដឹកនាំកងទ័ព ធ្វើសង្គ្រាម។ ការហ្វឹកហ្វឺន នេះ ត្រូវការពេលវេលាច្រើន តែ ពួក យៀកកុង ដឹងច្បាស់ ថាខ្មែរគ្មានពេលវេលា និង មធ្យោបាយ នោះឡើយ ហេតុនេះឯង ពួកគេមានជំនឿជាក់ច្បាស់ថា ពួកគេនឹង វាយរំលំកងទ័ពខ្មែរ តែមួយសប្តាហ៍ ប៉ុណ្ណោះ។ ពួក យៀកកុង គេយក អនុភាព វាយឆ្មក់[10] ធ្វើជាជំនឿ នៃជ័យជំនះ។ ជំនឿស៊ប់ នេះ ហើយ ដែលនាំ ឲ សម្តេច សីហនុ និង ប

---

[10] អនុភាពវាយឆ្មក់= Effet de surprise។

រីវារ ព្រះអង្គ នៅទីក្រុង ប៉េកាំង នាំគ្នា បើកស្រា Champagne គោះកែវគ្នា ចាំដំណឹង នៃបរាជ័យ របស់កងទ័ពជាតិខ្មែរ។ តែ ដំណឹង នេះ មិនចេះមកដល់សោះ ព្រោះកងទ័ពជាតិខ្មែរ ដែលមាន យុវជន, ពុទ្ធសាសនា និង រដ្ឋាភិបាលស្រោចស្រង់ជាតិ ជា ខែលនៃការតស៊ូ ទប់ទល់នឹង គំនក់ (coup) របស់ ពួកអាថ៌ិលឥតសាសនា។

សម្តេច សីហនុ ព្រះអង្គ បង្កើត រណសិរ្ស តាមឱវាទចិន ដើម្បី បំរើ ប្រយោជន៍យួនកុម្មុនិស្ត ដែលមាន ពួកខ្មែរក្រហម ជាស្នូល ហើយ បង្កើត រាជរដ្ឋាភិបាល នៅក្រៅប្រទេសដើម្បី បិទបាំង សង្គ្រាមឈ្លានពាន ពីសំណាក់ យួនកុម្មុយនិស្ត ឲសហគមន៍អន្តរជាតិ គេមើលឃើញថាជា សង្គ្រាមស៊ីវិល ទុកឱកាស ឲពួកយៀកកុង បំផ្លាញ ហេដ្ឋារចនាសម្ព័ន្ធជាតិ សម្លាប់ជនខ្មែរ តាមសេរី ហើយនាំចូល អាណិកជនយួន ចូលបន្ថែម មករស់នៅក្នុងបឹងទន្លេសាប ធ្វើជា ហត្ថពលិក សំរាប់កងទ័ព។ យៀកកុង គេយក ខេត្ត ពោធិសាត់ ជាអាថិ មូលដ្ឋានសឹក នៅក្នុងស្រុកខ្មែរ។ តាំង ពីមុនឆ្នាំ ១៩៧០ តាមដងទន្លេមេកុងនិងនៅ បឹង ទន្លេសាប អាណិកជនយួន មករស់នៅ មានចំនួន ៩០% ក្នុងចំណោម ប្រជាជន ដែលរស់នៅ នៅក្នុងដំបន់នេះ។ ក្នុងឆ្នាំ ១៩៧១ អាណិកជនយួន កើនឡើង រហូតដល់ទៅ ៩៩%។ តាមឯកសារ ពួកខ្មែរ ក្រហម ក្នុងឆ្នាំ ១៩៦៦ អាណិកជនយួន ដែលចូលមករស់នៅក្នុងស្រុកខ្មែរ មានចំនួន ៦ សែននាក់។ រដ្ឋាភិបាល យួនខាងជើងនិង អាជ្ញាធរ យៀកកុង គ្រោង បញ្ចូល ជនជាតិយួន មកក្នុងស្រុកខ្មែរឲឡើងដល់១លាននាក់ ដើម្បីទុកជា ហត្ថពកម្ម នៃសេដ្ឋកិច្ចសង្គ្រាម សំរាប់ គាំទ្រទ្រ សមរភូមិ នៅក្នុងស្រុកខ្មែរផង និង នៅយៀកណាមខាងត្បូងផង។ ចំនួននេះឯងហើយ ដែលនាំបង្កើត ឲមានឧប្បត្តិហេតុ នៃការសម្លាប់ អាណិកជនយួន ពីសំណាក់ ខ្មែរអ្នកជ្រុលនិយម រាប់រយនាក់ ភាគច្រើនបំផុតសុទ្ធជា ភ្នាក់ងារ សកម្ម របស់ ពួក យៀកកុង ធ្វើវិទ្ធង្សនា ប្រឆាំងនឹង រដ្ឋាភិបាលខ្មែរ។ តែជាអកុសល នៅក្នុងចំណោមខ្មាំងយៀកកុងនោះ មានជនស្លូតត្រង់ខ្លះ ទទួលរងគ្រោះជាសាខារួម[11]។ តើ ត្រូវធ្វើបែបណាទៅ អាច ជៀសវៀង នូវឧប្បត្តិហេតុដ៏គួរឲសោកស្តាយនេះកើត នៅក្នុងសមរភូមិមួយ ដែលសត្រូវលាក់ខ្លួននៅគ្រប់ទីកន្លែងហើយចាំឱកាស វាយប្រហារនៅក្នុងបរិវេណការពារ តាមគ្រប់មធ្យោបាយ និង កំហឹង នៃអ្នកជាតិនិយម ជ្រុលនិយមមួយក្រុម នៅចំពោះមុខ សត្រូវរុករាន ? រដ្ឋាភិបាលខ្មែរចាត់វិធានការរារាំងយ៉ាងប្រញាប់ ធ្វើសហការ ជាមួយ រដ្ឋាភិបាល យៀកណាមខាងត្បូង ដើម្បីនាំអាណិកជនយួន ដែលបានចូលមករស់នៅក្នុងស្រុកខ្មែរឥតច្បាប់ ឲ

---

11 រងគ្រោះជាសាខារួម= Victime collatéral។

វិលត្រឡប់ទៅកាន់ប្រទេសយួនវិញ។ ឧប្បត្តហេតុ នេះ ត្រូវបាន ពួកកុម្មុយនិស្ត គេយកទៅឃោសនា តាមរយៈសារព័តមាន អន្តរជាតិរាប់មុខ[12] ដើម្បី ចោទប្រកាន់ រដ្ឋាភិបាលខ្មែរថាប្រព្រឹត្ត អំពើប្រល័យពូជសាសន៍ តាមពិត នៅក្នុងដំបន់ ដែលពួកយៀកកុងកាន់កាប់ ពួកវា បានសម្លាប់ខ្មែរស្លូតត្រង់ជាច្រើនពាន់នាក់ តែពួកវា ចេះលាក់បាំងនៃអំពើឃាតកម្មរបស់ពួកវា។ គ្រប់សមរភូមិ ពួកយៀកកុង តែងតែយក ប្រជាជនធ្វើជាខែលស្បែកស្រស់ សំរាប់ការពារវា, យក វត្ត វិហាគ្រិសសាសនា អ៊ីស្លាម ធ្វើជាកន្លែងពួនបាញ់ទ័ពខ្មែរ ហើយនៅពេល មានការតបតនឹងពួកវា ពួកវាថតរូប យកទៅឲ សារព័តមានអន្តរជាតិ ចុះផ្សាយ ថាទ័ពខ្មែរ បាញ់សម្លាប់ប្រជាពលរដ្ឋ ឬ ដុត ទីកន្លែងសាសនា។ ឧទាហរណ៍មួយ ក្នុងចំណោមឧទាហរណ៍ជាច្រើនឯទៀត គឺ នៅសមរភូមិស្រុកស្អាង យៀកកុង យកអាណិកជនយួនតែម្តង ដែលរស់នៅទីនោះ យកធ្វើជាខែលស្បែកស្រស់ គឺវាឲអ្នកទាំងនោះ ដើរជាក្បួនហែ ស្រែកប្រាប់កងពលខ្មែរ ថាកុំវាយចូលភូមិ ព្រោះគ្មានយៀកកុងទេ តែនៅពេលទ័ពខ្មែរស្រែកប្រាប់ជនទាំងនោះ ឲចាកចេញពីភូមិ ដើម្បី ទ័ពខ្មែរវាយចូល ហើយយួនទាំងនោះ ហាក់បីដូចជាស្តាប់ ហើយចង់ ធ្វើតាម ពេលនោះ ស្រាប់តែពួកយៀកកុង វាបាញ់ភ្លាមពីក្រោយ ទៅលើក្បួនហែ ដែលនាំឲស្លាប់មនុស្សអយោធ (ស៊ីវិល) ជាច្រើន[13]។

សង្គ្រាម របស់ យួនកុម្មុយនិស្ត នៅស្រុកខ្មែរ ជាសង្គ្រាម គ្មានអនុសញ្ញិក ហើយក៏មិនមែនជាសង្គ្រាមមហាជន និង សង្គ្រាម មិនទុកជីវិតអ្នកចាញ់ វាជាសង្គ្រាមចម្លែកមួយគ្មានឈ្មោះ ព្រោះវាជាស្នាដៃ នៃមនុស្សព្រៃ ឃោរឃៅ ដូច ពាឡម្រឹគ (សត្វសាហាវ) ដើម្បីឈ្នះ គឺវាមិនខ្លាចសម្លាប់មនុស្ស មិនរើសមុខ ដូចយ៉ាង អយោធ ទាំងប្រុសស្រី ក្មេងចាស់, ទារក, បសុសត្វ គឺថាអ្វីៗ ដែលមានរូបី នៅក្នុងលោកីយ បើនិយាយជាសង្ខេប គឺកំទេច អជដាកាស(univers) ក្នុងនាម កុម្មុយនិស្ត ដែលគ្រាន់តែជា ឧបករណ៍ សំរាប់សមិទ្ធិ មហិច្ឆតា ពាន់ឆ្នាំ របស់ ជាតិសាសន៍យួន គឺស្រូបកម្ពុជា បញ្ចូលទៅក្នុង យៀកណាម។ យួនកុម្មុយនិស្ត ថ្មែ សង្គ្រាមឈ្លានពាន ឲក្លាយជា សង្គ្រាមស៊ីវិល យកឈ្មោះ សម្តេចសីហនុ ជាអ្នកដឹកនាំសង្គ្រាមក្រោមទង់ រណសិរ្សរួបរួមជាតិកម្ពុជា (រ.រ.ជ.ក.) ដែលជាពួកយៀកកុង ពាក់អាវខ្មែរ ធ្វើជាម្ចាស់ រណសិរ្ស និង រាជរដ្ឋាភិបាល រួបរួមជាតិកម្ពុជា ដែលស្ថិតនៅក្នុង នឹម ចិនប្រជាមានិត។ ពាក្យរួបរួមជាតិ របស់ សម្តេច សីហនុ គឺជាការ

---

[12] រាប់មុខ= Se montrer partial។
[13] សក្ខីកម្ម នេះ បរិយាយ ដោយ លោក ឧត្តមសេនីយ ស៊ុសស្តែន ហ្វែណង់ដែស ពេលនោះ លោកជាមេបញ្ជាការកងឯកភាពខ្មែរ នៅសមរភូមិស្អាង។

បោកប្រាសជាតិ អោយរាស្ត្រខ្មែរលះបង់ព្រលឹងដែលជា មរតក អមត្តៈ ដូនតា ទៅបំរើ យួន-ចិន កុម្មុយនិស្ត ដែលមានញាតិខ្លួនមួយក្តាប់តូច ដង្ហែរខ្លួន ទៅទីក្រុង ប៉េកាំង ដេកចាំ បរាជ័យជាតិខ្មែរ ក្នុងសេចក្តីសង្ឃឹម បំភ័ន្តចិត្ត ថានឹងអាចវិលត្រឡប់ ចូលស្រុក ដើម្បីយកជើង និង ល្អងធូលីព្រះបាទ មកដាក់ពីលើ សិរិសារ ជាន់ឈ្លីជាតិខ្មែរ។ សួរថា រណសិរ្សរួបរួមកម្ពុជា ធ្វើការតស៊ូ រំដោះអ្នកណា ?



## ការតស៊ូ របស់ សាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)

របបសាធារណខ្មែរ ប្រកាសឡើង នៅថ្ងៃទី ៩ តុលា ឆ្នាំ ១៩៧០។ សួរថា តើជាការចាំបាច់មួយ ត្រូវប្តូរ របប រាជានិយម មកជារបប សាធារណរដ្ឋ ក្នុងការតស៊ូ ប្រឆាំងនឹងការឈ្លានពាន ពួកយៀកកុង និង យួនខាងជើងដែរ ឬទេ ? នៅក្នុងវិស័យ យោធា ការប្តូររបបនយោបាយ វាគ្មាន អនុភាពអ្វីច្រើន នៅលើ សមរភូមិ នោះឡើយ ព្រោះថា យុវជនខ្មែរ នៅពេលនោះ បានផ្តោតគំនិតតែមួយគត់ នៅក្នុងឆន្ទះ របស់ខ្លួន គឺច្បាំងដេញខ្មាំងយៀកកុង ឥតសាសនា ចេញពី កម្ពុជា។ សម័យ សង្គមរាស្ត្រនិយម សម្តេច សីហនុ បានបង្កើត ចលនា យុវជនសង្គមរាស្ត្រនិយម (យ.ស.រ.ន.) ដើម្បី ការពារ របបព្រះអង្គ និង ការពារជាតិ។ យុវជន នេះឯង នៅក្នុងគំនិត ការពារជាតិ ក្លាយជាយុវជនស្រោចស្រង់ជាតិ ងើបឈរឡើង ធ្វើការតស៊ូ ជាមួយ កងទ័ពជាតិ ដោយទឹកចិត្តស្នេហាជាតិ។ តែការប្រកាស សាធារណរដ្ឋ ជាការបន្តសមហេតុផល នៃព្រឹត្តិការណ៍ ១៨ មិនា ព្រោះ សម្តេច សីហនុ បង្កើត រាជរដ្ឋាភិបាល រួបរួមជាតិ កម្ពុជា នៅ ស្រុកចិនកុម្មុយនិស្ត ប្រកាសប្រឆាំងនឹង រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ដែលព្រះអង្គខ្លួនឯង ជាអ្នកបង្កើតនោះដែរ ដូច្នេះ ការរំលំរបបរាជានិយម ជា ចម្លើយនឹង អំពើក្បត់ជាតិ របស់ព្រះអង្គ ព្រោះព្រះអង្គនៅពេលនោះ ជាតំណាង របបរាជានិយម ក្បត់ជាតិ លក់ទឹកដី ឲ យៀកកុង។ ដូច្នេះ អ្នកដែល រំលាយ របបរាជានិយម គឺ សម្តេច សីហនុ ខ្លួនឯង ហើយ អ្នកដែលរំលាយ ចលនាសង្គមរាស្ត្រនិយម គឺព្រះអង្គខ្លួនឯងដែរ ព្រោះព្រះអង្គ បានបង្កើត របសិរ្ស ដែលជាកត្តា លុប ឯកឯង នៃចលនា សង្គមរាស្ត្រនិយម។ អ្វីដែលព្រះអង្គ បង្កើតនៅក្នុងទសវត្សរ៍ ទី៥០ ព្រះអង្គ រំលាយវាចោលអស់ ដោយខ្លួនឯង នៅក្នុង ទសវត្សរ៍ ទី៧០។ ហេតុអ្វី ? ចម្លើយមានតែមួយគត់ គឺ ព្រះអង្គ មាន អត្តៈ ជាមនុស្សពិសេស ដែលមាន និន្នាការ យកការបំផ្លាញ ជាល្បែង របស់ព្រះអង្គ។

សង្គ្រាម តស៊ូ នៃកងទ័ពជាតិខ្មែរ ដេញយៀកកុង ពីស្រុកខ្មែរ វាស្ថិត នៅចំពេល ដែល ស.រ.អ. ធ្វើនយោបាយ ដកទ័ពខ្លួនចេញ ពី សង្គ្រាម នៅយៀកណាម ដូច្នេះ ស.រ.អ. មិនសូវជាស្វាគមន៍ កាប្តូរ របបនយោបាយ នៅស្រុកខ្មែរ នោះឡើយ។ ដូចបានជំរាប ពីខាងលើរួចមកហើយថា ក្នុងទំនាក់ទំនង ឡើងវិញ រវាង ស.រ.អ. នឹង កម្ពុជា ស.រ.អ. គេឈរលើ ទស្សនៈ រក្សា អព្យាក្រឹតភាពខ្មែរ។ ដូច្នេះ ការទំលាក់ សម្តេច សីហនុ ពីអំណាច ចំពោះ ស.រ.អ. វាជា ពន្ធុ ច្រើនជាង ជា លាភ ចំពោះ គេ។ ទស្សនៈ របស់ សម្តេច សីហនុ ថា ពួក CIA និង ពួក ខ្មែរអ្នកស្តាំនិយម ទម្លាក់ព្រះអង្គ គឺគ្រាន់តែជា ជំនឿគ្មានមូលហេតុអ្វីពិតប្រាកដ តែប៉ុណ្ណោះ ហើយ ជាពិសេស ជាពាក្យ ឃោសនា របស់ ពួកកុម្មុយនិស្ត ចិន-យួន ដើម្បី យកពាក្យ រដ្ឋប្រហារ មកធ្វើ ជាឧបករណ៍ នយោបាយ តែពាក្យ រដ្ឋប្រហារ

នេះ វាមិនអាច បំភាន់ សហគមន៍ អន្តរជាតិ បាន ព្រោះ របប សាធារណៈរដ្ឋខ្មែរត្រូវ អង្គការសហប្រជាជាតិ គេទទួលស្គាល់ជា របបតំណាងជាតិខ្មែរ។

នៅចំពោះមុខ ការវាយប្រហារ របស់ ពួកយៀកកុង មកគ្រប់ទីតាំងទ័ពខ្មែរ តម្រូវឲ រដ្ឋាភិបាលខ្មែរ ស្នើសូមជំនួយ យោធាពី ស.រ.អ.។ លើកទី១ ស្នើ នៅថ្ងៃទី ១៤ មេសា តែគ្មានចម្លើយ ពី ស.រ.អ.។ នៅថ្ងៃទី ២២ មេសា រដ្ឋាភិបាលខ្មែរ ស្នើជាថ្មី ដល់ ស.រ.អ. ទើប អាមេរិកាំង សម្រេចចិត្តផ្តល់ជំនួយដល់ខ្មែរ ហើយដឹក សម្ភារៈយោធា មកដល់ស្រុកខ្មែរនៅថ្ងៃទី ២៧ មេសា។ ក្នុងចំណុចនេះ យើងគ្រាន់តែចង់បញ្ជាក់ថា បើ CIA ជាអ្នកធ្វើរដ្ឋប្រហាររដ្ឋាភិបាលខ្មែរ មិនចាំបាច់ស្នើសូមជំនួយ យោធា អាមេរិក នោះឡើយ គឺជំនួយនោះ វាត្រូវទទួលបានតាំងពី ថ្ងៃទី ១៨ មិនា មកម្លេះ ដើម្បី គ្រោងទុកជាមុនទប់នឹងការវាយប្រហារ របស់យៀកកុង។ នៅក្នុង សេចក្តីកត់ចំណាំ របស់ លោក ឧត្តមសេនីយ ស៊ុសស្តែន-ហ្វៃណង់ដែស[14] អគ្គិអង្គមេបញ្ជាការកងទ័ពជាតិខ្មែរ លោកធ្វើគំនន់ថា ពីថ្ងៃទី ២៧ មិនា មកដល់ ថ្ងៃ ដែល ស.រ.អ. សម្រេចចិត្តផ្តល់ជំនួយ យោធាឲខ្មែរ កងទ័ពជាតិ ធ្វើការតស៊ូ ទប់ទល់ ដោយមធ្យោបាយ ដែលខ្លួនមាន តិចតួចបំផុតនឹងការវាយលុក របស់យៀកកុង និង យួនខាងជើង។ ២ ភាគ ៣ នៃទឹកដីខ្មែរ បានក្លាយជាសមរភូមិ ហើយយៀកកុង វាមានជំនឿជាក់ច្បាស់ថា តែ ១សប្តាហ៍ វានឹងអាចវាយឈ្នះកងទ័ពជាតិខ្មែរ។ ១៤ថ្ងៃ វាជាពេលវេលា ដ៏ខ្លីមួយពិត តែនៅចំពោះមុខ យៀកកុង ប្រដាប់អាវុធទំនើប មានបទពិសោធ ក្នុងសង្គ្រាម តាំងទីទ័ពនៅក្នុងស្រុកខ្មែររួចស្រេច មានចំនួនទាហាន ២ដង ច្រើនជាង ទ័ពខ្មែរ ជាពេលវេលាមួយ ដ៏យូរអង្វែងចំពោះកងទ័ពជាតិខ្មែរ ក្នុងការវាយទប់នឹង ការវាយប្រហារ របស់ខ្មាំងជាតិ។ ១៤ថ្ងៃ ជាពេលវេលាដែលយោធាខ្មែរម្នាក់ៗ ធ្វើពលកម្ម ក្រៃលែង ដើម្បីជាតិ បូជាជីវិត រាប់ពាន់នាក់ ទុកជាគុណស្រ័យ ក្នុង សម្ពរកម្ម (bataille) មិនស្មើកម្លាំងគ្នា តែយោធាខ្មែរ មានទឹកចិត្តខ្ពង់ខ្ពស់អាចទប់ទ័ពសត្រូវគ្រប់ទីកន្លែងបាន។ សម្ពរកម្ម នៅស្រុកស្អាង ចំងាយ ២០ គ.ម. ពីទីក្រុងភ្នំពេញ ជាការបង្ហាញមួយ នូវបញ្ញា និង ការប្តេជ្ញចិត្ត ខ្មែរ លើសត្រូវ ដែលវាមានបំណង វាយលុកចូលទីក្រុងភ្នំពេញ ដើម្បី ប្រកាសជ័យជំនះ និង រំលំរបបនយោបាយថ្មីខ្មែរ។ កងទ័ពខ្មែរ មិនត្រឹមតែវាយទប់បាន តែប៉ុណ្ណោះ គឺថែមទាំង វាយបណ្តេញខ្មាំងចេញពីស្រុកស្អាងបានថែមទៀត។ សម្ពរកម្ម អធិគម (ជោគជ័យ) នៅស្រុកស្អាង នេះជា សម្ពរកម្ម ដ៏សំខាន់មួយ សំរាប់អាយុជីវិត នៃរបបនយោបាយថ្មីខ្មែរ។

[14] Mémoire de guerre oubliée –Edition AsieInfo Thaïland(2015).

នៅថ្ងៃទី ៣០ មេសា ឆ្នាំ ១៩៧០ លោក ប្រធានាធិបតី ស.រ.អ. Richard Nixon ប្រកាសជាសាធារណៈ ថា លោក អនុញ្ញាត ឲកងទ័ព អាមេរិកាំង និង យៀកណាមខាងត្បូង ចូលមកធ្វើប្រតិបត្តិការសឹកនៅក្នុងស្រុកខ្មែរ ក្នុងរយៈ ២ ខែគត់ ក្នុងចម្ងាយ ៣០ គ.ម. ពីព្រំដែន យៀកណាមខាងត្បូង៖ បេសកកម្ម គឺ ស្វែងរក និង កំទេចចោល នូវមូលដ្ឋានសឹកយៀកកុង នៅស្រុកខ្មែរ។ ប្រតិបត្តិការសឹកនេះ ជាជំនួយ មិន នឹងស្មានថា អាចមានដល់កម្ពុជា ព្រោះវា រំលែកភារៈមួយភាគយ៉ាងធំ ដល់កងទ័ពជាតិខ្មែរ ដែលកំពុងត្រូវពួកយៀកកុងវាយប្រហារឥតសំចៃ តែតាមផ្នែយុទ្ធសាស្ត្រ លោក Richard Nixon ប្រព្រឹត្តកំហុសមួយ គួរឲសោកស្តាយជាទីបំផុត គឺ លោក ប្រកាស នូវកំរិតពេលវេលានិងផ្ទៃសមរភូមិ ហាក់បី លោក ចង់ ជូនដំណឹង ដល់ ទ័ពកុម្មុយនិស្ត នៅស្រុកខ្មែរថា ទ័ពអាមេរិកាំង គ្មានបំណង ជួយ កងទ័ពជាតិខ្មែរ វាយប្រហារខ្លាំង ចេញពីកម្ពុជា នោះឡើយ គឺគ្រាន់តែចូលមកវាយកំទេច មូលដ្ឋាន យៀកកុង នៅតាមបណ្តោយ ព្រំដែន ខ្មែរ-យៀកណាមខាងត្បូង តែប៉ុណ្ណោះ។ ពួក យៀកកុង ដឹង គោលបំណង អាមេរិកាំង នេះ វានាំគ្នារុលចូលមកលាក់ខ្លួន ជាបណ្តោះអាសន្ន លើសពីចម្ងាយ ដែល អាមេរិកាំង កំណត់ទុក។ តាម អ្នកវិភាគនយោបាយ ការប្រកាសបែបនេះ គឺ លោក Richard Nixon មិនចង់ ទី១ បង្កើតបញ្ហាថ្មី ក្នុងការចរចារ ជាមួយ យួនកុម្មុយនិស្តស្តីពី ដំណោះស្រាយ តាមផ្លូវនយោបាយ ដើម្បីបញ្ចប់សង្គ្រាម នៅយៀកណាម ហើយកិច្ចចរចារនេះកំពុងតែគាំងស្ទះ អស់រយៈពេល ២ឆ្នាំមកហើយ។ ទី២ គឺ លោក មិនចង់ឲមានការខ្ចុខ្ចី ក្នុងទំនាក់ទំនង ជាមួយ ចិន ប្រជាមានិត។ អ្នកវិភាគ នយោបាយខ្លះ រហូតចោទលោក Richard Nixon ត្រង់ៗតែម្តង ថា លោក ឆ្លៀត យកព្រត្តិការណ៍ នៅស្រុកខ្មែរ ដើម្បី ធ្វើឲមានសំទុះ ក្នុង ការចរចារ ជាមួយ យៀកណាមខាងជើង យៀកកុង និង ចិន ដោយយកស្រុកខ្មែរជា ការបង្ហាញ នូវសន្តានចិត្ត ល្អ របស់ អាមេរិកាំង នៅក្នុងកិច្ចចរចារនេះ[15]។

លទ្ធផល នៃប្រត្តិបត្តការសឹក នេះ មានជាក់ស្តែង ដល់ ទ័ពអាមេរិកាំង គឺ ប្រមូលយកបាន សម្ភារៈយោធា យួនកុម្មុយនិស្តបានជាច្រើន មានចំនួន ដូចខាងក្រោមនេះ៖

- ១ ២៨២ កាំភ្លើង AK 47 - ២០២ កាំភ្លើងយន្ត - ១៥០ 000 គ្រាប់កាំភ្លើងធំ និង ៣៤០ តោន គ្រាប់កាំភ្លើង - អង្ករ ៣០ តោន - ពោត ៨ តោន។ មួយសប្តាហ៍ ក្រោយមក ទ័ពអាមេរិកាំង រកឃើញ កន្លែងសំងាត់ លាក់អាវុធ ១៨២ កន្លែង៖ កន្លែង មួយ នោះ មាន

---

[15] ដកស្រង់ពី ការកត់សំគាល់ របស់ លោក ឧត្តសេនីយ ស៊ុសស្តែន-ហ្វៃណង់ដែស :Mémoire d’une guerre oubliée (2015)។

លាក់ ៤៨០ កាំភ្លើង, កន្លែងមួយទៀត លាក់ ១២០ គ្រាប់កាំភ្លើងធំ។ នៅក្នុង សមរភូមិមួយសំខាន់ ទ័ព អាមេរិកាង រកឃើញ ៦ម៉ឺន ៥សែន គ្រាប់កាំភ្លើងត្បាល់ និង កាំភ្លើងបាញ់យន្តហោះ, ៥សែន គ្រាប់កាំភ្លើង, រាប់ពាន់ រ៉ុកកែត, ឡានធំ (General Motors) ច្រើនគ្រឿង និង ស្តង់ដារ ទូរសព្ទ មួយគ្រឿង[16]។ គុល្យការ នៃប្រតិបត្តិការសឹកនេះ មានភាពគួរអោយស្ងើត តែគោលបំណងធំមួយ ដែល លោក Richard Nixon ស្វែងរកគឺ ទីបញ្ជាការជាន់ខ្ពស់យៀកកុង ដែល ក្រុមស៊ើបការ អាមេរិកាំង បានទទួលពត៌មាន ថាវាស្ថិតនៅក្នុងដំបន់ទំពក់ត្រី (Fish Hook) ក្នុងស្រុក មេមុត ខេត្តកំពង់ចាម តែគោលដៅនេះ មិនបានសម្រេចនោះឡើយ ព្រោះទ័ពអាមេរិកាំង មិនបានរកឃើញដានបន្តិចបន្តួចសោះនៅទីនោះ។ ចំពោះ លោក អ៊ិន-តាំ, អតីត រដ្ឋមន្ត្រីទី១ សាធារណរដ្ឋខ្មែរ, ប្រតិបត្តិការសឹក អាមេរិកាំង ដែលមានកងទ័ពយួនខាងត្បូងចូលរួមនេះជា កំហុសមួយ របស់ លោក ប្រធានាធិបតី អាមេរិក ព្រោះ រដ្ឋាភិបាលខ្មែរ ពិបាក ពន្យល់ ប្រជាពលរដ្ឋខ្មែរ នៅខេត្ត ស្វាយរៀង ដែលជាអ្នកធ្វើបាតុកម្ម លើកទី១ ដេញយៀកកុង ចេញពីស្រុកខ្មែរ ស្រាប់តែឃើញ ទ័ព យួនខាងត្បូង រាប់ពាន់នាក់ (១២ ០០០) ដឹកនាំដោយឧត្តមសេនីយ យួន ឈ្មោះ Do Cao Try ចូលមកក្នុង ដំបន់ ចំពុះទា ក្នុងខេត្តស្វាយរៀងតែម្តង។ ក្នុងប្រតិបត្តិការសឹង នេះ មានការប្រយុទ្ធគ្នា តិចតួចណាស់ ព្រោះ កងពលធំលេខ ៧, លេខ ៥ និង លេខ ៩ របស់ យៀកកុង ស្ថិត នៅក្នុងដំបន់នោះ វាគេចវេះ មិនព្រមប្រយុទ្ធ តទល់ជាមួយ ទ័ព អាមេរិកាំង និង យៀកណាមខាងត្បូង ព្រោះវាដឹងថាពួកនេះ នឹងដកទ័ពថយ នៅថ្ងៃទី ៣០ មិថុនា។ លោក អ៊ិន-តាំ សន្និដ្ឋានថា ស.រ.អ.ជាមហាអំណាច មាន អ្នកដឹកនាំ មានចំណេះខ្ពង់ខ្ពស់ មាន មហាវិទ្យាល័យ ល្បីឈ្មោះពេញពិភពលោក មានបទពិសោធក្នុងចម្បាំង នៅ អាស៊ី នៅ យៀកណាម តែ ស.រ.អ.មិនស្គាល់ ប្រវត្តិសាស្ត្រខ្មែរ ទឹកចិត្តខ្មែរ ពិតប្រាកដ ព្រោះ ចំពោះខ្មែរ យួនខាងជើង ក្តីយៀកកុង ក្តី យៀកណាមខាងត្បូងក្តី គឺយួនតែមួយគត់ មានមហិច្ឆតា លេបស្រុកខ្មែរទាំង ក្រោម កណ្តាល និង លើ បញ្ចូលទៅក្នុងប្រទេសយួន។ ការនេះ វាជា សច្ចះនៃប្រវត្តិសាស្ត្រ ចំពោះជាតិខ្មែរ ដូច្នេះ វត្តមាន ទ័ពយួនខាងត្បូង នៅក្នុងស្រុកខ្មែរទោះបីមាននៅក្នុង រយៈពេលខ្លីក្តី វាលើកជាចំណោទនៅក្នុងចិត្តគំនិតខ្មែរ សួរជាសំណួរថា តើវាខុសអ្វីនឹង សម្តេច សីហនុ ព្រះអង្គ កំពុង យល់ច្រឡំ អនុញ្ញាត ឲយៀកកុង វាយប្រហារកងទ័ពខេមរភូមិន្ទ ដែលព្រះអង្គ ជាឧត្តមអគ្គមេបញ្ជាការ។

---

[16] ដកស្រង់ចេញពី NAM – Edition Atlas n° 15។

លោក លន់-នល់ ទ្រង់ សិរិមតៈ លោក អ៊ីន-តាំ ក្តី ដែលជា តួអង្គសំខាន់ នៃព្រឹត្តិការណ៍ ១៨ មិនា ទុក អន្តរគមន៍រួម អាមេរិកាំង-យៀកណាមខាងត្បូង ជាអំណោយមួយ មានជាតិពិសពល់ ដែលខ្មែរ ត្រូវតែទទួល ព្រោះ ស.រ.អ. គេមិនបានប្រាប់រដ្ឋាភិបាល ខ្មែរ ជាមុន នាំខ្មែរ បាក់មុខ លើឆាកអន្តរតជាតិ។ អាមេរិកាំង គេធ្វើដោយសម្ងាត់ ព្រោះ គេចង់ ឲមាន អនុភាពវាយឆ្មក់ ទៅលើទ័ពយួនកុម្មុនិស្ត តែអនុភាពនេះ វាបាត់ ប្រសិទ្ធិភាពវា នៅត្រង់ ស.រ.អ.និយាយប្រាប់សត្រូវខ្លួន ជាមុនថាខ្លួនគ្មានគោលបំណងធ្វើសង្គ្រាមយកឈ្នះចាញ់ នៅក្នុងស្រុកខ្មែរ នោះឡើយ។ ទោះបី នៅក្នុង សុន្ទកថា លោក ប្រធានាធិបតី ស.រ.អ. មានខ្លឹមសារ គួរឲខ្មែរ មានសេចក្តីសង្ឃឹមនៅក្នុងចិត្ត នូវការសម្រេចចិត្ត របស់ លោក ថាលោកនឹង ទប់ទល់នឹង វិត្ថាកម្ម នៃកម្លាំងកុម្មុយនិស្ត នៅក្នុងប្រទេសតូចៗ នៅក្នុងពិភពលោក ដែលជាអ្នក ស្រឡាញ់ សន្តិភាព និងសេរីភាព ដែលកំពុងទទួលការវាយប្រហារ ពី សំណាក់ កម្លាំងកុម្មុយនិស្ត ដែលជា កម្លាំងផ្តាច់ការ ជាអង្គការ អនាធិបតេយ្យនិយម ធ្វើភេរវកម្ម គំរាម ប្រជាជាតិ ជាច្រើន និង ស្ថាប័ន សេរី៖ «...ស.រ.អ.ត្រូវសួរជាសំនួរ ឯកឯងថា ខ្លួនជា មហាអំណាច ជា ប្រទេស អ្នកមានស្តុកស្តម ជាងគេ មាន ពលានុភាព នៅក្នុងពិភពលោក នៅក្នុងប្រវត្តិសាស្ត្រ នៃមនុស្សជាតិ តើអាចមាន ឆន្ទៈ និង កម្លាំង និស្ស័យ ប្រឈរមុខទប់ទល់នឹង ពួកភេរវកម្ម ទាំងនោះ ដើម្បី នាំមកវិញ នូវសន្តិភាព សមតាមសមធម៌ បានដែរ ឬទេ ?...»។ សុន្ទកថា នេះ ទុកជា គោលទស្សនៈ របស់ លោក Nixon នៅក្នុងសង្គ្រាមនៅយៀកណាម សួរថា សង្គ្រាមនៅស្រុកខ្មែរ គោលទស្សនៈនេះ តើខ្មែរអាចទុកជា ការធានានៃជីវិត ជាតិខ្មែរបានដែរ ឬទេ ?

## ១. យុទ្ធសាស្ត្រ សាធារណរដ្ឋខ្មែរ

ចាប់ពីសង្គ្រាមផ្ទុះឡើង អ្នកដឹកនាំ នៃរបបនយោបាយថ្មី នៅស្រុកខ្មែរ ដែលជាមនុស្សកាន់អំណាចនៅក្នុងរបបចាស់រួចស្រេចទៅហើយ គឺថា នៅក្នុង រដ្ឋាភិបាល ស្រោចស្រង់ជាតិ ដែល សម្តេច សីហនុ ជាអ្នកបង្កើតឡើង ព្រោះ ព្រះអង្គ ជាអ្នកតែងតាំងលោក លន់-នល់ ជានាយករដ្ឋមន្ត្រី ហើយរដ្ឋសភាជាតិ បានបោះឆ្នោត ប្រគល់សេចក្តីទុកចិត្តឲរដ្ឋាភិបាលនេះ ក្នុង ផែនការនយោបាយបីចំណុចសំខាន់៖ ទី១. ស្រោចស្រង់សេដ្ឋកិច្ចជាតិ ដែលសម្តេច សីហនុ ខ្លួនឯងទទួលស្គាល់ថា វាកំពុងជួបប្រទះ នូវវិបត្តដ៏ធំមួយ, ទី២. ស្វែងរកទំនាក់ទំនងជាថ្មី ជាមួយ លោកសេរី ដើម្បី រកតុល្យការស្របតាមនយោបាយអព្យាក្រឹតខ្មែរ, ទី៣. ជាចំណុចលាក់សិន ដែលខ្មែរយើងជំនាន់នោះទុកជានយោបាយជាន់ខ្ពស់ របស់ សម្តេចឪ គឺ ពិនិត្យឡើងវិញ នូវទំនាក់ទំនងពិសេសខ្មែរ ជាមួយ យៀកណាមខាងជើង និង ចិនប្រជាមានិត។ នៅក្នុងចំណុចទីបីនេះហើយដែល សម្តេចសីហនុ និងលោក លន់-នល់ ជួបពិភាក្សាគ្នា នៅក្នុងខែ កុម្ភៈឆ្នាំ១៩៧០ នៅប្រទេសបារាំង

មុននឹងលោក លន់-នល់ វិលត្រឡប់មកមាតុភូមិវិញ ក្នុងការពិភាក្សាគ្នានោះ សម្តេច សីហនុ មាន អនុសាសន៍ ដល់ លោក នាយករដ្ឋមន្ត្រីខ្មែរ គឺ ពន្លឿន សំណុំរឿង នៃយៀកកុង តែព្រះអង្គមិនបានបញ្ជាក់ថា តាមវិធីណា។ សួរថា សម្តេច សីហនុ ខ្លួនឯងតើព្រះអង្គ ដឹងថាត្រូវធ្វើបែបណា នោះទេ ? មិនពិតប្រាកដ ថា ព្រះអង្គដឹងនោះទេព្រោះ ទំនាក់ទំនងពិសេស របស់ ព្រះអង្គ ជាមួយ យួនកុម្មុនិស្ត វាមានភាពស្មុកស្មាញណាស់ គឺ វាដូចជាចរិត របស់ព្រះអង្គនោះដែរ។ លោក Charles Mayer អតិតទីព្រឹក្សា នៃ ខុទ្ទកាល័យ សម្តេច សីហនុ សរសេរថា[17] សម្តេច សីហនុ ចាប់ពី ឆ្នាំ ១៩៦៥ មក ព្រះអង្គ ហាក់បីដូចជា ជនរវើរវាយម្នាក់ ឆាប់ខឹង ដេរគេឯង ប្រើសំដី អាសគ្រាម ធ្វើអ្វីមិនច្បាស់លាស់។ ការសង្កេតនេះជាការចាំងបង្ហាញ នូវនយោបាយ សម្តេច សីហនុ តែម្តង។

សាធារណរដ្ឋខ្មែរ មាន លិទ្ធិ នៃសង្គ្រាម ៣យ៉ាង ហើយ លទ្ធិនិមួយ មាន តស្សូជនសំខាន់ នៃសាធារណរដ្ឋខ្មែរ ជាតំណាងៈ ទី១. សង្គ្រាម វាយលុក តំណាងដោយ លោក លន់-នល់, ទី២. សង្គ្រាម ការពារ ដើម្បី រកដំណោះស្រាយ តាមផ្លូវនយោបាយ តំណាងដោយ ទ្រង់ សិរិមតៈ, ទី៣. ច្បាំងផង ចរចារជាមួយសម្តេច សីហនុផង តំណាងដោយ លោក អ៊ិន-តាំ តែមានលទ្ធិទី៤ ជាលទ្ធិគ្មានឈ្មោះ តំណាងដោយ ក្រុម លោក ហង់-ធុនហាក់ យក លោក ស៊ីន-ង៉ុកថាញ់ ជា ក្បាលនាវា ហើយយក លោក លន់-ណុល ជា ឧបករណ៍។ ក្រុមនេះហើយ ជាក្រុមគ្រប់គ្រង នយោបាយខ្មែរ ចាប់ពី ថ្ងៃទី ១៥ មិនា ឆ្នាំ ១៩៧២ គឺនៅថ្ងៃដែល លោក លន់-នល់ គាត់ប្រកាស ឯកឯង តែងតាំងខ្លួនលោក ជា ប្រធានាធិបតិ នៃ សាធារណរដ្ឋខ្មែរ ហើយបន្ទាប់មក លោក តែងតាំង លោក ស៊ឹន-ង៉ុកថាញ់ ជា រដ្ឋមន្ត្រីទី១។ ចាប់ពីពេលនោះមក លោក លន់-នល់ គាត់ចាប់ផ្តើម រអិល ទៅរកអំណាចបុគ្គលនិយម ដែលជាអំណាចកូនកាត់ កើតចេញពី អំណាចផ្តាច់ការ និងអំណាចប្រពៃណី។ ខ្ញុំនឹងលើក វិវិធ នយោបាយ នៃក្រុមនិមួយៗ នៅក្នុង សាធារណរដ្ឋខ្មែរ មកអធិប្បាយ នៅពេលក្រោយ។

ត្រឡប់មកនិយាយ ពីដើម នៃសង្គ្រាមវិញ ព្រោះនៅពេលនោះ វាមាន អាសន្នមួយដែលខ្មែរត្រូវដោះស្រាយ ដូច្នេះ កិច្ចការនយោបាយ នៅក្នុងអាសន្ននោះ វាគ្រាន់តែជា ឧបសាធន នៃកិច្ចការយោធា តែប៉ុណ្ណោះ។ ឃ្លាថា សង្គ្រាម ជា ការបន្ត នៃនយោបាយ ចំពោះជាតិខ្មែរ នៅពេលនោះ វាមិនមានន័យពិតដូចឃ្លានោះឡើយ ព្រោះថា សង្គ្រាម ដែល យួនកុម្មុយនិស្ត វាបង្កើតឡើង តម្រូវ ឲជាតិខ្មែរ ប្តូរ របបក្បត់ជាតិ បង្កើត របបការពារ

[17] Charles Mayer – Derrière le sourire khmère។

ជាតិ ដែលមានកងទ័ពជាតិ ជាអ្នកដើរមុខ ទៅតតាំងនឹងខ្មាំង ឥតសាសនា។ ដើម្បីរបបនយោបាយថ្មី អាចនៅរស់បាន កងទ័ពខ្មែរ មានយុទ្ធសាស្ត្រ បែងចែកជា៣ដំណាក់ការៈ ទី១ គឺ ទប់ទល់សត្រូវ ដើម្បីបង្កើត បរិវេណ នៃជីវិតរស់នៅបាន ជាដំណាក់ការការពារទប់ទល់, ទី២. ពង្រឹង បរិវេណ នៃការការពារ ជាដំណាក់ការ ហ្វឹកហ្វឺនយោធា និង រៀបចំកងទ័ព, ទី៣. ធ្វើសង្គ្រាម វាយលុក ដើម្បី ដេញសត្រូវ ចេញពីទឹកដីដែលពួកវា បានវាយយកទៅកាន់កាប់ ជាដំណាក់ការ ធ្វើសង្គ្រាម ការពារបូរណភាពទឹកដី និង អធិបតេយ្យភាពជាតិខ្មែរ។

**២. ដំណាក់ការ ទប់ទល់ ឬ សង្គ្រាមទប់ទល់**

យួនកុម្មុយនិស្ត មានជំនឿជាក់ច្បាស់ ថាពួកវា អាចវាយរំលាយកងទ័ពខ្មែរ តែមួយសប្តាហ៍ប៉ុណ្ណោះ។ ជំនឿនេះហើយ ដែល លោក Pham Van Dong (1906-2000) អតីតនាយករដ្ឋមន្ត្រី យៀកណាមខាងជើង បានលួចខ្សឹប សម្តេច សីហនុ នៅទីក្រុង ប៉េកាំង នៅថ្ងៃទី ២៧ មិនា ឆ្នាំ១៩៧០ ថា កុំឲ្យព្រះអង្គ មានបារម្ភ ឲសោះ ព្រោះទ័ព រណសិរ្សជាតិរំដោះយៀកណាមខាងត្បូង នៅស្រុកខ្មែរ ឡោមព័ទ្ធ កងទ័ពខ្មែរ រួចស្រេចទៅហើយ ដូច្នេះ វាគ្មានពិបាកអ្វីនឹងវាយរំលំ ឬ បង្ខំ ឲទ័ពខ្មែរ ដាក់អាវុធ ចុះចូល ព្រះអង្គនោះឡើយ។ ជាការពិតមែន យៀកកុង វាយបែក យោធភូមិ (garnison) ជាច្រើននៅដំបន់ព្លសាន និង បុព៌ា ហេតុនេះឯង អគ្គមេបញ្ជាការជាន់ខ្ពស់ខ្មែរ (អ.ម.ប.ខ.ខ.) បានសម្រេចនៅក្នុង ខែមិថុនា បង្វេះចេញ គ្រប់យោធភូមិ ពី ខេត្ត ស្ទឹងត្រែងក្រចេះនិង រតនៈគីរី។ ដោយខ្វះមធ្យោបាយ ផ្លូវអាកាស អ.ម.ប.ខ.ខ. ស្នើសូមជំនួយ ទ័ពអាកាស អាមេរិកាំង។អាមេរិក សុខចិត្តជួយដោយមានជំនួយ កងអាកាស យៀកណាមខាងត្បូង ដែលកំពុងធ្វើប្រតិបត្តិសឹក នៅក្នុងដំបន់នោះស្រាប់ដែលលោកប្រធានាធិបតីអាមេរិកាំង កំពុងអនុញ្ញាតឲធ្វើ។ ប្រតិបត្តិការ បង្វេះ យោធភូមិខ្មែរ នេះ បានជ្រើសរើសកន្លែង៣ទុកជាកន្លែងកំនៀរ (Ramassage) ឬ ណាត់ជួបគ្នា រវាង យោធាខ្មែរនឹង យន្តហោះ អាមេរិកាំង និង យួនខាងត្បូងៈ ក្រុងស្ទឹងត្រែង, ស្រុក សំបាន់ និង វើនសៃ។ អ.ម.ប.ខ.ខ. បញ្ជូន លោក ឧត្តមសេនីយ ប៉ុក-សំអាន ទៅទីក្រុងព្រៃនគរ (Saigon) ដើម្បីដើរតួនាទីជា នាយទាហានខ្មែរ នៃការទំនាន់ទំនង រវាង យោធភូមិខ្មែរ និង កងអាកាសនៃសម្ពន្ធមិត្ត។ នៅក្នុងប្រតិបត្តិការ បង្វេះ នេះ ចំនួន យោធាខ្មែរ ភាគតិចណាស់ ដែលអាច ធ្វើដំណើរមកដល់កន្លែង កំនៀរ បាន ព្រោះ យៀកកុង ពួកវា តាមវាយសម្លាប់តាមផ្លូវ។ ចំណែក យោធភូមិ នៅ ខេត្ត ក្រចេះ និង មណ្ឌលគីរី បានរៀបចំ បង្វេះខ្លួនចេញពីដំបន់ ដោយមានការឧបត្ថម្ភ ពីកងទ័ពជាតិខ្មែរតែម្តង។ តែដោយសារអំពើក្បត់របស់មេបញ្ជាការសឹកខ្មែរ លោក វរៈសេនីយឯក ចេង-សាយោមប៉ូន យោធាខ្មែរ

ដែលនៅក្រោមបញ្ជាលោក ត្រូវបាន ពួកយៀកកុង សម្លាប់ចោលស្ទើរតែទាំងអស់ មានតែបីបួននាក់ ប៉ុណ្ណោះ ដែលអាចរត់គេចខ្លួនរួច។

នៅចំពោះមុខ ការវាយសម្រុក នៃសត្រូវជាតិនេះ អ.ម.ប.ខ.ខ. បានរៀបចំខ្សែក្រវាត់ការពារបរិវេណ នៃសុវត្ថិភាពមួយ ដើម្បីពង្រឹង កងទ័ព អង្គការនយោបាយ និង សោមនស្ស នៃប្រជាពលរដ្ឋ គឺសេចក្តីត្រូវការ របស់ជីវភាព ដោយបង្កើត ខ្សែការពារ ដែលមានឈ្មោះថាបន្ទាត់ទប់ទល់ លន់-នល់ ដែលជាបន្ទាត់កលយុទ្ធ។ បន្ទាត់នេះ ចែកផ្ទៃដីស្រុកខ្មែរជាពីរដំបន់៖ ដំបន់ខាងជើងនិងខាងត្បូង។ ខាងជើងជា សមរភូមិក្តៅ ដែលមានវត្តមានទ័ពយៀកកុង ឯចំណែកខាងត្បូងជាដំបន់កាន់កាប់ដោយកងទ័ពជាតិខ្មែរ។ បន្ទាត់នេះ មានបណ្តោយ ពីព្រំប្រទល់ ខ្មែរ-សៀម ចេញពី ស្រុក អូស្មាច់ ក្នុងខេត្ត ឧត្តមានជ័យកាត់ អង្គរវត្ត ក្នុងខេត្តសៀមរាប បន្តទៅស្រុក មេមុត ក្នុងខេត្តកំពង់ចាម ចាក់រហូត ទៅដល់ទល់ដែនខ្មែរ-យៀកណាមខាងត្បូង។ បន្ទាត់នេះនៅស្របតាម ផ្លូវជាតិលេខ៦ និង ៧ ដែលជា រោហិណីសំខាន់ សំរាប់ជីវិតសេដ្ឋកិច្ចខ្មែរ។

មកដល់ខែ មិថុនា ទស្សនវិស័យ នៃជ័យជំនះ រហ័ស របស់ យៀកកុង កាត់តែបញ្ចៀសពីការនឹកស្មានរបស់ពួកវា រហូតចាត់ទុកថា មិនអាចមានតែម្តង។ កងទ័ពជាតិខ្មែរ រឹតតែមានសេចក្តីទុកចិត្ត លើ សក្តានុភាពរបស់ខ្លួន។ ចំនួនយោធា កាន់តែកើតឡើងដោយសារមានយុវជន រាប់ម៉ឺននាក់ ស្ម័គ្រចិត្តចូលធ្វើទាហាន។ ពីចំនួន ៣ម៉ឺននាក់ទៅ ២សែនកន្លះ តម្រូវឲមានការរៀបចំច្បាស់លាស់ និង ការហ្វឹកហ្វឺន ប្រកបដោយគុណភាពដែលជា ការធានា នៃជីវិត យោធា តែមួយគត់ នៅក្នុងសមរភូមិ។ ដោយសារពួកយៀកកុង យកផ្ទៃដីខ្មែរ ជាសមរភូមិ នៃសង្គ្រាមទាំងអស់ (la guerre totale) រដ្ឋាភិបាលខ្មែរ ត្រូវចាំបាច់ បញ្ជូន យោធាខ្មែរ ទៅហ្វឹកហ្វឺន ក្បួនសឹក នៅក្នុងមជ្ឈមណ្ឌលហ្វឹកហ្វឺនយោធា របស់ អាមេរិកាំង នៅយៀកណាមខាងត្បូង និង នៅប្រទេសសៀម។ អ.ម.ប.ខ.ខ. ចាត់ការរៀបចំ កងឯកភាពយោធាជាថ្មី បង្កើត កងពលតូច និង កងពលធំ ដើម្បី ទប់ទល់នឹង កងពលធំ របស់សត្រូវ ប្រដាប់អាវុធយុទ្ធភ័ណ្ឌទំនើប។ ស្ថានភាពនៅស្រុកខ្មែរ នៅពេលនោះ វាដូចជាឃ្លាមួយ របស់ អ្នកនិពន្ធបរទេសម្នាក់ឈ្មោះ Alberti សរសេរថា៖

*« យើងមិនទាន់ដឹងច្បាស់ថា តើទិសណាមួយ ដែលយើងនឹងអណ្តែតរសាត់ទៅនោះឡើយ នៅកណ្តាលមហាសាគរ ប៉ុន្តែហាក់បីយើងមានអារម្មណ៍ពិសម័យរួចហើយ នៅពេលក្បាលយើង ងើបផុតពីក្នុងទឹក ដែលអាចឲយើងដកដង្ហើមបាន»*

**ទឹកចិត្តយុទ្ធជនខ្មែរ**

យុទ្ធជនខ្មែរ គឺជា យុវជនខ្មែរ កាន់អាវុធ នាំគ្នាទៅច្បាំង ដេញខ្មាំងយួនកុម្មុយនិស្ត ចេញពីមាតុភូមិ។ ដូច លោក អ៊ិន-តាំ មុនលោក ឡើង ឧទ្ទម្ភាគចក្រ ទៅកាន់សមរភូមិ លោក មានប្រសាសន៍ថា «ខ្ញុំមិនចាំបាច់ មានសេចក្តីក្លាហាន នៅចំពោះសត្រូវឥត សាសនា ឈ្លានពានប្រទេសខ្ញុំ នោះឡើយ គ្រាន់តែមាន សភាវគតិ ជាកូនខ្មែរ វាគ្រប់ គ្រាន់ណាស់ហើយ សំរាប់ខ្ញុំបូជាជីវិត នៅក្នុងសមរភូមិ ដើម្បីការពារទឹកដី និង សាសនា ដូនតារបស់ខ្ញុំ» សំដីនេះហើយ ជា ភារៈ នៃទឹកចិត្ត យុទ្ធជនខ្មែរ កាលសម័យនោះ ព្រោះ ភាវគតិ ជា កូនខ្មែរ មិនអាចអោបដៃឈរមើលសត្រូវជាតិ ចូលមករុករានស្រុកខ្មែរ បាននោះឡើយ។ ទឹកចិត្តបែបនេះហើយ ដែលនាំឲមាន ឧទ័យ (émergence) នៃកម្លាំង ជាតិខ្មែរ ដែលអាចរំលាយ នូវការស្រម័យរបស់ខ្មាំង ថាវា អាចវាយយកជ័យជំនះ លើកង ទ័ពជាតិខ្មែរ តែមួយសប្តាហ៍ បានងាយស្រួល។ យុទ្ធជន និង យុវជន ជា អង្គកាយ តែ មួយ ទឹកចិត្តតែមួយ កម្លាំងតែមួយ មិនព្រមចុះចាញ់ខ្មាំង មិនអោយវាបំបាត់សារៈ ធាតុ នូវទឹកចិត្តស្នេហាជាតិ ដោយកាត់ចេញ (éviscérer) ពីព្រលឹងខ្មែរ បាននោះឡើ យ។ ដង្ហើម នៃយុទ្ធជនខ្មែរ ជាកម្លាំងតស៊ូ នៅក្នុងសមរភូមិ បើបងស្លាប់កំពុងបាញ់ តបខ្មាំង មានប្អូន មានឈាមជាតិតែមួយ បន្តការប្រយុទ្ធ សងសឹកជូនអ្នក ឲទាល់តែ បាន ដើម្បីជាតិឈ្នះ។ យុទ្ធជនខ្មែរ មិនមែន ជាពូជអ្នកច្បាំង ដើម្បី សម្លាប់កាប់ចាក់ តែជាខ្មែរអ្នកជា កាន់អាវុធ ធ្វើចម្បាំង ការពារជាតិ ការពារសាសនា។ យុទ្ធជនខ្មែរ មិន មែនជា អ្នកប្រកាន់ពូជសាសន៍ ព្រោះខ្មែរជា មនុស្សនិយម មានសីលធម៌ជាក្បួតនៃ ជីវិត មានទឹកចិត្ត ជាអ្នកសង្គ្រោះអ្នកខ្សត់ ដូចមានចារទុកក្នុងកំណាព្យបុរាណខ្មែរ៖

អ្នកមានរក្សាខ្សត់   ដូចលំពត់ព័ទ្ធពីក្រៅ

អ្នកប្រាជ្ញរក្សាខ្លៅ   ដូចសំពៅនូវសំប៉ាន។

អ្នកខ្ពស់រក្សាទាប   ដោយសភាពធម៌បុរាណ

អ្នកឆ្អែតរក្សាឃ្លាន  នាអ្នករុងរក្សាឆ្នារ។.......

តែ ទឹកចិត្តយុទ្ធជនខ្មែរ នៅចំពោះខ្មាំង ឈ្លានពាន ឥតសាសនា ជា អ្នកតស៊ូ មិនព្រម ថយ បើស្លាប់ គឺ ស្លាប់ក្នុងនាម ជាអ្នកការពារជាតិ បើរស់ គឺរស់ក្នុងនាមជា ខ្មែរតស៊ូរ: មានកិត្តិយស មិនមែន ដូច ស្តេច សីហនុ សុខចិត្តបំរើខ្មាំងជាតិ ដើម្បីប្រយោជន៍អាត្មា រស់គ្មានតម្លៃជាខ្មែរអ្នកជា៖ សួរថា តើ ស្តេច សីហនុ ជាអ្វី ?

### ៣. ដំណាក់ការ នៃភាពពង្រឹង ឬ សង្គ្រាមមហាជន

យួនកុម្មុយនិស្ត ធ្វើសង្គ្រាមនៅក្នុងស្រុកខ្មែរ ខុសពីសង្គ្រាម នៅស្រុកយួនព្រោះវាឥតត្រូវការប្រជាពលរដ្ឋខ្មែរ គាំទ្រវា លើកលែងតែ សម្តេច សីហនុ, បរិវា ព្រះអង្គ, ពួកខ្មែរយៀកមុិញ និង ខ្មែរក្រហម ដូច្នេះសង្គ្រាម របស់ពួកយៀកកុង មានជាតុជាសង្គ្រាមឈ្លានពាន បំផ្លេចបំផ្លាញស្រុកខ្មែរ បង្កើតឲមាន ឡិក្ស ដើម្បីបង្អត់បាយរាស្ត្រខ្មែរ ដែលជាសត្រូវជាធម្មជាតិ របស់ពួកវា។ យុទ្ធសាស្ត្រ «ត្រីរស់នៅក្នុងទឹក» របស់ តាម៉ៅ មិនអាចអនុវត្តន៍បាននោះឡើយ នៅក្នុងស្រុកខ្មែរ ព្រោះពួកយៀកកុង ជាជនបរទេសឈ្លានពានកម្ពុជា។ ត្រូវដឹងថា កាលមុនចម្បាំង ពួកយៀកកុង វា ហាមមិនឲរាស្ត្រខ្មែរទៅជិតជំរុំ របស់ពួកវាជាដាច់ខាត បើដីស្រែ របស់កសិករខ្មែរ នៅក្បែរ ជំរុំវា គឺច្បាស់ជាគាត់មិនអាចចូលទៅដីស្រែគាត់បាននោះឡើយ។ បំរាមបែបអស់នេះហើយ ដែលជាបុព្វហេតុ នៃបាតុកម្មកើតមានឡើងនៅខេត្តស្វាយរៀង។

មួយវិញទៀត រណសិរ្សរួបរួមជាតិកម្ពុជា ដែលចិនបង្កើតឲ សម្តេច សីហនុ វាគ្មានការគាំទ្រពីសំណាក់យៀកកុង នៅក្នុងទឹកដីខ្មែរ ព្រោះពួកយៀកកុង គេដើរតួដោយខ្លួនឯងតែម្តង ដែលមាន ពួកខ្មែរ យៀកមុិញ ជាអាយ៉ង។ ចំណែក ពួកខ្មែរ ក្រហមវិញ មានចំនួនតិចតួចបំផុត ព្រោះគ្មាន រាស្ត្រខ្មែរ ស្ម័គ្រចិត្ត ចូលធ្វើយោធាខ្លួន ហើយក៏គ្មាន បឃោសនាបាយ ទាំង ក្នុងវិស័យ នយោបាយ និង យោធា ដើម្បី បង្ហាញ នូវវត្តមានខ្លួនពិតប្រាកដ នៅក្នុងដំបន់កាន់កាប់ដោយ ពួកយៀកកុង។ ចិនប្រជាមានិតស្នើ យួនកុម្មុយនិស្ត ឲជួយបង្កើត កងទ័ពខ្មែរក្រហម និង ផ្តល់សម្ភារះយោធា សំរាប់ចំនួនទាហានប្រមាណ ៦ពាន់នាក់ តែពួកយៀកកុង គេធ្វើមិនដឹងឮ ព្រោះពួកគេយល់ឃើញថាទ័ពនេះវាគ្មានប្រយោជន៍អ្វីដល់ពួកគេ ផ្ទុយទៅវិញ វាមានតែរំខាន ដល់យុទ្ធសាស្ត្ររបស់គេទៅវិញ។ តែដើម្បីយករំងាប់ចិត្តចិន Pham Van Dong ឆ្លើយតបចិនថា គាត់នឹងជួយបង្កើត តែទ័ពនេះត្រូវស្ថិតនៅក្នុងយុទ្ធសាស្ត្រ របស់យួន គឺថា នៅក្នុង បញ្ជាការ របស់យួន។ គេដឹងថារហូតដល់ឆ្នាំ ១៩៧៣ ពាក្យសន្យា របស់ Pham Van Dong ជាសំដីខ្យល់ ព្រោះ យៀកកុងមិនសូវរវីរវល់ នឹងរឿងបង្កើតទ័ពរណសិរ្សរួបរួមកម្ពុជា ប៉ុន្មានទេ រហូតចិន បាត់អំណត់ បញ្ជូន អ្នកឯកទេសចិន ក្នុងវិស័យយោធា ជាច្រើនមកក្នុងកម្ពុជា ដើម្បីជួយ ឧបត្ថម ពួកខ្មែរក្រហម និង ជំរុញយួនឲប្រដាប់អាវុធដល់ពួកនេះ ក្នុងភាគកំណត់ នៃជំនួយចិន ដល់ យួន។ ដូច្នេះ សង្គ្រាម ពីឆ្នាំ ១៩៧០ ដល់ ឆ្នាំ ១៩៧៣ ជា សង្គ្រាម តទល់គ្នា ដោយចំពោះ រវាងកងទ័ពជាតិខ្មែរ នឹង ទ័ពយួនកុម្មុយនិស្ត នៅលើទឹក

ដីខ្មែរ ក្នុង លក្ខណៈ ជាសង្គ្រាមឈ្លានពាន ពីសំណាក់ កងទ័ពយួនកុម្មុយនិស្ត មកលើបូរណភាពទឹកដីខ្មែរ។

ក្រោយពីបានទប់ទល់ ប្រកបដោយជោគជ័យ នូវការវាយលុក របស់ ពួកយៀកកុង អគ្គបញ្ជាការ នៃកងទ័ពជាតិខ្មែរ បាន បង្កើត ខ្សែរបន្ទាត់ទប់ទល់ មួយ ដើម្បី ទុកពេលវេលាឲ្យខ្លួន មានលទ្ធភាពពង្រឹង កម្លាំងតស៊ូ។ ខ្សែរបន្ទាត់នោះ គេឲ្យឈ្មោះថា ខ្សែរបន្ទាត់ «លន់-នល់»។

កិច្ចការប្រញាប់ របស់ អគ្គសេនាធិការ (État-Major Général) នៃកងទ័ពជាតិ គឺត្រូវហ្វឹកហ្វឺនជាបន្ទាន់ ចំនួន យោធាខ្មែរ ៦០ ០០០ នាក់ ដែលស្ម័គ្រចិត្តចូលធ្វើទាហាន។ ហើយ ដើម្បីឆ្លើយនឹង សេចក្ដីត្រូវការ ជាបន្ទាន់ នៃសមរភូមិ គេ ត្រូវបន្ថយ រយៈពេល ហ្វឹងហ្វឺន គឺ កាត់នៅត្រឹមតែពាក់កណ្ដាល ដែលវាខុសពី ក្បួនសិក្សាកងទ័ព។ ក្នុងពេលជាមួយគ្នានោះដែរ រដ្ឋសភាជាតិ បានអនុញ្ញាតិ ឲ រដ្ឋាភិបាល ធ្វើ កំណែនទ័ព ដោយប្រើពាក្យស្លោកថា «ការតស៊ូការពារជាតិ»។ ដូចបានជំរាបខាងលើរួចមកហើយថា យុវជនខ្មែរ រាប់ម៉ឺននាក់ បានស្ម័គ្រចិត្តចូលធ្វើទាហាន រួចស្រេចទៅហើយ ដូច្នេះ ការប្រើច្បាប់នៃកំណែនទ័ព នេះ វាគ្រាន់តែជាទម្រង់ការ តែប៉ុណ្ណោះ។ ម្យ៉ាងទៀត នៅស្រុកខ្មែរ ធ្លាប់មាន កងកម្លាំង យោធាប្រតិព័ទ្ធ[18] នៅតាមភូមិ ដែលមានឈ្មោះថា «កងជីវពល» ឬ «កងកម្លាំងការពារភូមិ»។ កងកម្លាំងនេះ បង្កើតឡើង នៅក្នុង ចន្លោះឆ្នាំ ១៩៤៩-១៩៥៣ គឺថា នៅពេល ធ្វើ បូជនិយកិច្ច ទាមទារ ឯករាជ្យ។ ចំពោះ កងកម្លាំទ័ពជាតិ (កកទជ) ការដែលត្រូវធ្វើជាប្រញាប់មួយដែរ គឺ ប្រដាប់អាវុធ ជាបន្ទាន់ ដល់កងជីវពល ដើម្បីការពារភូមិរបស់ខ្លួន។ ត្រូវដឹងថា នៅថ្ងៃទី១ ដែលពួកយៀកកុងវាយប្រហារមូលដ្ឋាន កកទជ ពេលនោះ កងវរសេនាតូច លេខ៣ នៅខេត្ត ក្រចេះ, លេខ១ នៅខេត្ត តាកែវ និង លេខ៩ នៅខេត្ត ស្វាយរៀង បានធ្វើការប្រយុទ្ធទប់ទល់ខ្លាំងដោយអង់អាច ដែលប្រដាប់អាវុធទំនើប ហើយមានចំនួនច្រើន ជាងខ្លួន។ កិច្ចការចាំបាច់មួយទៀត របស់ កកទជ គឺ រៀបចំបង្កើតឲមាន កងវរសេនាធំ (Régiment) និង កងពលតូច (Brigade) ដើម្បី បញ្ជូនទៅកាន់សមរភូមិឲទាន់ពេលវេលា។ ដូច្នេះ នៅពេលនោះយោធា ដែលបញ្ជូនទៅសមរភូមិ បានទទួលការហ្វឹកហ្វឺន តែ ១សប្ដាហ៍ តែប៉ុណ្ណោះ

[18] កងកម្លាំង យោធាប្រតិព័ទ្ធ= Force paramilitaire។

ដែលអ្នកសារពត៌មាន អន្តរជាតិ អោយឈ្មោះថា «យោធា ២៤ ម៉ោង»។ បួនថ្ងៃក្រោយ ពីពួកយៀកកុង បើកការវាយប្រហារ ចំនួនយោធា កកទជ កើនជាទ្វេ ដូច្នេះការ រៀបចំ កងឯកភាពនិមួយ ៗមានប្រសិទ្ធភាព គឺចំបាច់ត្រូវ លាយគ្នា ពាក់កណ្តាល ជា យោធាចាស់ ពាក់កណ្តាលទៀត ជាយោធាថ្មី។ ហើយនៅក្នុងសមរភូមិ យោធាចាស់ ជួយ បង្ហាត់បង្រៀន នូវបច្ចេកទេសសឹក ដល់យោធាថ្មី នៅក្នុងទឹកចិត្ត ភាតរភាព។ យុទ្ធជន ខ្មែរជាច្រើនណាស់ បានយកជីវិតខ្លួន ទៅប្តូរក្នុង សម្ពរកម្ម ដំបូង នេះ នាំឲខ្មាំង ហូរ លោហិត នូវបរាជ័យ ដែលជា ភេទនការណ៍[19] របស់វា នៅចំពោះការប្តេជ្ញាចិត្ត របស់កូន ខ្មែរ ថា ហ៊ានស្លាប់ ដើម្បី ជាតិ រស់។

ក្នុងរយៈពេលតែ បីបួនខែតែប៉ុណ្ណោះ ចំនួនទាហានខ្មែរ កើនឡើងជាច្រើន។ ពីខែ មិថុនា ឆ្នាំ ១៩៧០ មានចំនួន ១០០ ០០០ នាក់ មកដល់ ខែ កក្កដា ចំនួន កើតដល់ទៅ ២០០ ០០០ នាក់។ កកទជ ទម្រង់រូប (structurer) ចំនួនយោធា ជា កងពលតូច ដើម្បី បង្កើន នូវកម្លាំង នៃអគ្គី (puissance de feu) នៅក្នុងសមរភូមិះ

- កងពលតូចលេខ១ មាន បញ្ជាការដ្ឋាន នៅទីក្រុងភ្នំពេញ គឺជាកងពលបំរុង ;

- កងពលតូចលេខ២ មាន បញ្ជាការដ្ឋាន កំពង់ចាមក្រុង ជា អាថិកងម្លាំង ក្នុង ភូមិភាគយោធា ទី១ ;

- កងពលតូចលេខ៣ មាន បញ្ជាការដ្ឋាន នៅក្រុងកំពង់សោម ទទួលបន្ទុកសឹកនៅ ក្នុង ភូមិភាគយោធា ទី២ ;

- កងពលតូចលេខ៤ មាន បញ្ជាការដ្ឋាន នៅ ខេត្តព្រៃវែង ក្នុងភូមិភាគយោធាទី១ ទទួល បេសកកម្ម ពិសេស ការពារ ដងទន្លេ មេកុង, ការពារ ស្រុក នាក់លឿង និងខេត្ត ព្រៃវែង ;

- កងពលតូចលេខ៥ មាន បញ្ជាការសឹក នៅទីក្រុងភ្នំពេញ ជាកងពលបំរុង ដែលមាន យោធា សុទ្ធតែជាខ្មែរអ៊ីស្លាម ;

---

[19] ភេទនការណ៍= ហេតុដែលដែលយំ។

- កងពលតូចលេខ៦ ជាកងពលចល័ត ធ្វើប្រតិបត្តិការសឹក នៅខេត្តកំពត និង កំពង់ចាម ក្នុងភូមិភាគយោធា ទី២។ កងពល នេះ មានសុទ្ធតែខ្មែរអ៊ីស្លាម។

- កងពលតូចលេខ៨ ធ្វើប្រតិបត្តការសឹក នៅក្នុងខេត្ត តាកែវ និង មាត់ជ្រូក(ចៅដុក) ក្នុងភូមិភាគយោធា ទី២។ កងពលនេះ មានយោធា សុទ្ធតែ ខ្មែរមានកំណើតនៅខេត្ត តាកែវ និង កណ្ដាល ;

- កងពលតូចលេខ១០ ធ្វើប្រតិបត្តការសឹកនៅក្នុងភូមភាគយោធាទី៤(ខេត្តសៀមរាប កំពង់ធំ និង ឧត្តរមានជ័យ ;

- កងពលតូចលេខ១១ ជាកងម្លាំងជំនួយ មានតួនាទី ជាអ្នកការពារផ្លូវជាតិលេខ៥ និង ខេត្ត តាកែវ។ យោធានៅក្នុងកងពលនេះ ជាខ្មែរស្មគ្រចិត្ត មានដើមកំណើត នៅខេត្តកណ្ដាល ;

- កងពលតូចលេខ១២ ជាកងពល ដែលមានយោធា ជាខ្មែរស្មគ្រចិត្ត មានដើមកំណើត នៅខេត្តសៀមរាប និង បាត់ដំបង។ កងកម្លាំង នេះ មាន បញ្ជាការដ្ឋាន នៅខេត្តសៀមរាប សំរាប់ ការពារខេត្តសៀមរាប ;

- កងពលតូចលេខ១៣ មានបញ្ជាការដ្ឋាន នៅទីក្រុង កំពង់ស្ពឺ ការពារទឹកដីខេត្តកំពង់ស្ពឺ តែធ្លាប់បានចូលរួមប្រតិបត្តិសឹក នៅសមរភូមិ នៅ ខេត្តតាកែវ និង ស្រុកអង្គតាសោម បន្ទាប់មក ទទួល បេសសកម្ម ការពារផ្លូវជាតិលេខ៤ ;

- កងពលតូចលេខ១៤ មានបញ្ជាការសឹក នៅស្រុក ត្រាំខ្នា ធ្វើប្រតិបត្តការសឹក នៅក្នុងភូមិភាគយោធាទី២។ ដើមឡើយ កងពលនេះ ជាកងឯកភាពកាំភ្លើងបាញ់យន្តហោះ ក្រោយពីបានទទួលបារាជ័យសឹក នៅក្នុងសមរភូមិ ភក់-លុង អ.ម.ប.ខ.ខ. បានរៀបចំឡើងវិញ៧ទៅជា កងពលតូច ធ្វើប្រតិបត្តិការសឹក នៅក្នុងភូមិភាគយោធាទី២។

ក្នុងឆ្នាំ ១៩៧១ លោក ឧត្តមសេនីយ លន់-នល់ បានរៀបចំផែនការមួយ ដើម្បីគ្រោងបង្កើនចំនួនអ្នកតស៊ូ ៧មានចំនួន ៦០០ ០០០ នាក់ ដែលជា កម្លាំងកងទ័ពនិងកម្លាំង មហាជន នៅក្នុងនោះ មាន កងជីវពល ចំនួន ៥៣ ០០០ នាក់ ដែលជាកម្លាំងវាយពេញប្រទេស (force de surface) និងជា កម្លាំងចំណុច (force des points)។ កម្លាំងទ័ព ជាកម្លាំងវាយសម្រុកទៅលើខ្មាំង រីឯ កម្លាំងមហាជន ជាកម្លាំងការពារភូមិស្រុក ទីក្រុង ហើយកម្លាំងទាំងពីរនេះ ជាកម្លាំងឯកភាពតែមួយ ដើម្បីធ្វើសង្គ្រាមមូលដ្ឋានមហាជន ដើម្បីវាយលុក និង ទប់ទល់ យកជ័យជំនះជាស្ថាពរ។

ផែនការនេះលោក លន់-នល់ បានយកទៅស្នើសុំជំនួយ អាមេរិកាំង តែ អាមេរិកាំង គេ មិនគាំទ្រ ព្រោះវាផ្ទុយ ពីនយោបាយដកទ័ព របស់គេ ចេញពី យៀកណាម។ នៅក្នុង ចំណុចនេះ បញ្ជាក់ឲយើញថា ស.រ.អ. គេភ្ជាប់ សង្គ្រាមនៅស្រុកខ្មែរ ដែលជា សង្គ្រាម រំដោះជាតិ ទៅនឹង សង្គ្រាមនៅស្រុកយួន ដែលជា សង្គ្រាម ស៊ីវិល។ ការយល់បែប នេះបើ តាម យល់របស់ខ្ញុំ គឺជា ការភាន់ច្រឡំ អាមេរិកាំង អាចនឹងមាន ផលវិបាក ក្នុង អបរកាល (dans le futur) ដល់ជាតិខ្មែរ នៅពេលយៀកណាមរួបរួមគ្នា តែមួយ ព្រោះអា មេរិកកាំង មិនជួយខ្មែរ ឲមានលទ្ធភាព ទប់ទល់នឹង យៀកណាម និង គ្រោះថ្នាក់ នៃ កុម្មុយនិស្ត ដល់ស្រុកខ្មែរ។ អ្វីដែលខ្មែរ មានការបារម្ភ វាបានកើតឡើងមែន គឺនៅក្នុង ឆ្នាំ ១៩៧៥ និង ១៩៧៩ ស្រុកខ្មែរ ធ្លាក់ចូលទៅក្នុងរណ្តៅ កុម្មុយនិស្ត យួនចិន និង ក្លាយ ជាប្រទេសអាណានិគម៌យៀកណាម មកដល់សព្វថ្ងៃនេះ។ វិទូយុទ្ធសាស្ត្រសង្គ្រាម ចិន ម្នាក់ ថ្លែងថា ដើម្បីយកជ័យជំនះ លើខ្មាំង ត្រូវយើង ស្គាល់ខ្លួនឯង និង សត្រូវ ឲច្បាស់ ចំពោះ អាមេរិកាំង គេពិតជា ស្គាល់ខ្លួនគេច្បាស់ណាស់ ហើយ ប្រហែលជាគេស្គាល់ សត្រូវ គេ ច្បាស់ផងដែរ តែខ្ញុំមានជំនឿថា អាមេរិកាំង មិនបានស្គាល់ មិត្តរួមអារុជ របស់ខ្លួន ច្បាស់នោះឡើយ ជាពិសេស ស្គាល់ខ្មែរ ដូច លោក អ៊ិន-តាំង លោក បានធ្វើគំនន់ (remarque) ញយដង។ តាមពិត ស.រ.អ. បោះបង់ខ្មែរ តាំងពីឆ្នាំ ១៩៧១ មកម្លេះ ព្រោះ សង្គ្រាមរំដោះជាតិរបស់ខ្មែរ វានាំរំខាន ដល់ ផែនការសន្តិភាព អាមេរិកាំង ជាមួយ យួន កុម្មុយនិស្ត និងការរងទំនាក់ទំនងជាមួយចិនប្រជាមានិត។ គួរអាណោចដល់ខ្មែរយើង ណាស់ ! (Pauvre khmer !)។

## សាកល្បងសិក្សាអំពីកុម្មុយនិស្តយួន ឬ ឥណ្ឌូចិន[20]

### ក. សេចក្តីសង្ខេត

---

20 ដកស្រងពីឯកសារ នៃសាលាសង្គ្រាមនយោបាយ នៃសាធារណរដ្ឋខ្មែរ។

**ទី១៖** កុម្មុយនិស្តឥណ្ឌូចិននេះ ខ្លះធ្លាប់ឲ្យឈ្មោះថាកុម្មុយនិស្តយួន ខ្លះទៀតថាជាយួនខាងជើង ខ្លះទៀតថាជាយៀកមិញ ខ្លះទៀតថាជា យៀកកុង។ ការពិតទាំងអស់នេះមានតែមួយគត់ គឺកុម្មុយនិស្ត ដែលយើងឲ្យឈ្មោះថា «កុម្មុយនិស្តឥណ្ឌូចិន» នេះឯង។

ដោយហេតុថា កុម្មុយនិស្តឥណ្ឌូចិននេះ មានឫស មានគល់ជា «យួន» យើងគោងសិក្សាអំពីយួននេះក្នុងឋានៈជាជាតិសាសន៍មួយឲបានស្គាល់បន្តិចសិន។

**ក១. ដើមកំណើតនៃជនជាតិយួន**

ជនជាតិយួនមានដើមកំណើត នៅក្នុងស្រុកចិន ម្តុំខាងត្បូងសៀងហៃ តាមទំនាបនៃទន្លេ យ៉ង់ សេ (YANG TSE)។ ពួកនេះមានឈ្មោះដើមហៅថា ណាំវៀត (NAMVIET) ឬ យូវ៉េ (YUE) ដែលខ្មែរឲ្យឈ្មោះថាយួន។ សាសន៍យួននេះគ្មានជាប់ពូជអំបូរជាមួយខ្មែរមនទេ។

## ខ. ការរាតត្បាតនៃជាតយួនមកលើដែនដីតុងកឹង

ដែនដីតុងកឹង ឬ ដីទំនាបទន្លេក្រហម (Delta du fleuve rouge) ដែលយួនហៅថា «បាក់គី» (BAC KY) ឬ យួនកុម្មុយនិស្តនិយមហៅថា «បាក់បូ» (BAC BO) ជាដីរបស់កុលសម្ពន្ធ ម៉េវ (MEO) ម៉ុយ (Moïs) ថៃ មិន (MAN) ។ល។

លុះដល់ឆ្នាំ ១១១ មុន គ.ស. ទើបជនជាតិយួន វាតទី មកលើតំបន់នេះ។ គេតាំងរដ្ឋធានីមួយឈ្មោះហៅថា ក្រុងដុងគិញ (DONG KINH) ដែលក្រោយមកដូរឈ្មោះថា ហាណូយ។ ចំណែកឯជនជាតិដើម ក៏នាំគ្នាភៀសខ្លួនឡើងទៅនៅលើភ្នំអស់ទៅ។

តុងកឹង ឬ បាក់គីនេះគឺស្ថិតនៅក្រោមការត្រួតត្រាចិនប្រហែល ១០០០ ឆ្នាំ គឺពីឆ្នាំ ១១១ មុនគ.ស. រហូតដល់ឆ្នាំ ៩៣៩ នៃគ.ស.។

## គ. ការវាតទីនៃជនជាតយួនមកលើនគរចំប៉ា

នគរចាម ឬ ចំប៉ា លាតសន្ធឹងតាមឆ្នេរសមុទ្រចិន ចាប់ពីតាំងពីខែត្រ ក្វាប៊ិញ (QUANG BINH PHANTHIET) រហូតដល់ខែត្រ ផាន់ ធាត (QUANG ETIH-QUANHIET) ដែលមានរដ្ឋធានីឈ្មោះ ពិជ័យ(VIJAYA)។

ជនជាតិយួនបានដណ្តើមយកនគរចំប៉ានេះពីចាមបាន ក្នុងកំឡុង ពីឆ្នាំ ៦០៥ រហូតដល់ឆ្នាំ ១៤៧០។ គេប្រែឈ្មោះហៅថា អាណ្ណាម ឬ ដែលយួននិយមហៅថា «ទ្រុង

គី» (TRUONG KY) ពួកកុម្មុយនិស្តហៅថា «ទ្រុងបូ» (TRUONG BO) ដែលមានរដ្ឋធានីឈ្មោះ ក្រុងវ៉េ (HUE)។

ក្នុងការដណ្តើមនគរចាមនេះ យួនគេប្រើមធ្យោបាយពិសេស ៣យ៉ាងគឺៈ

- លបជ្រៀតជ្រែងចូលតាំងទីរស់នៅដោយសន្តិភាព,
- កាលណាចូលតាំងទីបានហើយ គេនាំគ្នាធ្វើឲអំណាចកណ្តាលខ្សោយ,
- អន្តរាគមយោធា។

ក្រៅពីនេះ គេមានប្រើកលឧបាយផ្សេងៗ ដូចជាសំណូកសូកប៉ាន់ ជាស្ត្រីរូបស្អាត ឬ ជាវត្ថុមានដំឡៃ ។ល។ ឧទាហរណ៍ កាលពីឆ្នាំ ១៣០៦ ស្តេចយួនបានលើកកូនក្រមុំ ឈ្មោះនាង «ត្រាន» (HUYEN TRAN) ទៅថ្វាយស្តេចចាមឈ្មោះ ព្រះបាទ ឆេម៉ាន់ (CHEMAN) ដែលនាំឲចាមខាតបង់ខែត្រមួយយ៉ាងធំ គឺខែត្រ អូលី ឯកសារខ្លះថា អូ ជាខែត្រ ឯ លី ក៏ជាខែត្រមួយទៀតដែរ ដែលយួនប្រែឈ្មោះថា ធុយ អាន វ៉ា (THUAN HAO)។

## ឃ. ការរាតត្បាតនៃជនជាតយួនមកលើកម្ពុជាក្រោម

ក្នុងការដណ្តើមយកដីខ្មែរនៅកម្ពុជាក្រោមនេះ យួនប្រើមធ្យោបាយ ដូចកាលដែលគេប្រើដើម្បីដណ្តើមយកនគរចាមដូច្នេះដែរ។ គេបានប្រើពេលច្រើនសតវត្ស រហូតមកដល់ឆ្នាំ ១៩៤៩ ទើបយកកម្ពុជាក្រោមបាន។ ដីខ្មែរកម្ពុជាក្រោម បើរាប់ទាំងកោះត្រឡាច និងកោះត្រល់ផង មាន២១ខែត្រ ដែលមានឈ្មោះដូចតទៅៈ

ទួលតាម៉ូក (THUDAUMOT), ត្រពាំងស្រែកាត្រី (BIEN HOA), ស្រែអំបិល (BARIA), រោងដំរី (TAYNINH), ព្រៃនគរ (SAIGON), ដំបូកកោង (GOCONG), មេសរ (MYTHO), កំពង់ឫស្សី (BENTRE) មាត់ជ្រូក (CHAUDOC), ពាមបារាជ (LONGYUEN), ផ្សារដែក (SADEC), ឡុងហោ (VINHLONG), ព្រះត្រពាំង (TRAVINE), ពាម (HATIEN), ក្រមួនសរ (RACHGIA), ព្រែកឫស្សី (CANTHO), ឃ្លាំង (SOCTRANG) ,ពលលាវ (BACLIEU), ទឹកខ្មៅ (CAMAU), កោះត្រល់ (PHU QUOC), កោះត្រឡាច (CONG SONG ou POULO CONDOR)។

គួរកត់សំគាល់ថា ឈ្មោះខែត្រទាំងនេះត្រូវបានយួនគេដូរឈ្មោះជាច្រើនលើកច្រើនសារ ប្រយោជន៍ដើម្បីបំបាត់ឲអស់នូវអនុស្សាវរីយ៍ទាំងឡាយរបស់ម្ចាស់ដើម។

មកដល់ត្រង់នេះយើងឃើញថា ក្នុងកំឡុងពេលវេលាប្រហែល ២០០០ឆ្នាំ ជនជាតិយួនបានដណ្តើមយកដី គេឯង បានជាច្រើន គឺប្រមាណ ៣៣៤.០០០ គ.ម$^2$។ ព្រឹត្តិការណ៍នេះ

អ្នកប្រាជ្ញប្រវត្តិសាស្ត្រ និយមឲឈ្មោះថា «មហាដំណើរនៃជនជាតិយួនឆ្ពោះទៅទិសខាងត្បូង»។

**ទី២៖ តើអ្នកណាខ្លះជាកុម្មុយនិស្តពេញលក្ខណ: ?៖**

បណ្តាអ្នកដឹកនាំធំៗ នៃកុម្មុយនិស្តមានតែ ហូជីមិញ មួយគត់ ដែលជាសមាជិកពេញលក្ខណ:នៃអន្តរជាតិទី៣ នៅក្រុងមូស្គូ។ អ្នកដឹកនាំឯទៀតៗ សុទ្ធតែជាអ្នកជាតិនិយមទាំងអស់។ ប៉ុន្តែគេនាំគ្នាជ្រើសរើសយក លទ្ធិកុម្មុយនិស្តនេះ ដើម្បីជា មធ្យោបាយ មួយ ដើម្បី សម្រេច នូវគោលបំណងគេ ក្នុងការបំរើដល់ប្រយោជន៍ប្រទេសជាតិគេតែប៉ុណ្ណោះ។

**ទី៣៖ គោលបំណងរបស់កុម្មុយនិស្តឥណ្ឌូចិន៖**

**ក**. ទាមទារយកដឹកម្ពុជាក្រោមដោយយកលេសថា «ឯកភាព» នៃជនជាតិយួន(បង្រួបបង្រួមដំបន់បីៈ តុងកឹង,អាណ្ណាម និង កម្ពុជាក្រោម ឬ កូសាំងស៊ីន),

**ខ**. ទាមទារឯករាជឲប្រទេសយួន,

**គ**. ដេញបារាំងចេញពីឥណ្ឌូចិន,

**ឃ**. ត្រួតត្រាឥណ្ឌូចិនជំនួសបារាំងក្នុងឋាន:ជាយួន។

គួរកត់សំគាល់ថា ហូជីមិញ បានធ្វើញត្តិមួយក្នុងនាម «ឥណ្ឌូចិន» សុំចូលជួប លោកប្រធានាធិបតី វិល សុន (WILSON) នៅក្រុងប៉ារីស៍។

**ទី៤៖ បុព្វហេតុធំៗ ដែលនាំឲយួនជ្រើសរើសយកលទ្ធិកុម្មុនិស្តមកធ្វើជាមធ្យោបាយដើម្បីដណ្តើមយកឥណ្ឌូចិន៖**

**ក. បដិវត្តន៍នៅប្រទេសចិន ឆ្នាំ ១៩១១៖**

ដើម្បីរំលំរបបរាជានិយមនោះ អ្នកដឹកនាំបដិវត្តន៍ចិន បានហៅអ្នកជំនាញការ រុស្សីជាច្រើនឲមកធ្វើការក្នុងប្រទេសខ្លួន។ ហូជីមិញ ក៏ត្រូវបានអង្គការអន្តរជាតិទី៣ នៅក្រុងមូស្គូ ប្រើមកឲធ្វើការនៅក្នុងប្រទេសចិនដែរ ក្នុងឋាន:ជាអ្នកប្រែភាសាឲអ្នកជំនាញការរុស្សី។ អ្នកជំនាញការទាំងឡាយនោះ បានខិតខំប្រឹងប្រែងធ្វើសកកម្មភាព បំរើចលនាកុម្មុយនិស្តអន្តរជាតិយ៉ាងខ្លាំង។ ដោយមានជំនួយពីហូជីមិញផង ពួកយួនដែល

រស់នៅក្នុងប្រទេសចិនក៏បាក់ចិត្តបាក់គំនិត ដោយសារការឃោសនារបស់អ្នកជំនាញការទាំងនោះទៅ។

ម្យ៉ាងទៀត សមាជទី២ នៃអន្តរជាតិទី៣នៅឆ្នាំ ១៩២០ បានសម្រេចៈ

- បង្កើតការិយាល័យនយោបាយកុម្មុយនិស្តមួយនៅក្នុងក្រុង សៀងហៃ នៃប្រទេសចិន ដើម្បីងាយនឹងផ្តល់ជំនួយគ្រប់បែបយ៉ាងចំពោះកុម្មុយនិស្តអាស៊ី,
- «ជួយរំដោះ» ប្រទេសទាំងអស់ក្នុងលោកឲផុតពីអាណានិគមចាស់,
- គាំទ្រចលនាស្នេហាជាតិទាំងអស់ក្នុងលោក,

**ខ. ព្រឹត្តិកាល[21] នៃកុម្មុយនិស្តចិនៈ**

គណបក្សកុម្មុយនិស្តចិន បានចាប់កំណើតនៅឆ្នាំ ១៩២១។ ពួកនេះដណ្តើមអំណាចពីលោក ចាងកៃឆែក (Tchiang Kai Shek) បាននៅឆ្នាំ ១៩៤៩។ ចាប់តាំងពីពេលនោះមក កុម្មុយនិស្តចិនបានក្លាយទៅជាបង្អែកមួយយ៉ាងមាំបំផុតសំរាប់កុម្មុយនិស្តយួនឬឥណ្ឌូចិន។ ជំនួយខាងសម្ភារៈគ្រប់បែបយ៉ាងមកពីរុស្ស៊ីក្តី មកពីចិនក្តី មកពីប្រទេសកុម្មុនិស្តទៀតៗក្តី ត្រូវដឹកកាត់ប្រទេសចិនទាំងអស់។ មិនតែប៉ុណ្ណោះ ជ័យជំនះរបស់ម៉ៅសេងទុង នេះ បានទៅជាបង្អែកខាងចិត្តសាស្ត្រមួយយ៉ាងធំរបស់ ហូជីមិញ។

**គ. រណសិរ្សប្រជាមានិតនៃប្រទេសបារាំងរបស់ លោក ឡេអុងប្លុម (Léon Blum)ៈ**

នៅឆ្នាំ ១៩៣៦ ពួកកុម្មុយនិស្តបារាំងបានឡើងកាន់អំណាចនៅប្រទេសបារាំង ក្រោមការដឹកនាំ របស់ ឡេងុងប្លុម។ ក្នុងឋានៈជាកុម្មុយនិស្តដូចគ្នា រណសិរ្សប្រជាមានិត របស់ ឡេអុងម្លុម បានជ្រុំជ្រែងកុម្មុយនិស្តឥណ្ឌូចិនរបស់ហូជីមិញយ៉ាងច្រើន។

**ឃ. កត្តាហូជីមិញៈ**

កត្តាមួយដែលធំជាងគេក្នុងការដែលធ្វើឲកុម្មុយនិស្តឥណ្ឌូចិនមានជីវិតបានរហូតដល់សព្វថ្ងៃនេះ គឺការប្រឹងប្រែងរបស់ហូជីមិញនេះឯងតែម្តង។

---

[21] ព្រឹត្តកាល= Avènement។

## I. ប្រវត្តសង្ខេបនៃគណបក្សកុម្មុនិស្ត ឥណ្ឌូចិន

### ទី១៖ សមាគមយុវជនបដិវត្តន៍យួន៖

ហូជីមិញ ដែលកាលណោះមានឈ្មោះជា ង្វៀងអៃកុក នៅឡើយ បានដឹកនាំអ្នកស្នេហាជាតិយួន ដើម្បី បង្កើតសមាគមនេះឡើង នៅក្រុងកង់តុង ក្នុងប្រទេសចិនក្នុង ១៩២៥។ សមាគមនេះបង្កើតឡើង ក្នុងគោលបំណង អប់រំជនជាតិយួន ឲមានស្មារតីជាតិនិយម។ សមាជិកសំខាន់ៗដែលបង្កើតសមាគមនេះគឺ ហូជីមិញ, ហូទុងម៉ៅ, ឡៃហុងផុង, ហុងសុង, ផាំវ៉ាន់ដុង ។ល។

អង្គការដែលសំខាន់ជាងគេ របស់សមាគមនេះគឺ ទស្សនាវដ្តី មួយមានឈ្មោះ «យុវជន» (Thanh Nien)។ នៅឆ្នាំដដែលនេះ ពួកអ្នកស្នេហាជាតិទាំងឡាយ ដែលទើបនឹងចេញពីកោះត្រឡាចបានបង្កើតគណបក្សមួយ ឈ្មោះ គណបក្សបដិវត្តន៍នៃយួនថ្មី។ ក្រោយមកគណបក្សនេះមានបំណងដូច ហូជីមិញ ក៏ចូលជាសមាជិកនៃសមាគមយុវជនបដិវត្តន៍យួនទៅ។

លុះឆ្នាំ ១៩២៧ លោក ចាងកៃឆែក បានដេញពួកជំនាញការរុស្សី ហើយនឹង ហូជីមិញ ឲត្រឡប់ទៅមូស្គូវិញ។ សមាជិកសំខាន់ៗខ្លះទៀតត្រូវបានចិនចាប់បាន ហើយដាក់គុក។

ដល់ឆ្នាំ ១៩២៩ ហុងសុង ដែលជាអ្នកទទួលខុសត្រូវ ចំពោះសមាគម ជំនួស ហូជីមិញ បានកោះប្រជុំសមាជិក ដែលសល់ទាំងប៉ុន្មាន នៅក្រុងហុងកុង។ សមាគមនេះក៏ត្រូវរលាយនៅពេលនោះទៅ។ សមាជិកទាំងប៉ុន្មានបែកគ្នាជា៣ពួក ហើយបង្កើតគណបក្ស ៣។

### ទី២៖ គណបក្សកុម្មុយនិស្តឥណ្ឌូចិន៖

គណបកសនេះកើតឡើងនៅខែមិថុនា ១៩២៩។ សមាជិកភាគច្រើនមកពីសមាគមយុវជនបដិវត្តន៍យួន ខ្លះទៀតមកពីគណបក្សយួនថ្មី ខ្លះទៀតមកពីសមាគមឥណ្ឌូចិនរបស់ង្វៀងអាននិញ។

### ទី៣៖ គណបក្សកុម្មុយនិស្តអាណ្ណាមីត៖

គណបក្សកុម្មុយនិស្តអាណ្ណាមិតនេះ កើតឡើង កាលពីខែតុលា ១៩២៩។ អ្នកបង្កើតគ្មានគោលបំណងនយោបាយ ធំដុំទេ គឺគ្រាន់តែ ដើម្បីដេញជើង គណបក្សកុម្មុយនិស្តឥណ្ឌូចិនតែប៉ុណ្ណោះ។

**ទី៤៖ សហភាពកុម្មុយនិស្តឥណ្ឌូចិន៖**

គណបក្សកើតនៅខែមករា ១៩៣០។ អ្នកដែលបង្កើតគឺភាគច្រើនជាសមាជិកឆ្វេងនិយមនៃគណបក្សយួនថ្មី។ គោលបំណងរបស់គេ មិនខុសពីគោលបំណង របស់គណបក្សកុម្មុយនិស្តឥណ្ឌូចិននោះប៉ុន្មានទេ។ សមជិកនៃគណបក្សនេះច្រើនជា បញ្ញវន្តដែលទទួលវប្បធម៌ និង អរ្យធម៌បារាំងសែស។ អ្នកដែលខ្នះខ្នែងជាងគេគឺ ដាងថៃម៉ៃ និង យ៉ង្វៀងយ៉ាប់ ។ល។

**ទី៥៖ គណបក្សកុម្មុយនិស្តយួន៖**

ដំណឹងបាក់បែកគ្នានេះបានឮទៅដល់ ង្វៀងអៃកុក។ ពេលនោះ ង្វៀងអៃកុក ឬ ហូជីមិញ នេះ ពួនសម្ងំនៅប្រទេសសៀម។ គាត់ក៏កោះប្រជុំសមជិកធំៗ នៃគណបក្សទាំង៣ ដែលទើបតែបង្កើតនេះ នៅក្រុងហុងកុង កាលពីខែកុម្ភៈ ១៩៣០។ ពេលនោះគាត់បានសម្រុះសម្រួលសមាជិកធំៗ នៃគណបក្សទាំង៣នេះឲលប់គណបក្សខ្លួនចោលទាំងអស់ ហើយគាត់បង្កើតគណបក្សថ្មីមួយជំនួសវិញ។ គណបក្សថ្មីនេះ មានឈ្មោះថា គណបក្សកុម្មុយនិស្តយួន ដែលមានទីស្នាក់ការនៅក្រុងហៃហ្វុង។

**ទី៦៖ គណបក្សកុម្មុយនិស្តឥណ្ឌូចិន៖**

ដើម្បីឲសម្រេចគោលបំណងរបស់គេ ដែលចង់ត្រួតត្រាឥណ្ឌូចិនទាំងមូល ង្វៀងអៃកុក ក៏សំរេចចិត្តជាមួយនិងសហារីជំនិតៗខ្លះ ដូចជា ផាំវ៉ាន់ដុង យ៉ង្វៀងយ៉ាប់ ដាងថៃម៉ៃ ជាដើម ប្តូរឈ្មោះគណបក្សកុម្មុយនិស្តយួន ជាគណបក្សឥណ្ឌូចិនវិញ ក្នុងខែមេសា ១៩៣០។ ការប្រែឈ្មោះនេះ មានន័យវែងឆ្ងាយណាស់។ គេអាចធ្វើសកម្មភាពពេញប្រទេសទាំងឡាយ នៃឥណ្ឌូចិននេះឯង។

គណបក្សកុម្មុយនិស្តឥណ្ឌូចិនក្រោយនេះ ត្រូវបានអន្តរជាតិទី៣ ទទួលស្គាល់កាលពីឆ្នាំ ១៩៣១។ ពេលនោះគណបក្សមានសមាជិកសកម្មជាង ១៥០០ នាក់។

នៅរវាងឆ្នាំ ១៩៣០ នៅក្នុងពិភពលោកទាំងមូល មានវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងបំផុត។ ឆ្លៀតពេលដែលមានវិបត្តិយ៉ាងខ្លាំងនេះ គណបក្សកុម្មុយនិស្តឥណ្ឌូចិន ក៏សម្រេចធ្វើសកម្មភាពយ៉ាងខ្លាំង ដែលគេឲឈ្មោះថា «ចលនាសូវៀត» នៅខែត្រ ង៉ែអាន ដែលជាខែត្រកំណើតរបស់ហូជីមិញ។ ប៉ុន្តែចលនានោះត្រូវបានទ័ពបារាំងបង្ក្រាបវិញយ៉ាងសាហាវ។ សមាជិកគណកម្មការកណ្តាល នៃគណបក្សនៅព្រៃនគរ ត្រូវបារាំងរកឃើញហើយក៏ចាប់យកទៅដាក់គុកនៅកោះត្រឡាច ឬ នៅលើភ្នំបាមីធ្មួក។ ម្យ៉ាងទៀត ង្វៀងអៃកុក ដែលបង្គោលយ៉ាងធំរបស់គណបក្សបានលួចរត់ទៅស្រុកចិន ដែលអង់គ្លេសចាប់បាននៅក្រុងហុងកុង នៅឆ្នាំ១៩៣១ ហើយដាក់គុកនៅទីនោះទៅ។ ដូច្នេះពេលនោះ យើងឃើញថា គណបក្សកុម្មុយនិស្តឥណ្ឌូចិនស្ទើរតែរលាយរូប។

**ទី៧៖ គណបក្សជំទាស់ពេញលេញ៖**

ការពិតគណបក្សកុម្មុយនិស្តឥណ្ឌូចិន មិនរលាយទេ។ ដើម្បីបន្តសកម្មភាពទៅតាមកម្លាំងរបស់ខ្លួន សមាជិកខ្លះ ដែលនៅសល់ ជាពិសេស ត្រាន់វ៉ាន់គ្វោរ បានបង្កើតនៅចុងឆ្នាំ ១៩៣២ នូវគណកម្មការពេញច្បាប់មួយ នៅក្រុងព្រៃនគរ។ គណកម្មការនេះមានអង្គការសារព័តមាន២ សំរាប់បំរើឧត្តមគតិរបស់គេ៖ ទង់ក្រហម និង ទស្សនាវដ្តីកុម្មុយនិស្ត។

## II. រណសិរ្ស របស់ គណបក្សកុម្មុយនិស្ត ឥណ្ឌូចិន

ដើម្បីទ្រទ្រង់សកម្មភាពគណបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលរលាយទៅហើយនោះ ពួកកុម្មុយនិស្តយួនបានបង្កើតជា រណសិរ្សជាច្រើន។

**ទី១៖ រណសិរ្សប្រជាធិបតេយ្យឥណ្ឌូចិន៖** (Front démocratique indochinois)

នៅឆ្នាំ ១៩៣៦ នៅប្រទេសបារាំងឯណោះ ពួកកុម្មុយនិស្តបារាំងបានឡើងកាន់អំណាចក្រោមការដឹកនាំ របស់ ឡេអុងព្លុម។ ឡេអុងព្លុម បានបង្កើត រណសិរ្សមួយឈ្មោះរណសិរ្សប្រជាមានិតុ។ ឆ្លៀតឱកាស ដែលពួកកុម្មុយនិស្តបារាំង ឡើងកាន់អំណាចនេះ ពួកកុម្មុយនិស្តយួន ក៏បង្កើតជារណសិរ្សមួយដែរ ដែលមានឈ្មោះជា រណសិរ្សប្រជាធិបតេយ្យឥណ្ឌូចិន។ រណសិរ្សយួននេះ មានបំណងធំបំផុតគឺ ធ្វើយ៉ាងណាឲពួកកុម្មុយនិស្តបារាំង

ដោះលែងអ្នកទោសនយោបាយជាតិយួន ដូចជា ង្វៀងអៃកុក ផាំវ៉ាន់ដុង ជាដើម។ ប៉ុន្តែ រណសិរ្សនេះត្រូវរលាយខ្លួនទៅវិញជាមួយនឹងរណសិរ្សប្រជាមានិតុបារាំង។

**ទី២៖ រណសិរ្សប្រជាមានិតុរួម៖**

ឆ្នាំ ១៩៣៩ ជាឆ្នាំដែលបារាំង កំពុងតែជាប់ដៃជាមួយនឹងអាឡឺម៉ង់ ក្នុងសង្គ្រាមលើកទី២។ ឆ្លៀតពេលដែលបារាំងកំពុងមានបញ្ហាសង្គ្រាមយ៉ាងធំនេះ ពួកកុម្មុយនិស្តយួន ក៏នាំគ្នាបង្កើត រណសិរ្សប្រជាមានិតុ មួយទៀត ឈ្មោះ រណសិរ្សប្រជាមានិតុរួម។ រណសិរ្សនេះបានរៀបចំធ្វើបាតុកម្ម និង ការបេះបោរ ផ្សេងៗ ជាច្រើន។ បារាំងដែលកំពុងជាប់ដៃធ្វើសង្គ្រាម ជាមួយ អាឡឺម៉ង់ មិនអាចដោះស្រាយបញ្ហាយួន ដែលបង្កើតឡើងដោយរណសិរ្សប្រជាមានិតុរួមនេះបានឡើយ។ អាស្រ័យហេតុនេះហើយ បានជាពួកជនជាតិយួនជាច្រើន ជាពិសេសកម្មករ និង កសិករ នាំគ្នាចូលជាសមាជិកគណបក្សកុម្មុយនិស្តឥណ្ឌូចិន។

**ទី៣៖ រណសិរ្សយៀកមិញ៖** (Front Vietnam Doc Lap Minh)

ង្វៀងអៃកុក ដែលគេស្មានថាតែស្លាប់កាលពីឆ្នាំ ១៩៣២ នៅក្រុងហុងកុង ទៅហើយនោះ ក៏បានលេចមកក្នុងឆាកនយោបាយវិញ ដោយផ្លាស់ឈ្មោះជា ហូជីមិញ។ នៅឆ្នាំ ១៩៤១ ហូជីមិញបានកោះហៅសហការីសំខាន់ៗ របស់គាត់នៅក្នុងគណបក្សកុម្មុយនិស្តឥណ្ឌូចិន ទៅប្រជុំជាសមាជិកនៅក្រុងស៊ិនស៊ី នៃប្រទេសចិន។ សមាជិកនេះក៏បានសម្រេចបង្កើតរណសិរ្សមួយមានឈ្មោះជា អក្សរកាត់ ជា រណសិរ្សយៀកមិញ។ គោលបំណងរបស់គេគឺប្រមូលជនជាតិយួនគ្រប់ជាន់ថ្នាក់ដើម្បី៖

ទី១ - វាតត្បាតលុកលុយកម្ពុជាក្រោម - ប្រទេសខ្មែរ និង លាវ។

ទី២ - ច្បាំងកំចាត់បារាំង ហើយនិង ជប៉ុន។

ដូច្នេះយើងឃើញថា ពួកកុម្មុយនិស្តឥណ្ឌូចិន មានអង្គការប្រយុទ្ធ ខាងនយោបាយផង និងខាងយោធាផង។ ដោយសា រណសិរ្សយៀកមិញនេះ ពួកកុម្មុយនិស្តបានវាតត្បាតពេញប្រទេសទាំងឡាយនៅឥណ្ឌូចិន «យួន-កម្ពុជាក្រោម-ខ្មែរ-លាវ»។

ក្រោយមក នៅថ្ងៃទី ២ កញ្ញា ១៩៤៥ ក្រោយដែលជប៉ុនបានប្រកាសចុះចាញ់ក្នុងសង្គ្រាមលោកលើកទី២ ហូជីមិញ បានប្រកាសឯករាជ្យ ឲប្រទេសយួន និង ប្រកាសបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យយួន។ - ចំណែកព្រះចៅ បៅដោយ ជាទីព្រឹក្សាជាន់ខ្ពស់នៃ

សាធារណរដ្ឋ -។ ពេលនោះ ដើម្បី ឲមានការគាំទ្រពី ប្រទេសចិនប្រជាមានិត អាមេរិកាំង អង់គ្លេស ។ល។ និងពលរដ្ឋយួន ដែលមិនស្រឡាញ់លទ្ធិកុម្មុយនិស្តនោះ ហូជីមិញ ក៍បានប្រកាសលប់គណបក្សកុម្មុយនិស្តចោល កាលពីខែវិច្ឆិកា១៩៤៥។

**សេចក្តីសង្កេត** :

ដើម្បីឲរុស្ស៊ី-ចិនកុម្មុយនិស្ត របស់ ម៉ៅ សេទុង «សមមិត្ត» របស់គាត់មានការទុកចិត្ត ហូជីមិញបានបង្កើត សមាគមមួយជំនួសគណបក្សកុម្មុយនិស្តឥណ្ឌូចិន។ សមាគមនោះឈ្មោះ សមាគមឥណ្ឌូចិន ខាងសិក្សា លទ្ធិមាក្ស (Association Indochinoise pour les Etudes Marxistes) ដែលមានសកម្មភាពដូចគណបក្សកុម្មុយនិស្តឥណ្ឌូចិនដដែល។ ម្យ៉ាងទៀត អ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រជាច្រើន បានសំគាល់ថា ឆ្នាំ១៩៤១ គឺជាឆ្នាំដែលសង្គ្រាមឥណ្ឌូចិនទី១ ចាប់ផ្តើមឡើងជាដំបូង។ ហេតុថា ពួកយៀកមិញបានធ្វើការលុកលុយប្រទេសទាំងឡាយនៅឥណ្ឌូចិន។

**ទី៤៖ រណសិរ្សលៀចវៀត ១៩៤៦៖**

ខែមករា ១៩៤៦ ហូជីមិញ បានជាប់ឆ្នោតជា ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាធិបតេយ្យយួន។ ពេលនោះ ហូជីមិញ បានរៀបចំធ្វើជា រណសិរ្ស បង្រួបបង្រួមជាតិមួយ ឈ្មោះជា រណសិរ្សលៀចវៀត។ គណបក្សនយោបាយធំឯទៀតជាច្រើនបានចូលទៅក្នុងរណសិរ្សលៀចវៀតនេះផងដែរ។ ចាប់តាំងពីពេលនេះមកហើយ ដែលគេឃើញរដ្ឋាភិបាល របស់ហូជីមិញ ចាប់ផ្តើមរៀបចំអនុវត្តន៍ នូវនយោបាយរបស់ខ្លួន ឲប្រទេសទៅតាមកម្មវិធីរបស់គណបក្សកុម្មនិស្តឥណ្ឌូចិន គឺ៖

- ទាមទារដីកម្ពុជាក្រោម

- ឯករាជនឹងឯកភាពយួន

- ដេញបារាំងពីឥណ្ឌូចិន

- ត្រួតត្រាឥណ្ឌូចិនជំនួសបារាំង។

ក្នុងការទាមទារដីកម្ពុជាក្រោមនេះ ហូជីមិញ បានប្រើកលល្បិចយ៉ាងប៉ិនប្រសប់បំផុត។ ខ្មែរយើងមិនទាំងដឹងខ្លួនស្រួលបួលផង ហូជីមិញ បានចុះហត្ថលេខាលើសេចក្តីព្រមព្រៀងជាមួយបារាំងចំនួនបីលើករួចជាស្រេចទៅហើយគឺ៖

- សេចក្តីព្រមព្រៀងនៅហាណូយ ចុះថ្ងៃទី ៦មិនា ១៩៤៦។ សេចក្តីព្រមព្រៀងនេះជាលទ្ធផលនៃការចរចារយ៉ាងស្វិតស្វាញរវាង ហូជីមិញ នឹងបារាំងអំពីបញ្ហាកម្ពុជាក្រោម ឯករាជ្យ ឯកភាពយួន ។ល។

- សេចក្តីព្រមព្រៀងក្រុងដាឡាត់ ចុះថ្ងៃទី ២៤ មេសា ១៩៤៦។ សេចក្តីព្រមព្រៀងនេះ ជាលទ្ធផល នៃសន្និសីទក្រុងដាឡាត រវាង គណប្រតិភូបារាំង នឹងគណប្រតិភូយៀកមិញ ស្តីអំពីការអនុវត្តន៍ នូវសេចក្តីព្រមព្រៀងចុះថ្ងៃទី ៦ មិនា ១៩៤៦។

- សទ្ធិសញ្ញាបណ្តោះអាសន្ន (Modus Vivendi) នៅក្រុងហ្វុងតែណឺប្លូ ចុះថ្ងៃទី១៤កញ្ញា ១៩៤៦។

សទ្ធិសញ្ញាបណ្តោះអាសន្ននេះ បានមកពីសន្និសីទមួយយ៉ាងយូរ និង យ៉ាងលំបាក រវាងយួននឹងបារាំង ស្តីអំពីកម្ពុជាក្រោម ឯករាជ្យ និង ឯកភាពយួន បញ្ហាសហពន្ធឥណ្ឌូចិន ។ល។

គួរកត់សំគាល់ថា សេចក្តីព្រមព្រៀង ឬ សទ្ធិសញ្ញាបណ្តោះអាសន្នទាំង៣លើកនេះសុទ្ធតែជាបញ្ហា ដែលទាក់ទង មកនឹង ប្រទេសខ្មែរទាំងអស់ ប៉ុន្តែគេចុះហត្ថលេខាមិន៨ខ្មែរយើងចូលរួមជាមួយផងទេ គឺគេដើរ «ខ្សែរលើ» លើយើងរហូត។ នេះហើយជាកលល្បិចមួយរបស់កុម្មុយនិស្តឥណ្ឌូចិនក្នុងការរៀបគ្រូតត្រាប្រទេសទាំងអស់នៅឥណ្ឌូចិន។ មកដល់ត្រង់នេះ យើងឃើញថាយៀកមិញបានប្រើល្បិចខ្លះទៀតក្រៅផ្លូវច្បាប់។

ម្យ៉ាងទៀតដោយហេតុថា គោលបំណងរបស់គេខាងលើនេះ មិនបានសម្រេច ពួកកុម្មុយនិស្ត ក៏បានចាប់ផ្តើមវាយបារាំងចេញមុខមែនទែន តាំងពីថ្ងៃ ១៩ ធ្នូ ១៩៤៦។ ក្នុងការប្រយុទ្ធជាមួយបារាំងនេះ វណសិរ្សលៀចរៀតបានដើរតួរយ៉ាងសំខាន់នៅក្នុងប្រទេសយួន ចំណែកពួកយៀកមិញ វិញ គេខំប្រឹងប្រែងយ៉ាងសម្ងៀម នៅកម្ពុជាក្រោម នៅប្រទេសខ្មែរ និង លាវ។

ចម្បាំង រវាង យួន នឹងបារាំងបានចប់ (ក្រោយដែលបារាំងចាញ់នៅ ឌៀងប្រៀងភូកាល ពីពីថ្ងៃ ៧ ឧសភា ១៩៥៤) ដោយសន្និសីទក្រុង ហ្សឺណែវ ស្តីអំពីបញ្ហាឥណ្ឌូចិនដែលបានបញ្ចប់កិច្ចការរបស់ខ្លួននៅ ថ្ងៃ ២០ កក្កដា ១៩៥៤ ដោយចែកប្រទេសយួនជា ២ តាមបណ្តោយខ្សែស្របទី១៧។

## III. សង្គ្រាមឥណ្ឌូចិនទី១ នៅប្រទេសខ្មែរ និង លាវ

ប្រទេសខ្មែរ ជាគោលដៅមួយធំរបស់ ពួកកុម្មុយនិស្តយួន ក្នុងការចង់ត្រួតត្រាឥណ្ឌូចិន ជំនួសបារាំង។ គណបក្សកុម្មុយនិស្តឥណ្ឌូចិន បានបញ្ជូនក្របខ័ណ្ឌកុម្មុនិស្ត ឲមកក្នុងប្រទេសទាំង២ (ខ្មែរ-លាវ) នេះតាំងពីឆ្នាំ ១៩៤១ម្លេះ (ឆ្នាំដែល ហូជីមិញបង្កើត រណសិរ្សយៀកមិញ)។

ប៉ុន្តែយោធាចេញមុខរបស់គេបានចាប់ផ្តើមពីឆ្នាំ ១៩៤៧ នៅជុំវិញទន្លេសាប បប៉ៃលិន កណ្តាល តាកែវ កំពត ។ល។ ក្នុងការដែលគេធ្វើសកម្មភាពយោធានេះ គេខំធ្វើការឃោសនាថា គេបានជួយខ្មែរក្នុងការដេញបារាំងឲទៅស្រុកវិញ។ ដោយការប្រសប់ក្នុងការរើសប្រធានឃោសនានេះ (Thème de propagande) ខ្មែរយើងនៅជនបទនានាខ្លះបានភាន់ច្រឡំជួយពួកកុម្មុយនិស្តយ៉ាងពេញដៃពេញជើង។

ឆ្នាំ ១៩៤៨ សក្តិ៥ យៀកមិញម្នាក់ឈ្មោះ ងៀងថាន់សឺន ដែលជាស្នងការនយោបាយរបស់យៀកមិញ ប្រចាំភូមិភាគណាំបូ (NAM BO) គឺតំបន់កម្ពុជាក្រោម បានប្រកាសច្បាំងជាមួយនឹងប្រទេសខ្មែរជាផ្លូវការ។

គួរយើងចែកសកម្មភាពឃោសនារបស់ យៀកមិញនៅក្នុងប្រទេសខ្មែរយើង ជា២ ដំណាក់ការ គឺមុន ខែ វិច្ឆិកា ១៩៥៣ និងក្រោយខែ វិច្ឆការ ១៩៥៣។

- មុនខែ វិច្ឆកា ១៩៥៣ : យៀកមិញបានធ្វើសកម្មភាពយោធាទូទៅពេញទាំងប្រទេស ជាពិសេសនៅជំវិញទន្លេសាប និងនៅប៉ៃលិន។ បានសេចក្តីថា គេមិនទាន់សម្រេចគោលដៅណាឲបានច្បាស់លាស់នៅឡើយទេ។

- ក្រោយខែ វិច្ឆកា ១៩៥៣ : លុះដល់ពេលក្រោយដែលបារាំងប្រគល់មេបញ្ជាការជាន់ខ្ពស់នៃកងទ័ពទាំងមូលឲខ្មែរហើយ (គឺទ័ពបារាំងបានដកថយទៅស្រុកវិញ) ពួកយៀកមិញដែលបានធ្វើការឃោសនាថា មកជួយដេញបារាំងនោះ ក៏បានធ្វើសកម្មភាពសឹក យ៉ាងខ្លាំងនៅក្នុងប្រទេសខ្មែរ តំបន់ភាគខាងកើតនៃទន្លេមេកុង។ ភស្តុតាងគឺពីខែ មិនា ដល់ ឧសភា ១៩៥៤ គេវាយ ហើយកាន់កាប់ទីតាំងទ័ពខ្មែរយើងនៅៈ វ៉ឺនសៃ សៀមប៉ាង បកែវ ជំវិញទីរួមខែត្រស្ទឹងត្រែង ឆ្លងលើ «ស្រែជេស» ព្រែកទេ ។ល។

តែដោយសារការឆ្លាតវៃ នៃកងទ័ពជាតិខ្មែរ ទ័ពខ្មែរបានវាយរុញច្រានពួកនេះឲត្រឡប់ទៅស្រុកវិញទៅ។ ស្របពេលជាមួយគ្នានេះ សន្និសីទក្រុងហ្សឺណែវ ៥៤ ក៏បានជួយដេញយៀកមិញឲចេញពីប្រទេសខ្មែរដែរ។

ចំណែកប្រទេសលាវវិញ ពួកយៀកមិញ បានធ្វើសកម្មភាព មិនខុសពីប្រទេសខ្មែរយើង ប៉ុន្មានទេ ប៉ុន្តែតាំងពីឆ្នាំ ១៩៤៦មក រហូតដល់ទស្សវត្សន៍ ទី៧០ ពួកយៀកមិញបាន កាន់កាប់ខែត្រលាវខ្លះ ដូចជាៈ ខុងសាលី សាមនឿ ខាំម៉ុន សុវណ្ណខែត្រ ជាដើម។

សន្និសីទ ក្រុងហ្សឺណែវ ១៩៥៤ បានបញ្ចប់នូវសកម្មភាព យោធា ចេញមុខ របស់កុម្មុយ និស្តយួន ឬ ទតណ្ឌូចិននេះ។

## IV. សង្គ្រាមឥណ្ឌូចិនទី២ ឬ រណសិរ្សសេរីការជាត

សង្គ្រាម ឥណ្ឌូចិន បានរលត់ទៅវិញ ដោយធ្វើឲពួកកុម្មុយនិស្តយួន បានសម្រេចគោល បំណងខ្លះមិនបានសម្រេចខ្លះ។

<u>គោលបំណងបានសម្រេចគឺៈ</u>

- បានដីកម្ពុជាក្រោមជាស្ថាពរហើយ,

- ប្រទេសយួនបានឯករាជ្យពេញលេញ,

- បារាំងចាកចេញពីឥណ្ឌូចិន។

<u>គោលបំណងដែលមិនទាន់បានសម្រេចគឺៈ</u>

- ត្រួតត្រាឥណ្ឌូចិនទាំងមូលជំនួសបារាំង,

- ឯកភាពនៃជនជាតិយួន។

ដើម្បីសម្រេចនូវគោលបំណងចុងក្រោយនេះ ពួកកុម្មុនិស្តយួននេះ គេត្រូវតែបង្ករ បង្កើតឲមានសង្គ្រាមឥណ្ឌូចិននេះឡើងវិញ។

សូមបញ្ជាក់ថា នៅឆ្នាំ ១៩៥៤ ហូជីមិញ គាត់បានលប់ «សមាគមឥណ្ឌូចិនខាងសិក្សាមា ក្ស» ចោល ហើយបង្កើត គណបក្ស ឈ្មោះថា «គណបក្សការងារ» ជំនួសវិញ។ គណបក្ស ការងារនេះហើយ ដែលជា គណបក្សធំតែមួយរបស់យួនខាងជើងក្នុងជំនាន់នោះ។

លុះដល់ថ្ងៃ ២១ ធ្នូ ១៩៦០ គណបក្សការងារនេះក៏សម្រេចបង្កើតរណសិរ្សមួយឈ្មោះថា «រ ណសិរ្សសេរីការជាតិ» (Front National de Libération ou FNL) ដែលយើងធ្លាប់ឲឈ្មោះ ថា «យៀកកុង»

ហូជីមិញ បង្កើតរណសិរ្សនេះឡើង ដើម្បីនឹងបង្កាត់សង្គ្រាមឥណ្ឌូចិននេះឲវាឆេះឡើងវិញ។ សង្គ្រាមនេះហើយ ដែលយើងឲឈ្មោះថា សង្គ្រាមឥណ្ឌូចិនទី២នោះ។

សង្គ្រាមដំបូងឡើង ហូជីមិញ ធ្វើឲផ្ទុះនៅក្នុងប្រទេសយួនខាងត្បូង និង លាវ។ បន្ទាប់មក ពួកកុម្មុយនិស្តយួនបាន «បោក» សម្តេច សីហនុ ហើយក៏តាំងទ័ពរបស់ខ្លួននៅក្នុងខែត្រខ្មែរទាំងឡាយ ដែលមានព្រំដែនជាប់នឹងយួន ដោយមានការយល់ព្រមពី ស្តេច សីហនុ ដែលពេលនោះ ធ្វើជាប្រមុខរដ្ឋខ្មែរផង។ បានសេចក្តីថាយួនកុម្មុយនិស្ត បានច្បាំងជាមួយខ្មែរ តាំងពីថ្ងៃ២០ ធ្នូ ១៩៦០ ម្លេះ តែខ្មែរហាក់បីដូចជាមិនទាន់ដឹងខ្លួនសោះ។

លុះក្រោយព្រឹត្តិការណ៍ ថ្ងៃទី ១៨ មិនា ១៩៧០ សង្គ្រាមឥណ្ឌូចិនទី២ នេះក៏ផ្ទុះឡើងយ៉ាងខ្លាំង ស្របទៅតាមគោលបំណងរបស់កុម្មុយនិស្តយួន នៅក្នុងប្រទេសខ្មែរ។ - **ទាំងនេះហើយជាកលល្បិចប្លន់ទឹកដី របស់កុម្មុយនិស្តយួន ឬ ឥណ្ឌូចិន** - ។

## សង្គ្រាម មហាជន

រហូតមកដល់សព្វថ្ងៃនេះ យួនកុម្មុយនិស្ត គេ បំពាក់បំប៉ន ក្នុង សតិយុវជនខ្មែរ ថាសង្គ្រាមតស៊ូ របស់ សាធារណរដ្ឋខ្មែរ ប្រឆាំង និង គេ ជា សង្គ្រាម លន់-នល់ អាយ៉ង អាមេរិកាំង ឬ ពួកក្បត់នឹង សម្តេច សីហនុ។ ព្រឹត្តិការណ៍ ថ្ងៃទី ១៨ មិនា ឆ្នាំ ១៩៧០ ជារដ្ឋប្រហារ ដែលមាន CIA នៅពីក្រោយ។ ដោយពួកវា ជាអ្នកមានជ័យជំនះ ពាក្យទាំងនោះ ដែលពួកវានិយាយរាល់ថ្ងៃ វាក្លាយទៅជាការពិត សំរាប់ខ្មែរ បច្ចុប្បន្ន និង ពួកបញ្ញាវន្តឆ្វេងនិយម នៅក្នុងពិភពលោក។ តែខ្មែរយើងភាគច្រើន ឥតបានគិតពិចារណាថា ក្រោយពីរបប សាធារណរដ្ឋខ្មែរ តើនរណាជាឈ្នះពិតប្រាកដនៅស្រុកខ្មែរៈ ពួកខ្មែរក្រហម, សម្តេច សីហនុ, ពួក ហ៊ុន-សែន ? អ្នកឈ្នះពិត គឺ យួនកុម្មុយនិស្ត ដែលសុទ្ធជា សមមិត្តនឹង ប៉ុល-ពត សិហនុ និង ហ៊ុន-សែន។ យួនគេកំពុង សរសេរប្រវត្តិសាស្ត្រសំរាប់ឲយុវជនសិក្សា ដែលមាន លោក ហូ-ជីមិុញ ជាបិតា ឥណ្ឌូចិន គឺ មហាយៀកណាម ហើយប្រវត្តិសាស្ត្រគេចាប់ផ្តើម ផ្សាយតាមការនិយាយពីមាត់មួយទៅមាត់មួយនៅក្នុងសហគមន៍យួន ដែលកើត និង មករស់នៅស្រុកខ្មែរ ដើម្បី ឲយួនសញ្ជាតិកម្ពុជាក្តី មិនទាន់មានសញ្ជាតិក្តី ឲមានជំនឿថា ទឹកដីខ្មែរនេះ ជាទឹកដី ដូនតារបស់គេដែលខំតស៊ូយកបាន ហើយធ្វើអាជីវកម្ម ដើម្បីចិញ្ចឹមជីវិត ជនជាតិយួន។ ជាពិសេស គេឲជនជាតិយួនទុកខ្មែរ ជា អ្នកជំពាក់គុណ ដល់ ឪម៉ែ គេ ដែលចូលមកធ្វើសង្គ្រាម រំលាយរបប

ប្រល័យពូជ ឈ្មោះ ខ្មែរក្រហម។ គុណនេះ ជាគុណលុបមិនបាន ព្រោះជាការស្រោចស្រង់ជីវិតដល់ខ្មែរ ដូច្នេះ ខ្មែរ ត្រូវតែសងបំណុលពលិកម្មយួន គ្មានថ្ងៃបញ្ចប់។

សង្គ្រាម របស់ សាធារណរដ្ឋខ្មែរ មានធាតុជា សង្គ្រាម មហាជន ព្រោះជាសង្គ្រាមរំដោះជាតិ ដែល យួនកុម្មុនិស្ត ជាអ្នកបំពាន មកលើ បូរណភាពទឹកដីខ្មែរ។ តែយើងអាចសួរជាសំណួរថា តើសាធារណរដ្ឋខ្មែរ អាចមានលទ្ធភាព និង សមត្ថភាព ទទួលកាន់កាប់ សង្គ្រាមនេះបានដែរ ឬទេ ក្នុងឋានៈខ្លួនជា របបនយោបាយ ទទួលខុសត្រូវលើវាសនាជាតិ ? ចំណុចនេះហើយដែលខ្ញុំលើកយកពិនិត្យ ហើយជូនជាយោបល់ ក្នុងនាមជាកូនខ្មែរ ដែលជាសក្សីដែលបានឃើញនឹងភ្នែក ដូចខ្មែរ ដ៏ទៃទៀត នូវការវិវត្តន៍រាល់ថ្ងៃ នៃសង្គ្រាម ផង និង នយោបាយផង ពីឆ្នាំ ១៩៧០ ដល់ ឆ្នាំ ១៩៧៥។

**អ្វីជា សង្គ្រាម មហាជន ?**

នៅទីនេះ ខ្ញុំមិនលើកយក និយមន័យ នៃសង្គ្រាមមហាជន របស់ពួកកុម្មុនិស្តមកអធិប្បាយនោះឡើយ ព្រោះមកដល់ពេលនេះ ពាក្យសង្គ្រាមមហាជនរបស់ពួកនេះ គ្រាន់តែ យកពាក្យ មហាជន មកបោកប្រាស់ ប្រជាជនតែប៉ុណ្ណោះ ព្រោះ គេសង្កេតឃើញថា នៅទីកន្លែងណា ដែលមានលទ្ធិកុម្មុយនិស្ត ជារបបនយោបាយដឹក នៅទីនោះតែងតែមានការសម្លាប់រង្គាលជានិច្ច ហើយចំនួនជនគ្រោះនឹងរបបនេះនៅក្នុង ពិភពលោកមានប្រមាណ ១០០ លាននាក់ រហូតដល់គេទុក របបកុម្មុយនិស្ត ជារបប មានភាគឃោឃៅ ជាង របបណាស៊ី របស់ Hitler ទៅទៀត។

និយមន័យ នៃសង្គ្រាមមហាជន របស់រដ្ឋាភិបាលស្របច្បាប់ ជាការប្រយុទ្ធដើម្បីការពារជាតិ និង ការពារប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋ និង ដើម្បីប្រជាពលរដ្ឋ ដែលមានថេរវេលាយូរ។ ក្នុងការប្រយុទ្ធនេះត្រូវ រដ្ឋាភិបាល ដឹកនាំកងទ័ព វាយប្រហារខ្មាំងនិងដឹកនាំ មហាជន ជាក្រុមក្ដី ឬ នៅដាច់តែឯងក្ដី ដើម្បី ការពារ ភូមិស្រុកក្រុង របស់ខ្លួន ហើយបើមានឱកាស វាយខ្មាំងជាតិ តែម្ដង។ ក្នុង គោលដៅនេះ រដ្ឋាភិបាលត្រូវគាំទ្រមហាជន ទាំងផ្នែកសម្ភារៈ ឬ ផ្នែក គំនិត ដើម្បី ឲមហាជនក្លាយជាកម្លាំងតស៊ូការពារទឹកដី ពាសពេញប្រទេស។ សង្គ្រាមនេះ ជាសង្គ្រាមមួយបែប ក្នុងបណ្ដាសង្គ្រាមទាំងឡាយ ដែលប្រើនូវកម្លាំង តែកម្លាំង មិនសំដៅទៅលើតែកម្លាំងទ័ពនោះទេ តែជាកម្លាំងរបស់ពលរដ្ឋ ដែលជាអ្នកស្នេហាជាតិ ទទួលការហ្វឹកហ្វឺនខាងផ្នែកយោធា ហើយមានអង្គការចាត់តាំងដ៏ត្រឹមត្រូវ ដើម្បីគ្រប់គ្រងកម្លាំង ពុំនោះទេ កម្លាំងនេះនឹងក្លាយជាកម្លាំង

អនាធិបតេយ្យ នៅក្នុងយុទ្ធសាស្ត្រ សង្គ្រាម ដែលមានកម្លាំងទ័ព ជាអ្នកវាយលុកសត្រូវ។ នៅក្នុងដំបន់ដែលសត្រូវកាន់កាប់។

នៅក្នុង មហាជន មានកម្លាំងជាច្រើន ដូចយ៉ាង កម្លាំង កសិករ កម្មករ អ្នករដ្ឋការ យុវជន និង អ្នកចេះដឹង ដែលជាកម្លាំងចាំបាច់ ស្មគ្រចិត្ត ចូលរួមធ្វើសង្គ្រាមការពារជាតិ តែនៅក្នុងកម្លាំងនេះ អាចមាន អ្នកប្រឆាំង ដោយចាញ់បោកខ្មាំង ចូលបំរើខ្មាំងនោះដែរ ដូច្នេះ អង្គការ ដឹកនាំសង្គ្រាម ត្រូវចេះញែកឲ្យច្បាស់ឲដឹងនរណាជាមិត្ត នរណាជាអ្នកប្រឆាំង តែត្រូវតាំងក្នុងចិត្ត ថាអ្នកប្រឆាំង មិនមែនជាខ្មាំងនឹងខ្លួននោះឡើយ គឺគ្រាន់តែ ជាអ្នក ជួនកាលត្រូវខ្មាំងបង្ខំ ជួនកាល ខ្វះដំណឹងការពិត នាំខ្លួនឲជឿខ្មាំងប្រឆាំងនឹងជាតិឯង។ ដូច្នេះ អង្គការដឹកនាំសង្គ្រាម ត្រូវមាន វិធានការច្បាស់លាស់ដើម្បីប្រសិទ្ធិភាព នៃសង្គ្រាម។ ផែនការមានដូចនេះ៖

**១. អង្កេត**

បើចង់ឲការអង្កេតទៅលើមហាជនមានប្រសិទ្ធិភាព គ្រោងការអង្កេតត្រូវមើលឲគ្រប់ជ្រុងជ្រោយ ទាំងស្ថានបច្ចុប្បន្ន ទាងនិន្នាការរបស់មហាជន។ ការយល់ច្រឡំ ជា អបការ (កំហុស) មួយ មិនអាចកែបាន ព្រោះ វានាំឲអ្នកប្រឆាំង ក្លាយទៅជាសត្រូវពោពេញទៅដោយគំនុំ និង ការសងសឹក។

**២. ឃោសនា និង ការរៀបចំ**

ឃោសនា និង ការរៀបចំ ជាអាវុធពីរសំខាន់ណាស់។ ការឃោសនា សំរាប់សម្រួលការរៀបចំត្រូវការអ្នកមានការចេះដឹងនយោបាយ ចិត្តសាស្ត្រ សង្គមសាស្ត្រ និងប្រវត្តិសាស្ត្រជាតិ ច្បាស់លាស់។ កិច្ចការនេះ ជាកិច្ចការ របស់ អ្នកឯកទេស នៃសង្គ្រាមនយោបាយ។

**៣. ទិសដៅនៃការអប់រំ**

ក្នុងការដឹកនាំ មហាជន គោងធ្វើការអប់រំ។ ការអប់រំ ត្រូវមានលក្ខណៈ ជាការអប់រំផ្នែកខាងបច្ចេកទេស អប់រំឲមហាជន អាចរស់បានដោយខ្លួនឯង។ ការផ្តល់អំណោយជាលុយកាក់ ឬ ជា សម្ភារៈ ដល់មហាជនសម្រាប់ទាក់ទាញទឹកចិត្តមហាជន ជាការល្អហើយ តែពុំមានលក្ខណៈស្ថិតស្ថេរទេ។ ឧបមាយើងឲត្រីងៀត ឬ ប្រហុក ទៅមហាជន គាត់សប្បាយណាស់ តែដល់អស់ គាត់សុំទៀត សុំម្តងពីរដងមិនបាន មហាជន ច្បាស់ជាខឹង នាំឲខ្មាំងឈ្លានឱកាស ធ្វើឃោសនាបោកប្រាស់មហាជន ព្រោះកំហឹងជា កត្តា អាចនាំឲមនុស្សបាត់ ការពិចារណា រកខុសត្រូវ។

### ៤. ការប្រមូលមហាជន

បើចង់ឲមហាជន ចូលរួម ក្នុងសង្គ្រាម លុះត្រាតែ អ្នកដឹកនាំមហាជន មានការសម្រេចចិត្តឲបានច្បាស់លាស់ មិនរត់ចោលមហាជន ហើយសុខចិត្តស្លាប់ជាមួយមហាជន។ កាលណាទឹកចិត្ត អ្នកដឹកនាំមហាជន មានកំរិតខ្ពស់ រស់ជាមួយមហាជន ពេលនោះហើយដែលនាំសម្រេចនូវជោគជ័យ នៃសង្គ្រាមមហាជន។

ផែនការដែលរៀបរាប់ខាងលើនេះហើយ ដែល សាធារណរដ្ឋខ្មែរ យកមកធ្វើជាលទ្ធិនយោបាយ ធ្វើសង្គ្រាមមហាជន ដើម្បីរំដោះជាតិ ពីការឈ្លានពាន នៃយួនកុម្មុយនិស្ត។ សង្គ្រាមនេះ ចុះនាម (s'inscrit) ក្នុង «ដំណើរខ្មែរថ្មី» គឺ រំដោះជាតិផង និង ធ្វើបដិវត្តន៍ជាតិផង ដែលមានលក្ខណៈ ខុសពីបដិវត្តន៍ កុម្មុយនិស្ត ព្រោះបដិវត្តន៍ជាតិ ជាបដិវត្តន៍ដើម្បីដាំ លទ្ធិប្រជាធិបតេយ្យសេរី នៅក្នុងសង្គមខ្មែរ ក្នុងគោលការណ៍តែមួយគត់ គឺបំរើ ប្រយោជន៍ ប្រជាពលរដ្ឋ និង ប្រយោជន៍ជាតិ។

សួរថា តើ ក្នុង ខែ កក្កដា ឆ្នាំ ១៩៧០ លោក លន់-នល់ មានមធ្យោបាយ គ្រប់គ្រាន់ដើម្បីបើកធ្វើប្រតិបត្តិការសឹក វាយលុក ដណ្តើម ទឹកដី ដែលពួក យៀកកុង កាន់កាប់ ដែរឬទេ ?

### ៤. ដំណាក់ការ វាយលុក

**មានបន្ត**



# នៅមានបន្ត